# សុន្ទរកថា

## របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
## នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ស្តីពី

# «យុទ្ធសាស្ត្រចតុកោណ»

## *ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព នៅកម្ពុជា*
## ដំណាក់កាលទី ២

ថ្លែងនៅក្នុងអង្គប្រជុំគណៈរដ្ឋមន្ត្រីលើកទី ១

នីតិកាលទី ៤ នៃរដ្ឋសភា

NCDD Library
001057

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០០៨

*ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេ- ខាធិការ ដែលជាសមាជិក- សមាជិកានៃអង្គគណៈរដ្ឋមន្ត្រីទាំងមូល ជាទីមេត្រី !*

**1.** ថ្ងៃនេះ គឺជាទិវាប្រវត្តិសាស្ត្រដ៏សំខាន់មួយរបស់កម្ពុជា ដែលរាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី ៤ នៃរដ្ឋសភា បានបើកកិច្ចប្រជុំពេញអង្គរបស់ខ្លួនជាលើកទី ១ ។ ក្នុងនាមជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ខ្ញុំសូមសំដែងការស្វាគមន៍ និង ពរសព្ទសាធុការយ៉ាងកក់ក្តៅបំផុតជូនចំពោះឯកឧត្តម និង លោកជំទាវទាំងអស់ ដែលជាសហសេវិក ក្នុងរាជរដ្ឋាភិបាល សម្រាប់នីតិកាលទី ៤ នៃរដ្ឋសភា ។

**2.** ជាបឋម ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ជូនដល់ជនរួមជាតិទាំងអស់ ដែលបានផ្តល់នូវទំនុកចិត្តដល់រូបខ្ញុំ តាមរយៈលទ្ធផលនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៨ កន្លងទៅនេះ ដើម្បីឱ្យខ្ញុំមានលទ្ធភាពបម្រើជាតិមាតុភូមិ ក្នុងឋានៈជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា សម្រាប់នីតិកាលទី ៤ នៃរដ្ឋសភា បន្តទៅទៀត ។ ការបោះឆ្នោតនាថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៨ កន្លងមក គឺជាការបោះឆ្នោតមួយដែលមានលក្ខណៈសេរី យុត្តិធម៌ ត្រឹមត្រូវ និង មានតម្លាភាព ហើយត្រូវបានទទួលស្គាល់ថា ជា ***«អច្ឆរិយៈរបស់នៃនយោបាយខ្មែរ»*** ម្តងទៀត ។ រាជរដ្ឋាភិបាលថ្មី ដែលបានប្រសូត្រឡើង ស្របតាមឆន្ទៈរបស់ប្រជាជនកម្ពុជា បានឈានចូលកាន់តំណែងក្នុងនីតិកាលទី ៤ នៃរដ្ឋសភា ជាមួយនឹងភាពស្វាហាប់ និង ការប្តេជ្ញាចិត្តយ៉ាងពេញទំហឹង ដើម្បីកសាង និង អភិវឌ្ឍន៍ប្រទេសជាតិមាតុភូមិ ។

***3.*** ខ្ញុំសូមយកឱកាសនៃអង្គប្រជុំគណៈរដ្ឋមន្ត្រីលើកទី ១ របស់យើង ដើម្បីប្រកាសជូនជនរួមជាតិកម្ពុជា និងដៃគូអភិវឌ្ឍន៍ទាំងអស់ ឱ្យបានជ្រាបអំពីអាទិភាព

គោលនយោបាយសំខាន់ៗរបស់រាជរដ្ឋាភិបាល សម្រាប់នីតិកាលថ្មី និង អំពីការប្តេជ្ញាចិត្តយ៉ាងមោះមុតឥតងាករេរបស់រាជរដ្ឋាភិបាលទាំងមូល ក្នុងការបន្តអនុវត្តកម្មវិធីកំណែទម្រង់តាមមុខព្រួញសំខាន់ៗ ក្នុងគោលដៅបម្រើនូវឧត្តមប្រយោជន៍របស់ប្រទេសជាតិមាតុភូមិ និង ឆ្លើយតបទៅនឹងសំណូមពរ និង សេចក្តីត្រូវការទាំងឡាយរបស់ប្រជាជនកម្ពុជា ដែលរាជរដ្ឋាភិបាលបានទទួល តាមរយៈសម្លេងឆ្នោតផ្តល់ការទុកចិត្តក្នុងដំណើរការបោះឆ្នោតដោយសេរី និង យុត្តិធម៌ លើកទី ៤ នេះ ។

4. ខ្ញុំនៅតែចាត់ទុកថា កំណែទម្រង់ គឺជាកិច្ចការស្លាប់រស់របស់កម្ពុជា ។ ក្នុងន័យនេះ កម្ពុជាគ្មានជម្រើសអ្វីផ្សេង ក្រៅពីការបន្តជំរុញអនុវត្តយ៉ាងម៉ឺងម៉ាត់ និង ហ្មត់ចត់បំផុតនូវកំណែទម្រង់ទាំងឡាយ ដែលបានដាក់ចេញកន្លងមកនេះ ឱ្យបានកាន់តែទូលំទូលាយ និង ស៊ីជម្រៅថែមទៀត ដែលជាលក្ខខណ្ឌចាំបាច់បំផុតសម្រាប់ធានាបាននូវប្រសិទ្ធភាព និង ភាពស័ក្តិសិទ្ធិ ក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ច ក្នុងកម្រិតខ្ពស់ និង ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។ ជាការពិតទស្សនាទាននេះ កំពុងតែឆ្លុះបញ្ចាំងនូវភាពត្រឹមត្រូវ និង ភាពពេញលេញរបស់ខ្លួន ក្នុងសភាពការណ៍ពិភពលោក និង សភាពការណ៍កម្ពុជាបច្ចុប្បន្ន ។

5. ក្នុងស្មារតីនេះ រាជរដ្ឋាភិបាល បានយក ***«កម្មវិធីនយោបាយ»*** របស់ខ្លួននៃនីតិកាលទី ៤ នៃរដ្ឋសភា ដែលត្រូវបានតាក់តែងឡើង និង អនុម័ត ដោយផ្អែកលើការវាយតម្លៃលទ្ធផលការងារដែលបានអនុវត្តក្នុងនីតិកាលទី ៣ និង ដោយផ្អែកលើឆន្ទៈ និង បំណងប្រាថ្នារបស់ប្រជាជន ព្រមទាំងផ្អែកលើបរិការណ៍ជាតិ និង អន្តរជាតិ មកធ្វើអាទិភាវូបនីយកម្មនូវបណ្តាអាទិភាព ដែលត្រូវបានដាក់ចេញមក ហើយរៀបចំលម្អិត សម្រិតសម្រាំង សម្រួចបន្ថែម សំដៅរំលេចឱ្យចេញរបៀប

វារៈគោលនយោបាយសង្គម- សេដ្ឋកិច្ចរបស់កម្មវិធីនយោបាយនេះ និង ឱ្យចេញជាកញ្ចប់អាទិភាពនៅតាមបណ្ដាវិស័យសំខាន់ៗនានា ដែលមានលក្ខណៈជាប្រព័ន្ធស៊ីសង្វាក់ ប្រទាក់ក្រឡាគ្នា និង យោងគ្នាទៅវិញទៅមក សម្រាប់ជាមូលដ្ឋានទាំទៅសម្រេចឱ្យបាននូវចក្ខុវិស័យរួមរបស់ជាតិ ។ ដូច្នេះ របៀបវារៈគោលនយោ-បាយសង្គម- សេដ្ឋកិច្ចនេះ គឺជាសេចក្ដីប្រកាសអំពីបេសកកម្ម និង ការប្ដេជ្ញាចិត្តយ៉ាងម៉ឺងម៉ាត់របស់រាជរដ្ឋាភិបាល ក្នុងសកម្មភាពកែទម្រង់ ដើម្បីពង្រឹងគុណភាពអភិបាលកិច្ច និង ទ្រទ្រង់កំណើនសេដ្ឋកិច្ចក្នុងកម្រិតខ្ពស់ ដែលជាកត្តាដ៏ចាំបាច់បំផុត សម្រាប់ធានាចីរភាពនៃការអភិវឌ្ឍ និង ការកាត់បន្ថយភាពក្រីក្រ ។

6. ក្នុងស្មារតីនេះ ខ្ញុំសូមដាក់ជូនអង្គប្រជុំគណៈរដ្ឋមន្ត្រីលើកទី ១ របស់យើងនាថ្ងៃនេះ ជូនជនរួមជាតិ និង ដៃគូអភិវឌ្ឍន៍ទាំងអស់ ទាំងវិស័យសាធារណៈ ទាំងវិស័យឯកជន និង សង្គមស៊ីវិល ឱ្យជ្រាប និង ជំរុញអនុវត្តនូវ ***«យុទ្ធសាស្ត្រចតុ-កោណ»*** ដើម្បី ***កំណើន ការងារ សមធម៌*** និង ***ប្រសិទ្ធភាព*** នៅកម្ពុជា ***ដំណាក់កាលទី ២*** ដែលជា ***«របៀបវារៈគោលនយោបាយសង្គម- សេដ្ឋកិច្ច»*** នៃ ***«កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល នៃនីតិកាលទី ៤ នៃរដ្ឋសភា»*** ។

7. ខ្ញុំសូមអនុញ្ញាតអធិប្បាយអំពីសាវតា និង យុទ្ធសាស្ត្រនេះ ដូចតទៅ៖

# ផ្នែកទី ១

# លទ្ធផលនៃការអនុវត្តយុទ្ធសាស្ត្រចតុកោណ ក្នុងនីតិកាលទី ៣ នៃរដ្ឋសភា

## ១.១. សមិទ្ធផលសំខាន់ៗរបស់រាជរដ្ឋាភិបាលនីតិកាលទី ៣ នៃរដ្ឋសភា

**8.** កម្ពុជាបាន និង កំពុងទទួលផលពីសន្តិភាព និង ឯកភាពទឹកដីដ៏ពេញលេញ ដែលកើតចេញពីនយោបាយ«*ឈ្នះ-ឈ្នះ*» របស់រាជរដ្ឋាភិបាល តាមរយៈកំណើនសេដ្ឋកិច្ចខ្ពស់ និង ការកាត់បន្ថយភាពក្រីក្រ ក្នុងទសវត្សរ៍កន្លងទៅនេះ ។ នៅលើមូលដ្ឋាននេះ កម្ពុជាបានធ្វើសមាហរណកម្មខ្លួនចូលទៅក្នុងតំបន់ និង ពិភពលោក ហើយកំពុងដើរតួនាទីយ៉ាងសកម្ម ក្នុងកិច្ចដំណើរការប្រកបដោយជីវភាពនេះ ក្នុងឋានៈជាសមាជិកស្មើភាព និង ស្មើសិទ្ធិ ក្នុងអង្គការនានា ទាំងកម្រិតអនុតំបន់ តំបន់ អន្តរតំបន់ និង ពិភពលោក ។ ស្ថិរភាពនយោបាយ ដែលមិនធ្លាប់មានពីរប់ទសវត្សរ៍កន្លងមក បានអនុញ្ញាតឱ្យកម្ពុជាអនុវត្តនូវកិច្ចការកែទម្រង់ក្នុងគ្រប់វិស័យ សំដៅកសាងធនធានមនុស្ស អភិវឌ្ឍសមត្ថភាពស្ថាប័ន ពង្រឹងហេដ្ឋារចនាសម្ព័ន្ធសង្គម-សេដ្ឋកិច្ច និង បង្កើតបរិយាកាសអំណោយផល សម្រាប់ទាក់ទាញការវិនិយោគទាំងក្នុង និង ក្រៅប្រទេស ក្នុងគោលដៅធានាបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ និង ការកាត់បន្ថយភាពក្រីក្រ ។ យើងបានប្ដេជ្ញាចិត្តដោយឥតងាករេ ក្នុងការពង្រឹងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ដែលជាមាតិកាដ៏ត្រឹមត្រូវតែមួយគត់

សម្រាប់ដំណើរឈានទៅមុខរបស់កម្ពុជា ក្នុងការពង្រឹង ***«នីតិរដ្ឋ»*** ពិតប្រាកដ ដែលផ្តល់នូវកាលានុវត្តភាពប្រកបដោយសមធម៌ចំពោះប្រជាជនទាំងអស់ ។ ក្នុងនីតិកាលទី ៣ នៃរដ្ឋសភា កន្លងទៅ រាជរដ្ឋាភិបាល សម្រេចបាននូវលទ្ធផលធំៗ ដូចតទៅៈ

***ទី១.*** រាជរដ្ឋាភិបាល បានពង្រឹងសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និង សណ្តាប់ធ្នាប់សង្គម ដោយអនុវត្តលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ។

***ទី២.*** រាជរដ្ឋាភិបាល បានពង្រឹងការគោរពសិទ្ធិសេរីភាព និង សេចក្តីថ្លៃថ្នូររបស់មនុស្ស ក្នុងគ្រប់ទិដ្ឋភាពទាំងអស់ រួមមានសិទ្ធិសេរីភាពខាងនយោបាយ និង សង្គម- សេដ្ឋកិច្ច និង បានអនុវត្តកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ ក្នុងគោលដៅពង្រឹងលទ្ធិប្រជាធិបតេយ្យ និង ប្រសិទ្ធភាពនៃសេវាសាធារណៈនៅតាមមូលដ្ឋាន ។

***ទី៣.*** រាជរដ្ឋាភិបាល បានពង្រឹងអភិបាលកិច្ច តាមរយៈ កំណែទម្រង់រដ្ឋជាពិសេសកំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ ព្រមទាំងកំណែទម្រង់កងកម្លាំងប្រដាប់អាវុធ ដើម្បីធានាឱ្យបានថា រាល់ប្រតិបត្តិការ និង កិច្ចដំណើរការរបស់រាជរដ្ឋាភិបាល មានតម្លាភាព គណនេយ្យភាព ភាពអាចប៉ាន់ប្រមាណបាន មានប្រសិទ្ធភាព និង ភាពស័ក្តិសិទ្ធិ ។

***ទី៤.*** រាជរដ្ឋាភិបាល ធានាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និង កំណើនសេដ្ឋកិច្ចខ្ពស់ក្នុងកម្រិតពីរខ្ទង់ ដែលមិនធ្លាប់មាន ដោយគ្រប់គ្រងបាននូវអតិផរណា និង ធានាស្ថិរភាពជារួមនៃអត្រាប្តូរប្រាក់ ។ រាជរដ្ឋាភិបាល បានពង្រឹងសមត្ថភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចជាតិ បង្កើនផលិតភាពនៃវិស័យកសិកម្ម កសាងបាននូវមូលដ្ឋានសេដ្ឋកិច្ចជនបទ ពង្រីកវិស័យឧស្សាហកម្ម ជាពិសេស

វិស័យកាត់ដេរឱ្យនៅបន្តជាភាពរបស់ខ្លួន ព្រមទាំងពង្រឹង និង ពង្រីកវិស័យសេវា ឱ្យសម្រេចបាននូវការរីកលូតលាស់យ៉ាងឆាប់រហ័ស ដែលប្រការទាំងអស់នេះ បានបង្កើតការងារ និង ជំរុញការបណ្តុះបណ្តាលមុខជំនាញដល់ប្រជាជនកម្ពុជា ជាពិសេស យុវជន និង យុវនារីជាច្រើនសែននាក់ ។

***ទី៥.*** បន្ទាប់ពីបានដាក់ឱ្យអនុវត្ត *«កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ»* មក រាជរដ្ឋាភិបាល សម្រេចបានជាមូលដ្ឋាននូវ *«ភាពជឿទុកចិត្តបានលើថវិកា»* តាមរយៈការបង្កើនចំណូល និង វិចារណកម្មនៃចំណាយ ជាពិសេស ការបង្កើនបាននូវអតិរេកចរន្តនៃថវិកាជាតិ ដែលអនុញ្ញាតឱ្យបង្កើនទុនវិនិយោគសាធារណៈលើហេដ្ឋារចនាសម្ព័ន្ធសង្គម-សេដ្ឋកិច្ច ក្នុងគោលដៅពង្រឹង និង ពង្រីកសេវាសាធារណៈ និង កាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។

***ទី៦.*** វិស័យឯកជនបានក្លាយទៅជា ***«ក្បាលម៉ាស៊ីនពិតប្រាកដនៃកំណើនសេដ្ឋកិច្ច»*** និង បានចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ទាំងក្នុងវិស័យសេដ្ឋកិច្ចរូបវន្ត ទាំងក្នុងវិស័យហិរញ្ញវត្ថុ ។

***ទី៧.*** រាជរដ្ឋាភិបាល បញ្ចប់បានស្ទើរទាំងស្រុងនូវការស្តារ និង កសាងហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ថ្នាក់ជាតិសំខាន់ៗ និង កំពុងកែលម្អផ្លូវខេត្ត និង ផ្លូវលំជនបទ ។ វិស័យធារាសាស្ត្រ ថាមពល និង ទូរគមនាគមន៍ បាន និង កំពុងមានការរីកចម្រើនគួរឱ្យកត់សម្គាល់ ។

***ទី៨.*** រាជរដ្ឋាភិបាល បានពង្រឹងសមត្ថភាពស្ថាប័ន និង សមត្ថភាពធនធានមនុស្ស ដោយប្រមូលផ្តុំលើការអភិវឌ្ឍវិស័យអប់រំ និង សុខាភិបាល ។ ជាលទ្ធផលជាក់ស្តែង អត្រាចុះឈ្មោះចូលរៀនបានកើនឡើង អត្រាបោះបង់ចោលការសិក្សា

និង អត្រាគ្រួតថ្នាក់បានធ្លាក់ចុះ ហើយអត្រាមរណៈរបស់ទារក និង កុមារ និង អត្រាអ្នកផ្ទុកមេរោគហ៊ីវ- អេដស៍ ក៏ធ្លាក់ចុះផងដែរ ។

*៨៩.* រាជរដ្ឋាភិបាល បានពង្រឹងភាពជាដៃគូបន្ថែមទៀត ជាមួយភាគីពាក់ព័ន្ធទាំងអស់ ពិសេស ជាមួយដៃគូអភិវឌ្ឍន៍ផ្លូវការ វិស័យឯកជន និង សង្គមស៊ីវិល តាមរយៈការដាក់ឱ្យដំណើរការប្រកបដោយប្រសិទ្ធភាពនូវយន្តការនានា សម្រាប់កៀរគរ និង សម្របសម្រួលហិរញ្ញប្បទានសហប្រតិបត្តិការ និង ការវិនិយោគ ។

9. ដោយសារការអនុវត្តយ៉ាងប្តូរផ្តាច់ឥតរាថយនូវ *«យុទ្ធសាស្ត្រចតុកោណ»* រាជរដ្ឋាភិបាលនីតិកាលទី ៣ បានបង្កើតឡើងនូវបរិស្ថានអនុគ្រោះ និង លក្ខខណ្ឌចាំបាច់ជាច្រើន សម្រាប់ឱ្យកម្ពុជាបោះជំហានទៅមុខប្រកបដោយក្តីសង្ឃឹម និង ជំនឿទុកចិត្តយ៉ាងមុតមាំនៅលើមាគ៌ានៃកំណែទម្រង់ និង ការអភិវឌ្ឍ ។

10. ក្នុងក្របខ័ណ្ឌនេះ រាជរដ្ឋាភិបាល បានប្រកាន់ខ្ជាប់នូវគោលនយោបាយសាមគ្គីជាតិ ដើម្បីប្រមូលកម្លាំងប្រជាជាតិទាំងមូល ពីគ្រប់មជ្ឈដ្ឋាន គ្រប់និន្នាការនយោបាយ ទាំងនៅក្នុង និង នៅក្រៅប្រទេស ក្រោមបាវចនា ***ជាតិ សាសនា ព្រះមហាក្សត្រ*** ដើម្បីរួមគ្នាជាធ្លុងមួយសំដៅកសាង ការពារជាតិ និង សមិទ្ធផលសង្គម ក្នុងបរិការណ៍ ដែលប្រទេសមានឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី សុខសន្តិភាព ប្រជាធិបតេយ្យ និង វឌ្ឍនភាពថ្កើងថ្កាន ។ រាជរដ្ឋាភិបាល សូមសម្តែងនូវកតញ្ញុតាធម៌ និង កតវេទិតាធម៌ដ៏ជ្រាលជ្រៅបំផុតថ្វាយព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ ***នរោត្តម សីហមុនី*** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាជាទីសក្ការៈ ដែលជានិច្ចជាកាលព្រះអង្គទ្រង់បានប្រោសព្រះរាជទានការគាំទ្រ និង ការលើកទឹកចិត្តដ៏កក់ក្តៅបំផុតចំពោះរាល់សកម្មភាពរបស់រាជរដ្ឋាភិបាល តាមគន្លងប្រកបដោយគតិបណ្ឌិត និង សុភវិនិច្ឆ័យរបស់ព្រះករុណាព្រះបាទ

សម្តេចព្រះ ***នរោត្តម សីហនុ*** ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណ-ភាពទឹកដី និង ឯកភាពជាតិខ្មែរ និង សម្តេចព្រះមហាក្សត្រី ***នរោត្តម មុនិនាថ សីហនុ*** ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និង សុភមង្គលជាទីសក្ការៈដ៏ខ្ពង់ខ្ពស់ ។

## ១.២. បញ្ហាប្រឈមរបស់រាជរដ្ឋាភិបាល

**11.** ទន្ទឹមនឹងទទួលបានជោគជ័យនៅក្នុងការអនុវត្ត ***«យុទ្ធសាស្ត្រចតុកោណ»*** កម្ពុជាកំពុងជួបនឹងបញ្ហាប្រឈមមួយចំនួនដូចតទៅៈ

***ទី១.*** ទោះបីជាការងារកែទម្រង់ជួសំខាន់ៗ សំដៅធានាពង្រឹងអភិបាល-កិច្ចល្អ សម្រេចបានជោគជ័យគួរជាទីកត់សម្គាល់មួយចំនួនក៏ដោយ ក៏ប៉ុន្តែ បញ្ហាប្រឈមនៅតែមាន ជាអាទិ៍ គុណភាព ប្រសិទ្ធភាព និង ការផ្តល់សេវាសាធារណៈនៅមានកម្រិតមិនទាន់អាចឆ្លើយតបបានទៅនឹងតម្រូវការចាំបាច់ជាក់ស្តែង ស្ថាប័នតុលាការនៅមិនទាន់អាចទទួលបាននូវជំនឿទុកចិត្តពេញលេញពីសំណាក់មហា-ជន ការងារកសាងក្របខ័ណ្ឌច្បាប់ នៅមិនទាន់មានភាពគ្រប់ជ្រុងជ្រោយ ហើយការអនុវត្តច្បាប់ក៏នៅមានកម្រិតនៅឡើយ ។

***ទី២.*** មូលដ្ឋាននៃកំណើនសេដ្ឋកិច្ចនៅតូចចង្អៀត ដែលពឹងផ្អែកជាសំខាន់លើសសរទ្រូងបួនៈ គឺវិស័យកាត់ដេរ ទេសចរណ៍ សំណង់ និង កសិកម្ម ។ វិស័យកាត់ដេរ និង ទេសចរណ៍ងាយរងនូវហានិភ័យពីខាងក្រៅ ។ វិស័យកសិកម្ម ដែលមានប្រមាណ ៣០% នៃផលិតផលសរុបក្នុងស្រុក និង ជាមូលដ្ឋានបង្កើតការងារសម្រាប់ប្រជាជនជាង ៦០% មិនទាន់ត្រូវបានប្រើឱ្យអស់នូវសក្តានុពលនៅឡើយ ។

**១៣.** បាតុភូតនៃការប្រែប្រួលអាកាសធាតុ អតុល្យភាពនៃសេដ្ឋកិច្ចពិភព-លោក និង វិបត្តិហិរញ្ញវត្ថុ ដែលកើតមានក្នុងពេលថ្មីៗនេះ បណ្តាលឱ្យមានការធ្លាក់ចុះនៃសេដ្ឋកិច្ចពិភពលោក រួមមានទាំងការកើនថ្លៃនៃប្រេងឥន្ធនៈ និង ស្បៀងអាហារ និង ការចុះថ្លៃជាបន្តបន្ទាប់នៃប្រាក់ដុល្លារអាមេរិក បានដាក់មកលើសេដ្ឋកិច្ចកម្ពុជានូវសម្ពាធអតិផរណាដ៏ធ្ងន់ក្នុងរយៈពេលខ្លី និង មធ្យមខាងមុខ ។ ការកើនឡើងនូវសេចក្តីត្រូវការផ្ទៃក្នុងប្រទេសដែលផ្សារភ្ជាប់ទៅនឹងកំណើនសេដ្ឋ-កិច្ចខ្ពស់ ក្នុងរយៈពេលកន្លងមក បានបង្កើនថែមទៀតនូវសម្ពាធអតិផរណានេះ ។ ប្រការទាំងនេះ បង្កការគំរាមលើទស្សនៈអនាគតនៃកំណើនសេដ្ឋកិច្ចកម្ពុជា ។

**១៤.** ទោះបីជាក្នុងរយៈពេលកន្លងមក តាមរយៈកំណើនសេដ្ឋកិច្ចខ្ពស់ និង ការអនុវត្តគោលនយោបាយគាំទ្រផ្សេងៗ យើងបានកាត់បន្ថយភាពក្រីក្រពី ៤៧% ក្នុងឆ្នាំ ១៩៩៣ មកនៅត្រឹម ៣៥% ក្នុងឆ្នាំ ២០០៤ និង តាមការប៉ាន់ស្មានបឋម អាចចុះមកនៅត្រឹមប្រមាណ ៣២% ក្នុងឆ្នាំ ២០០៧ នេះក៏ដោយ ក៏អត្រាភាពក្រីក្រនៅជនបទ នៅមានកម្រិតខ្ពស់នៅឡើយ ។ លើសពីនេះ គម្លាតរវាងអ្នកមាន និង អ្នកក្រ ពិសេសវិសមភាពរវាងទីក្រុង តំបន់ទីប្រជុំជន និង តំបន់ជនបទ នៅបន្តស្ថិតនៅជាបញ្ហាប្រឈមនៅឡើយ ។

**១៥.** ការប្រមូលផ្តុំដីធ្លី និង ចំនួនពលរដ្ឋដែលគ្មានដី មាននិន្នាការកើនឡើង ដែលជាប្រការដាក់នូវបញ្ហាប្រឈមចំពោះសមធម៌ និង ប្រសិទ្ធភាព ក្នុងការប្រើប្រាស់ដីធ្លី ។ ម៉្យាងវិញទៀត ដីមួយចំនួនធំ ដែលរដ្ឋបានផ្តល់ជាសម្បទានសេដ្ឋកិច្ចមិនទាន់ត្រូវបានប្រើប្រាស់ឱ្យចំគោលដៅ និង ប្រកបដោយប្រសិទ្ធភាពនៅឡើយ ដែលទាមទារឱ្យរាជរដ្ឋាភិបាលចាត់វិធានការតឹងរ៉ឹង ដើម្បីដោះស្រាយ ។

**ទី៦.** ភាពអនាធិបតេយ្យក្នុងការកាន់កាប់ដីដោយខុសច្បាប់ និង បទ-បញ្ញត្តិ ការរំលោភយកដីរដ្ឋ ការកាប់រានទន្ទ្រានដីព្រៃក្នុងតំបន់ការពារធម្មជាតិទៅធ្វើជាកម្មសិទ្ធិឯកជន និង ការកាប់ឈើដោយខុសច្បាប់ នៅតែមានជាអន្លើៗទៅទៀយ ។ ទន្ទឹមនឹងនេះ ភាពក្រីក្រ និង បាតុភូតចំណាកស្រុកទៅរានដីថ្មី ល្មើសនឹងច្បាប់អនុញ្ញាត បានធ្វើឱ្យធនធានធម្មជាតិរងសម្ពាធនៃការបំផ្លាញ ។

**ទី៧.** នៅពេលដែលយើងបានបញ្ចប់ស្ទើរតែទាំងស្រុងនូវការស្តារ និង កសាងឡើងវិញនូវបណ្តាញផ្លូវជាតិទូទាំងប្រទេសរួចមក បញ្ហាប្រឈមរបស់យើងគឺការធានាសុវត្ថិភាពចរាចរណ៍ និង ជាពិសេសការធានាការជួសជុល ការថែទាំខួប និង ជាប្រចាំនូវផ្លូវជាតិ ផ្លូវខេត្ត និង ផ្លូវលំជនបទ ឱ្យបានជាប្រព័ន្ធ និង មានចីរភាព ។

**ទី៨.** វិស័យអាកាសចរណ៍ដើរតួនាទីយ៉ាងសំខាន់ ក្នុងការអភិវឌ្ឍវិស័យទេសចរណ៍ ។ ដូច្នេះ ការអភិវឌ្ឍបន្ថែមនូវហេដ្ឋារចនាសម្ព័ន្ធវិស័យអាកាសចរណ៍ រួមបញ្ចូលទាំងការបន្តការលើកកម្ពស់សុវត្ថិភាពហោះហើរ នៅតែជាអាទិភាពចម្បង ដើម្បីធានាការអភិវឌ្ឍវិស័យទេសចរណ៍ និង ការទាក់ទាញភ្ញៀវទេសចរឱ្យកាន់តែច្រើនមកទស្សនាកម្ពុជា ។

**ទី៩.** អគ្គិសនីនៅមានថ្លៃខ្ពស់ ធៀបនឹងប្រទេសជិតខាង ដែលជាឧបសគ្គដ៏ធំមួយ សម្រាប់ពង្រឹងភាពប្រកួតប្រជែងរបស់សេដ្ឋកិច្ចកម្ពុជា ក៏ដូចជាសម្រាប់ទាក់ទាញការវិនិយោគ និង លើកកម្ពស់ជីវភាពរបស់ប្រជាជន ។ វិសាលភាពនៃការប្រើប្រាស់អគ្គិសនីនៅជនបទ ក៏នៅមានកម្រិតទាបនៅឡើយ ។

**ទី១០.** ប្រព័ន្ធធារាសាស្ត្រមិនទាន់ត្រូវបានអភិវឌ្ឍគ្រប់គ្រាន់តាមសេចក្តីត្រូវការ និង មិនទាន់ត្រូវបានប្រើប្រាស់ឱ្យអស់សក្តានុពលនៅឡើយ ដែលតម្រូវឱ្យមានការបង្កើនប្រសិទ្ធភាពគ្រប់គ្រង និង វិនិយោគបន្ថែមទៀត ។

**ទី១១.** ហិរញ្ញប្បទាន ការគ្រប់គ្រង និង បច្ចេកវិទ្យា កំពុងស្ថិតនៅជាបញ្ហាប្រឈមដ៏ស្រួចស្រាវរបស់សហគ្រាសធុនតូច និង មធ្យមនៅកម្ពុជា ។

**ទី១២.** កិច្ចការពារសុវត្ថិភាពសង្គម ជាពិសេស សម្រាប់ពលករ និង ជនក្រីក្រ នៅមិនទាន់មានលក្ខណៈជាប្រព័ន្ធនៅឡើយ ។

**ទី១៣.** គុណភាពអប់រំនៅមានកម្រិតទាប ទាំងនៅកម្រិតបឋមសិក្សា មធ្យមសិក្សា និង ឧត្តមសិក្សា ។ ការផលិត និង ការជួញដូរគ្រឿងញៀនបានក្លាយជាបញ្ហាសង្គមមួយ ដែលអាចប៉ះពាល់ដល់សុខុមាលភាពរបស់យុវជន និង យុវនារីកម្ពុជា ទាំងនៅពេលបច្ចុប្បន្ន ទាំងនៅពេលអនាគត ។

**ទី១៤.** កង្វះខាតអ្នកបច្ចេកទេស និង ពលករជំនាញ គឺជាឧបសគ្គដ៏ធ្ងន់ធ្ងរមួយក្នុងការខិតខំពន្លឿន ការអភិវឌ្ឍសេដ្ឋកិច្ច ទាំងនៅទីក្រុង ទាំងនៅទីជនបទ ។

**ទី១៥.** ការផ្តល់សេវាសុខាភិបាលសាធារណៈ ប្រកបដោយគុណភាព នៅមានកម្រិតនៅឡើយ ។ ទោះបីជាយើងសម្រេចបានលទ្ធផលជាវិជ្ជមានជាច្រើននៅក្នុងវិស័យសុខាភិបាល ក៏ប៉ុន្តែ អត្រាមរណមាតានៅមានកម្រិតខ្ពស់ ។ សេវាថែទាំសុខភាព និង អនាម័យជនបទ រួមទាំងការផ្គត់ផ្គង់ទឹកស្អាតជនបទ សម្រេចបាន ក្នុងកម្រិតទាបនៅឡើយបើប្រៀបធៀបទៅនឹងគោលដៅអភិវឌ្ឍន៍សហស្ស - វត្សរ៍ ។

***ទី១៦.*** ការទទួលបាននូវការអប់រំតិចតួច អំពើហិង្សាក្នុងគ្រួសារ និង អំពើជួញដូរមនុស្ស គឺជាកត្តា ដែលធ្វើឱ្យស្ត្រីមិនអាចប្រើប្រាស់អស់នូវសក្តានុពលរបស់ខ្លួន ដើម្បីចូលរួមក្នុងការអភិវឌ្ឍសង្គម- សេដ្ឋកិច្ច ។

***ទី១៧.*** ជារួម សមត្ថភាពស្ថាប័នរបស់យើង នៅមានកម្រិតនៅឡើយ ដោយសារប្រាក់បៀវត្ស និង ការលើកទឹកចិត្តរបស់មន្ត្រីរាជការនៅទាប កិច្ចសហ-ប្រតិបត្តិការអន្តរស្ថាប័ននៅមានកម្រិត លិខិតបទដ្ឋានមួយចំនួន នៅមានចន្លោះប្រហោង និង កង្វះខាតធនធាន ដើម្បីអនុវត្តគោលនយោបាយដែលបានដាក់ចេញ ។

### ***១.៣. ភាពចាំបាច់ក្នុងការបន្តអនុវត្តយុទ្ធសាស្ត្រចតុកោណ***

**12.** ទិសដៅជាសារវន្តរបស់រាជរដ្ឋាភិបាល គឺកសាងជាជំហានៗនូវសង្គមកម្ពុជាមួយ ដែលមានសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និង សណ្តាប់ធ្នាប់សង្គម មានការអភិវឌ្ឍប្រកបដោយចីរភាព និង សមធម៌ ជាមួយនឹងការគោរពយ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍ប្រជាធិបតេយ្យសេរីពហុបក្ស ព្រមទាំងការគោរពសិទ្ធិ និង សេចក្តីថ្លៃថ្នូររបស់មនុស្ស មានគោសិកាផ្សារភ្ជាប់គ្នា មានប្រជាជនប្រកបដោយចំណេះដឹងខ្ពស់ និង វប្បធម៌ជ្រៅជ្រះ មានជីវភាពសមរម្យ និង មានការរស់នៅប្រកបដោយសុខដុមរមនា ទាំងក្នុងសង្គមជាតិ ទាំងក្នុងក្រុមគ្រួសារ ។

**13.** ដើម្បីសម្រេចបានតាមទិសដៅនេះ ***«យុទ្ធសាស្ត្រចតុកោណ»*** បានដាក់ចេញនូវគោលដៅ ៤ យ៉ាង ដែលស្តែងចេញ តាមរយៈបាវចនា ***កំណើន ការងារ សមធម៌*** និង ***ប្រសិទ្ធភាព*** ។ ក្នុងន័យនេះ ***«យុទ្ធសាស្ត្រចតុកោណ»*** គឺជា

យុទ្ធសាស្ត្រអភិវឌ្ឍរយៈពេលវែង ដែលផ្អែកលើគោលនយោបាយជាមូលដ្ឋានគ្រឹះ ដូចខាងក្រោម៖

***ទី១.*** ការធានានូវចីរភាពនៃសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និង សណ្តាប់ធ្នាប់សង្គម តាមរយៈ វិធានការជាក់ស្តែងនានា សំដៅលើកស្ទួយនីតិរដ្ឋ ការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស និងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ដើម្បីបង្កើតឡើងនូវបរិស្ថាននយោបាយ និង សន្តិសុខ ដែលអនុគ្រោះសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពក្នុងរយៈពេលវែង ។

***ទី២.*** ការធានាឱ្យបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ក្នុងរយៈពេលវែង មានអត្រាខ្ពស់ប្រមាណ ៧% ក្នុងមួយឆ្នាំ នៅលើមូលដ្ឋានទូលាយជាងមុន និង មានសមត្ថភាពប្រកួតប្រជែងជាងមុន ក្នុងបរិការណ៍អត្រាអតិផរណាទាបក្នុងកម្រិតតួលេខមួយខ្ទង់ អត្រាប្តូរប្រាក់មានស្ថិរភាព និង មានកំណើនទុនបម្រុងជាប្រចាំ ។

***ទី៣.*** ការធានាបែងចែកប្រកបដោយសមធម៌នូវកាលានុវត្តភាព និង ផ្លែផ្កានៃកំណើនសេដ្ឋកិច្ច ។

***ទី៤.*** ការធានាចីរភាពនៃបរិស្ថាន ជាពិសេស តាមរយៈការគ្រប់គ្រង និង ប្រើប្រាស់ប្រកបដោយចីរភាពនូវធនធានធម្មជាតិ ។

**14.** បន្ថែមពីលើនេះ នៅមានកត្តាជាក់ស្តែងមួយចំនួនទៀត ដែលកំណត់ពីភាពចាំបាច់ក្នុងការបន្តអនុវត្ត ***«យុទ្ធសាស្ត្រចតុកោណ»***៖

***ទី១.*** ភាពចាំបាច់ក្នុងការបន្តពង្រីក និង ពង្រឹងសមិទ្ធផលនានា ដែលរាជរដ្ឋាភិបាលកម្ពុជាសម្រេចបាន តាមរយៈការអនុវត្ត ***«យុទ្ធសាស្ត្រចតុកោណ»*** ក្នុងនីតិកាលទី ៣ កន្លងមក ។

***ទី២.*** ដូចបានគូសរំលេចខាងលើការអនុវត្ត ***យុទ្ធសាស្ត្រចតុកោណ*** ក្នុងនីតិកាលទី ៣ កន្លងមក បានបង្ហាញឱ្យឃើញនូវបញ្ហាប្រឈមសំខាន់ៗមួយចំនួន ដែលទាមទារឱ្យរាជរដ្ឋាភិបាល បន្តសម្រិតសម្រាំង កែលម្អ និង ពង្រឹងអាទិភាពគោលនយោបាយរបស់ខ្លួន ហើយជំរុញអនុវត្តរបៀបវារៈគោលនយោបាយនេះក្នុងដំណាក់កាលបន្ទាប់ទៀត ។

***ទី៣.*** ការបន្តអនុវត្ត ***«យុទ្ធសាស្ត្រចតុកោណ» ដំណាក់កាលទី ២*** គឺជាជំហានទៅសម្រេចឱ្យបាន ***«គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា»*** ។

***ទី៤.*** ឆន្ទៈ និង បំណងប្រាថ្នារបស់ប្រជាពលរដ្ឋកម្ពុជា តួបផ្សំនឹងការប្រែប្រួលសភាពការណ៍ពិភពលោក និង សភាពការណ៍ក្នុងប្រទេស គឺជាកត្តាកំណត់ថ្មីបន្ថែមទៀត ដែលទាមទារឱ្យមានការកែលម្អ និង សម្រិតសម្រាំងបន្ថែមនូវ ***«យុទ្ធសាស្ត្រចតុកោណ»*** ហើយជំរុញអនុវត្តក្នុងដំណាក់កាលទី ២ ។

**15.** ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាល ក៏ទទួលស្គាល់នូវភាពចាំបាច់នៃការធានាសង្គតិភាពនៃឋានានុក្រម តួនាទី ខ្លឹមសារ និង លំដាប់លំដោយនៃការអនុវត្តរវាង ***«យុទ្ធសាស្ត្រចតុកោណ»*** ជាមួយនឹង ***«ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ»*** ក៏ដូចជា ***យុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ*** ព្រមទាំងជាមួយនឹងឯកសារ ដែលមានលក្ខណៈជាផែនការគោលនយោបាយ កម្មវិធីវិនិយោគ និង ថវិកាជាតិ ។ ប្រការនេះ តម្រូវឱ្យរាជរដ្ឋាភិបាលពិនិត្យឡើងវិញនូវសង្គតិភាពនៃអាណត្តិកាលរបស់ ***«ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ»*** ជាមួយនឹង ***«កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល»*** ដែលមាន ***«យុទ្ធសាស្ត្រចតុកោណ»*** ជារបៀបវារៈគោល-នយោបាយសង្គម-សេដ្ឋកិច្ច ។

**16.** ក្នុងស្មារតីនេះ ក្នុងឋានៈជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា សម្រាប់នីតិកាលទី ៤ នៃរដ្ឋសភា ខ្ញុំសូមប្រកាសដាក់ឱ្យអនុវត្តនូវ ***«យុទ្ធសាស្ត្រចតុ-កោណ» ដំណាក់កាលទី ២*** ដូចតទៅ៖

# ផ្នែកទី ២

# យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ២

## ២.១. រចនាសម្ព័ន្ធនៃយុទ្ធសាស្ត្រចតុកោណ

17. ***យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី*** ២ រក្សារចនាសម្ព័ន្ធដើមនៃយុទ្ធសាស្ត្រនេះ ដោយគ្រាន់តែសម្រិតសម្រាំង និង សម្រួចបន្ថែមនូវអាទិភាពគោលនយោបាយ ស្របតាមសេចក្តីត្រូវការជាក់ស្តែងទាំងឡាយ ដូចបានគូសបញ្ជាក់ខាងលើ (សេចក្តីពន្យល់អំពីរចនាសម្ព័ន្ធនៃយុទ្ធសាស្ត្រចតុកោណ មានចែងក្នុងប្រអប់ និង គំនូសបំព្រួញដូចភ្ជាប់ជាមួយ) ។

**សេចក្តីពន្យល់អំពីរចនាសម្ព័ន្ធនៃយុទ្ធសាស្ត្រចតុកោណ**

***យុទ្ធសាស្ត្រចតុកោណ*** ត្រូវបានរៀបចំឡើងទៅតាមរចនាសម្ព័ន្ធជាមុំបួននៃចតុកោណ ដែលប្រទាក់ក្រឡាគ្នា ហើយផ្សារភ្ជាប់គ្នានៅគ្រប់ជ្រុងទាំងអស់ ។ ជារួម សមាសធាតុនៃ ***យុទ្ធសាស្ត្រចតុកោណ ដំណាក់កាល ទី*** ២ នេះ មានដូចតទៅ:

***ទី១. ស្នូលនៃយុទ្ធសាស្ត្រចតុកោណ*** គឺ *អភិបាលកិច្ចល្អ* ដែលផ្តោតការយកចិត្តទុកដាក់ទៅលើកំណែទម្រង់បួនយ៉ាងគឺ: *(១)*. ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ *(២)*. កំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ *(៣)*. កំណែទម្រង់

រដ្ឋបាលសាធារណៈ រួមមានទាំងកម្មវិធីវិមជ្ឈការ និង វិសហមជ្ឈការផង និង (៤). កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ ។

***ទី២. បរិស្ថានគ្រប់ជ្រុងជ្រោយ សម្រាប់ការអនុវត្តយុទ្ធសាស្ត្រចតុកោណ*** ដែលមានបួនយ៉ាងដែរ គឺៈ (១). សន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និង សណ្តាប់ធ្នាប់សង្គម (២). សមាហរណកម្មកម្ពុជាក្នុងតំបន់ និង ពិភពលោក (៣). ភាពជាដៃគូក្នុងការអភិវឌ្ឍ រួមមាន ភាពជាដៃគូជាមួយវិស័យឯកជន និង ដៃគូអភិវឌ្ឍន៍ ព្រមទាំង ភាពជាដៃគូជាមួយនឹងសង្គមស៊ីវិល និង (៤). បរិស្ថានម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលមានលក្ខណៈអនុគ្រោះ ។

***ទី៣. ចតុកោណយុទ្ធសាស្ត្រទាំងបួន សម្រាប់ជំរុញកំណើន*** រួមមានៈ (១). ការលើកស្ទួយវិស័យកសិកម្ម (២). ការបន្តស្តារ និង កសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត (៣). ការអភិវឌ្ឍវិស័យឯកជន និង ការងារ និង (៤). ការកសាងសមត្ថភាព និង ការអភិវឌ្ឍធនធានមនុស្ស ។

***ទី៤. ចតុកោណយុទ្ធសាស្ត្រនីមួយៗ មានមុំយុទ្ធសាស្ត្របួនយ៉ាង គឺ:***

***ចតុកោណទី១:*** *ការលើកស្ទួយវិស័យកសិកម្ម* មានៈ (១). ការលើកកម្ពស់ផលិតភាព និង ពិពិធកម្មកម្ម និង ពាណិជ្ជូបនីយកម្មកសិកម្ម (២). កំណែទម្រង់ដីធ្លី និង ការបោសសម្អាតមីន (៣). កំណែទម្រង់ជលផល និង (៤). កំណែទម្រង់ព្រៃឈើ ។

***ចតុកោណទី២:*** *ការបន្តស្តារ និង កសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត* មានៈ (១). ការបន្តស្តារ និង កសាង ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ (ផ្លូវគោក ផ្លូវទឹក និង ផ្លូវអាកាស) (២). ការគ្រប់គ្រងធនធានទឹក និង ប្រព័ន្ធធារាសាស្ត្រ (៣).

ការអភិវឌ្ឍវិស័យថាមពល (៤). ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍ ។

***ចតុកោណទី៣: ការអភិវឌ្ឍវិស័យឯកជន និង ការងារ*** មាន: (១). ការពង្រឹងវិស័យឯកជន និង ការទាក់ទាញការវិនិយោគ (ទី២). ការបង្កើតការងារ និង ការធានាលក្ខខណ្ឌការងារល្អប្រសើរជូនដល់កម្មករ និង និយោជិត (៣). ការលើកស្ទួយសហគ្រាសធុនតូច និង មធ្យម (៤). ការរៀបចំប្រព័ន្ធសុវត្ថិភាពសង្គម សម្រាប់មន្ត្រី បុគ្គលិក កម្មករ ។

***ចតុកោណទី៤: ការកសាងសមត្ថភាព និង ការអភិវឌ្ឍធនធានមនុស្ស*** មាន: (១). ការពង្រឹងគុណភាពវិស័យអប់រំ(២). ការលើកកម្ពស់សេវាសុខាភិបាល (៣). ការអនុវត្តគោលនយោបាយសមភាពយេនឌ័រ និង(៤). ការអនុវត្តគោលនយោបាយជាតិប្រជាជន ។

---

***គំនូសបំព្រួញនៃយុទ្ធសាស្ត្រចតុកោណ មានភ្ជាប់ជូននៅទំព័រក្រោយបង្អស់*

### ២.២. អាទិភាពនៃគោលនយោបាយសង្គម-សេដ្ឋកិច្ច

#### ២.២.១. ស្នូលនៃយុទ្ធសាស្ត្រចតុកោណ គឺអភិបាលកិច្ចល្អ

**18.** អភិបាលកិច្ចល្អ គឺជាបុរេលក្ខខណ្ឌសំខាន់បំផុតមួយ ដើម្បីធានាឱ្យមានការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចប្រកបដោយចីរភាព សមធម៌ និង យុត្តិធម៌ក្នុងសង្គម ។ អភិបាលកិច្ចល្អ ត្រូវបានពង្រឹងជាបន្តបន្ទាប់ តាមរយៈ កំណែទម្រង់ក្នុងវិស័យសំខាន់ៗ រួមមានការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ កំណែទម្រង់រដ្ឋបាលសាធារណៈ និង កំណែទម្រង់កងកម្លាំង

ប្រដាប់អាវុធ ។ ជាការពិត កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងកំណែទម្រង់ដីធ្លី កំណែទម្រង់ព្រៃឈើ និង កំណែទម្រង់ជលផល ក៏បានចូលរួមចំណែកផងដែរ ក្នុងការពង្រឹងអភិបាលកិច្ចល្អ និង ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ។ នៅក្នុងនីតិកាលទី ៤ នៃរដ្ឋសភានេះ កំណែទម្រង់អភិបាលកិច្ចរបស់រាជរដ្ឋាភិបាល នឹងផ្តោតជាសំខាន់ទៅលើការបង្កើនប្រសិទ្ធភាព ក្នុងការអនុវត្តគោលនយោបាយ និង ក្នុងការផ្តល់ និង ការគ្រប់គ្រងទំនិញសាធារណៈ ជាពិសេសការផ្តល់សេវាសាធារណៈ ឱ្យកាន់តែប្រសើរឡើង ដើម្បីឆ្លើយតបទៅនឹងបំណងប្រាថ្នារបស់ប្រជាជន ។

### ៦.១. ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ

19. រាជរដ្ឋាភិបាលនីតិកាលទី ៣ បានធ្វើសកម្មភាពជាក់ស្តែងជាច្រើនរួចមកហើយ ក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ។ ក្នុងស្មារតីនេះ ទោះបីជាមិនទាន់មានច្បាប់ប្រឆាំងនឹងអំពើពុករលួយនៅឡើយក៏ដោយ ក៏រាជរដ្ឋាភិបាល បានផ្តោតការយកចិត្តទុកដាក់ ជាពិសេសទៅលើការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយនេះ តាមរយៈ ការដាក់ចេញនូវផែនការសកម្មភាពអភិបាលកិច្ច ការអនុម័ត និង ការជំរុញអនុវត្តនូវវិធានការច្បាប់មុតស្រួចមួយចំនួន ដូចជា ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ច្បាប់ស្តីពីគយ អនុក្រឹត្យស្តីពីលទ្ធកម្មសាធារណៈ បទបញ្ជារបស់រាជរដ្ឋាភិបាលស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ក្រមសីលធម៌វិជ្ជាជីវៈរបស់មន្ត្រីរាជការគយ និង រដ្ឋាករ ។ ជាមួយគ្នានេះដែរ យន្តការត្រួតពិនិត្យនៃអាជ្ញាធរសវនកម្មជាតិ និង អធិការកិច្ចត្រូវបានពង្រឹងយន្តការសវនកម្មផ្ទៃក្នុងត្រូវបានបង្កើតឡើងនៅតាមគ្រប់ក្រសួង- ស្ថាប័នរដ្ឋ ពិសេស អង្គភាពប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយត្រូវបានពង្រឹង ជាមួយនឹងការដាក់ទណ្ឌកម្មខាងវិន័យ

រដ្ឋបាល និង ការបញ្ជូនទៅតុលាការនូវមន្ត្រីមួយចំនួន ដែលបានប្រព្រឹត្តកំហុសពាក់ព័ន្ធនឹងអំពើពុករលួយ ។

**20.** ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ នៅតែជារបៀបវារៈអាទិភាពមួយដ៏សំខាន់នៃបញ្ជីរបៀបវារៈរបស់រាជរដ្ឋាភិបាលនីតិកាលទី ៤ នៃរដ្ឋសភានេះ ។ រាជរដ្ឋាភិបាល យល់ច្បាស់ថា ច្បាប់ស្តីពីការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ គឺជាមូលដ្ឋានគតិយុត្តគន្លឹះមួយមិនអាចខ្វះបាន សម្រាប់ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយប្រកបដោយប្រសិទ្ធភាព ។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាល នៅតែប្តេជ្ញាចិត្តមោះមុតឥតរាថយក្នុងការរៀបចំ និង ជំរុញអនុម័តច្បាប់នេះ ដោយបន្តកិច្ចសហការពិគ្រោះយោបល់យ៉ាងជិតស្និទ្ធជាមួយនឹងគ្រប់ភាគីពាក់ព័ន្ធ ដោយផ្អែកលើច្បាប់គោលដទៃទៀតជាមូលដ្ឋាន ដែលត្រូវអនុម័តជាមុនសិន ។ ដំណើរការតាមលំដាប់លំដោយបែបនេះ ទើបអាចធានាបាននូវសង្គតិភាព និង ភាពរលូនរវាងច្បាប់ ដែលពាក់ព័ន្ធ ជាពិសេសធានាបាននូវប្រសិទ្ធភាពក្នុងការអនុវត្ត ។

**21.** រាជរដ្ឋាភិបាលនីតិកាលទី ៤ នឹងបន្តអនុវត្តវិធានការមុតស្រួចជាយុទ្ធសាស្ត្រជាក់ស្តែង ដែលអាចដោះស្រាយបញ្ហាអំពើពុករលួយប្រកបដោយប្រសិទ្ធភាពតាមរយៈវិធានការប្រទាក់ក្រឡាគ្នា ដូចខាងក្រោម៖

*១. ការបង្ការទប់ស្កាត់ជាមុនៈ* រាជរដ្ឋាភិបាល បន្តជំរុញសកម្មភាពលើកកម្ពស់ការយល់ដឹងរាល់ទិដ្ឋភាពស្តីពីអំពើពុករលួយ រួមមានមូលហេតុ ឥទ្ធិពល និង ផលលំបាកដ៏គ្រោះថ្នាក់ទាំងឡាយនៃអំពើពុករលួយនេះ ដើម្បីបន្តលើកទឹកចិត្តសាធារណជនឱ្យចូលរួម ក្នុងការទប់ស្កាត់ប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ។ រាជរដ្ឋាភិបាល បន្តអនុវត្តវិធានការជាក់ស្តែង ដើម្បីលើកទឹកចិត្តមន្ត្រីរាជការ

គ្រប់លំដាប់ថ្នាក់ ឱ្យប្រកាន់ខ្ជាប់នូវសេចក្ដីថ្លៃថ្នូរ សីលធម៌វិជ្ជាជីវៈ និង អនុវត្តការងារប្រកបដោយមនសិការវិជ្ជាជីវៈ និង ស្មារតីទទួលខុសត្រូវខ្ពស់ ។

*២. ការពង្រឹងគណនេយ្យភាព និង ពង្រឹងសមត្ថភាពស្ថាប័ន:* រាជរដ្ឋាភិបាល យកចិត្តទុកដាក់អនុវត្តឱ្យមានប្រសិទ្ធភាពនូវគោលការណ៍បញ្ចៀសទំនាស់ផលប្រយោជន៍រវាងឯកជន និង សាធារណៈ ដោយអនុវត្តនូវគោលការណ៍វិសមិតភាពមុខងារ ជាពិសេស វិសមិតភាពរវាងមុខងារនយោបាយ និង មុខងារសាធារណៈ និង រវាងមុខងារនយោបាយ ឬ មុខងារសាធារណៈ ជាមួយនឹងសកម្មភាពខាងវិជ្ជាជីវៈធុរកិច្ច ព្រមទាំងកាត់បន្ថយ និង លុបបំបាត់ចោលនូវការប្រើតួនាទី ឥទ្ធិពល សិទ្ធិអំណាច ដែលធ្វើឱ្យមានភាពមិនច្បាស់លាស់ ឬ មានភាពលំអៀង ក្នុងការធ្វើសេចក្ដីសម្រេច ។

*៣. ការគាំទ្រ និង ការចូលរួមពីសាធារណជន:* នេះ គឺជាលក្ខខណ្ឌមិនអាចខ្វះបាន ក្នុងការទប់ស្កាត់ កាត់បន្ថយ និង ប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយឱ្យមានប្រសិទ្ធភាព ។ ជាមួយគ្នានេះដែរ រាជរដ្ឋាភិបាល នឹងបន្តជំរុញលើកកម្ពស់ថែមទៀត នូវការការពារសេរីភាពនៃការស្វែងរកទទួល និង ផ្សព្វផ្សាយក្នុងបណ្ដាញព័ត៌មាននូវករណីពាក់ព័ន្ធនឹងអំពើពុករលួយ ។ ប៉ុន្តែ ការអនុវត្តកិច្ចការទាំងអស់នេះ ត្រូវតែមានលក្ខណៈជឿទុកចិត្តបាន និង មានការទទួលខុសត្រូវ ដោយត្រូវគោរពសិទ្ធិ កិត្តិយស និង សេចក្ដីថ្លៃថ្នូររបស់ប្រជាជន ព្រមទាំងការពារបាននូវសន្តិសុខជាតិ និង សណ្ដាប់ធ្នាប់សាធារណៈ ។

*៤. ការចូលរួមពីវិស័យឯកជន:* រាជរដ្ឋាភិបាល បន្តរៀបចំ និង ជំរុញអនុវត្តគោលនយោបាយ បទដ្ឋាន គតិយុត្ត និង នីតិវិធី សម្រាប់ការពារភាពសុចរិតនៃវិស័យឯកជន ដើម្បីបញ្ចៀសការឃុបឃិត និង ធានាឱ្យបាននូវការប្រកួតប្រជែង

ដោយស្មោះត្រង់រវាងក្រុមហ៊ុន-សហគ្រាសឯកជន ដោយធានាឱ្យបាននូវការប្រព្រឹត្តល្អត្រឹមត្រូវ ប្រកបដោយកិត្តិយស សេចក្តីថ្លៃថ្នូរ ក្នុងសកម្មភាពធុរកិច្ច ។ រាជរដ្ឋាភិបាល នឹងធានាតុល្យភាពរវាងសិទ្ធិ និង ផលប្រយោជន៍ទាំងឡាយ ដែលមានចែងក្នុងកិច្ចសន្យារវាងភាគីរដ្ឋ និង វិស័យឯកជន ។

*៥. ការពង្រឹងការអនុវត្តច្បាប់:* រាជរដ្ឋាភិបាល នឹងបន្តចាត់វិធានការច្បាប់ម៉ឺងម៉ាត់ តឹងរ៉ឹងចំពោះជនល្មើស ដើម្បីលុបបំបាត់វប្បធម៌និទណ្ឌភាព កាត់បន្ថយអំពើពុករលួយ និង បង្កើនជំនឿទុកចិត្តពីសំណាក់សាធារណជន ។

*****ឌ២. កំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌***

**22.** រាជរដ្ឋាភិបាល បានកែលម្អប្រព័ន្ធច្បាប់ និង ប្រព័ន្ធយុត្តិធម៌ ដោយផ្តោតជាសំខាន់ទៅលើការរៀបចំក្របខ័ណ្ឌច្បាប់ឱ្យបានរឹងមាំ និង ការធ្វើទំនើបនីយកម្មច្បាប់ ព្រមទាំងដាក់ចេញនូវយុទ្ធសាស្ត្រ និង វិធានការចាំបាច់នានា ក្នុងគោលដៅពង្រឹងសមត្ថភាព ឯករាជ្យ និង អព្យាក្រឹតភាពនៃស្ថាប័នតុលាការ ដែលជាកត្តាសំខាន់ ក្នុងដំណើរការពង្រឹងនីតិរដ្ឋ ។ ក្នុងនីតិកាលទី ៣ កន្លងទៅនេះ ច្បាប់ចំនួន ១៤០ ត្រូវបានអនុម័ត ក្នុងនោះ មានក្រមធំៗចំនួន ៣ គឺក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមនីតិវិធីរដ្ឋប្បវេណី និង ក្រមរដ្ឋប្បវេណី ។ រាជរដ្ឋាភិបាល បានផ្តោតការយកចិត្តទុកដាក់លើការកែលម្អប្រព័ន្ធតុលាការ តាមរយៈការពង្រឹងសមត្ថភាព និង ការទទួលខុសត្រូវរបស់ចៅក្រម ។ វិធានការវិន័យ ត្រូវបានដាក់ចេញជាបន្តបន្ទាប់ដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ព្រមជាមួយគ្នានេះ សមត្ថភាព និង ការទទួលខុសត្រូវវិជ្ជាជីវៈរបស់ចៅក្រម ក៏ត្រូវបានពង្រឹង តាមរយៈការបណ្តុះបណ្តាលដំបូង និងការបណ្តុះបណ្តាលបន្ត និងការអនុម័តនូវក្រមសីលធម៌វិជ្ជាជីវៈ សម្រាប់ចៅក្រម និង ព្រះរាជអាជ្ញា ។ រាជរដ្ឋាភិបាល បានបង្កើតមជ្ឈមណ្ឌលសេវា

យុត្តិធម៌ ថ្នាក់ស្រុកមួយចំនួន ដើម្បីធ្វើសាកល្បងនូវយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅកម្ពុជា ក្នុងទិសដៅកាត់បន្ថយការកកស្ទះសំណុំរឿង នៅក្នុងតុលាការ ។

**23.** រាជរដ្ឋាភិបាល នឹងបន្តអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ ដើម្បីឈានទៅសម្រេច ឱ្យបាននូវទិសដៅជាយុទ្ធសាស្ត្រទាំង ៧ របស់ខ្លួន ។ រាជរដ្ឋាភិបាល នឹងផ្ដោតការយកចិត្តទុកដាក់ខ្ពស់ថែមទៀត ក្នុងការបន្ត និង ជំរុញអនុម័តច្បាប់គោលសំខាន់ៗ ដូចជា ក្រមព្រហ្មទណ្ឌ ច្បាប់ស្តីពីការប្រឆាំងនឹងអំពើពុករលួយ ច្បាប់ស្ដីពីលក្ខន្តិកៈចៅក្រម និង ព្រះរាជអាជ្ញា ច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃអង្គការតុលាការ និង ច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។ ជាមួយគ្នានេះ រាជរដ្ឋាភិបាល នឹងបន្តរៀបចំកម្មវិធីផ្សព្វផ្សាយច្បាប់ដល់ប្រជាពលរដ្ឋ និង បណ្ដុះបណ្ដាលច្បាប់ដល់មន្ត្រីអនុវត្តច្បាប់ក្នុងគោលដៅបង្កើនការយល់ដឹង និង ការអនុវត្តឱ្យបានត្រឹមត្រូវ ។ ក្នុង **នីតិកាលទី ៤ នេះ រាជរដ្ឋាភិបាល នឹងបន្តផ្ដល់អាទិភាពបន្ថែមទៀតទៅលើ៖** *(១). ការពង្រឹងសមត្ថភាពរបស់ចៅក្រម និងព្រះរាជអាជ្ញា* តាមរយៈការបណ្ដុះ-បណ្ដាលបន្ត និង ការបណ្ដុះបណ្ដាលវិជ្ជាជីវៈដំបូង ប្រកបដោយគុណភាពខ្ពស់ និង ការពង្រឹងការទទួលខុសត្រូវរបស់ចៅក្រម និង ព្រះរាជអាជ្ញា តាមរយៈការបង្កើតឱ្យមានលក្ខន្តិកៈសម្រាប់ចៅក្រម និងព្រះរាជអាជ្ញា និងតាមរយៈការពង្រឹងវិន័យ ដោយសហការជាមួយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម *(២). ការកសាងនូវយន្តការផ្សេងៗ ដែលចូលរួមបម្រើឱ្យវិស័យយុត្តិធម៌* រួមមានការបង្កើតឱ្យមានលក្ខន្តិកៈក្រឡាបញ្ជី លក្ខន្តិកៈសារការី និង លក្ខន្តិកៈអាជ្ញាសាលា ព្រមទាំងការបង្កើតឱ្យមានសាលាបណ្ដុះបណ្ដាលវិជ្ជាជីវៈមន្ត្រីជំនួយឱ្យវិស័យយុត្តិធម៌ទាំងនេះ

ដើម្បីធានាឱ្យបាននូវគុណភាព និង សមត្ថភាពវិជ្ជាជីវៈខ្ពស់ *(៣). ការផ្តល់ជំនួយផ្នែកច្បាប់* ជាពិសេស តាមរយៈ ការផ្តល់ជំនួយមេធាវីដល់ជនក្រីក្រ ដើម្បីការពារសិទ្ធិ និង ប្រយោជន៍តាមផ្លូវតុលាការ *(៤). ការបន្តជំរុញលើកកម្ពស់យន្តការនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ* ជូនប្រជាពលរដ្ឋ ដើម្បីលើកស្ទួយ និង ពង្រឹងវប្បធម៌នៃការរួមរស់ជាមួយគ្នាដោយសន្តិភាព សាមគ្គីភាព និង សុខដុម-រមនាក្នុងសង្គម ។

### *ទី៣. កំណែទម្រង់រដ្ឋបាលសាធារណៈ*

**24.** រាជរដ្ឋាភិបាល បានដាក់ឱ្យដំណើរការនូវកន្សោមអាទិភាព នៅតាម ក្រសួង និង ស្ថាប័នមួយចំនួន ដើម្បីពង្រឹងសមត្ថភាពគ្រប់គ្រងរបស់ស្ថាប័ន បានរៀបចំលក្ខណៈវិនិច្ឆ័យសម្រាប់ការជ្រើសរើស និង រៀបចំឱ្យមានការប្រលងប្រជែងជ្រើសរើសមន្ត្រីរាជការ បានតម្លើងប្រាក់ឧបត្ថម្ភគោលនយោបាយធានារ៉ាប់រងសង្គម ប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការស៊ីវិល និង បានអនុវត្តសាកល្បងនូវគំនិតផ្តួចផ្តើមផ្តល់ប្រាក់លាភការ ដោយផ្អែកលើលទ្ធផលការងារ ក្នុងគោលដៅពង្រឹងសេវាសាធារណៈឱ្យមានប្រសិទ្ធភាព តម្លាភាព ការទទួលខុសត្រូវខ្ពស់ និង បានដាក់ឱ្យដំណើរការសាកល្បងនូវយន្តការ *«ច្រកចេញ-ចូលតែមួយ»* ដើម្បីជួយសម្រួលដល់អ្នកប្រើប្រាស់សេវាសាធារណៈ និង បានដាក់ឱ្យដំណើរការវិមជ្ឈការថ្នាក់ឃុំ-សង្កាត់ និង ការផ្តល់សេវាតាមប្រព័ន្ធព័ត៌មានវិទ្យា ។ ក្នុងការដ្ឋានកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រាជរដ្ឋាភិបាល សម្រេចបាននូវការធ្វើឱ្យមានភាពជឿទុកចិត្តបាននៃថវិកា តាមរយៈការគ្រប់គ្រងចំណូលប្រកបដោយប្រសិទ្ធភាព និង ការធ្វើចារណកម្មចំណាយសាធារណៈ ។ ប្រាក់បៀវត្សមធ្យមប្រចាំខែ

បានកើនឡើងពី ៣០ ដុល្លារ ក្នុងឆ្នាំ ២០០៤ ដល់ ៦២,៤ ដុល្លារ ក្នុងឆ្នាំ ២០០៨ គឺកើន ឡើងជាងទ្វេដង ។

**25.** ក្នុងនីតិកាលទី ៤ នេះ រាជរដ្ឋាភិបាល នឹងបន្តពង្រីកការអនុវត្តកន្សោមអាទិភាព និង ការផ្តល់ប្រាក់លាភការដោយផ្អែកលើលទ្ធផលការងារ នៅតាមក្រសួង និង ស្ថាប័នតាមវិស័យអាទិភាពមួយចំនួនថែមទៀត ក្នុងគោលដៅអនុវត្តឱ្យស៊ីជម្រៅនូវកម្មវិធីកំណែទម្រង់តាមផែ្នករបស់រាជរដ្ឋាភិបាលនៅទូទាំងប្រទេស ។ រាជរដ្ឋាភិបាល នឹងបន្តអនុវត្តគោលនយោបាយបង្កើនប្រាក់បៀវត្សមូលដ្ឋានចំនួន ២០% ក្នុងមួយឆ្នាំ ធៀបទៅនឹងការបង្កើនពី ១០-១៥% ក្នុងនីតិកាលទី ៣ ។ រាជរដ្ឋាភិបាល នឹងបង្កើនការយកចិត្តទុកដាក់លើប្រសិទ្ធភាពនៃការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា ការពង្រឹងការងារគ្រប់គ្រង និង អភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ ការពង្រីកតួនាទីស្ត្រីឱ្យចូលរួមកាន់តែសកម្មក្នុងរដ្ឋបាលសាធារណៈ ការពង្រឹងការផ្តល់សេវាសាធារណៈជាមូលដ្ឋាន សេវាអធិបតេយ្យរបស់រដ្ឋ សេវាពាក់ព័ន្ធទៅនឹងការវិនិយោគ និង ពាណិជ្ជកម្មធុនតូច និង មធ្យម តាមរយៈការបន្តពង្រឹងសេវាសាធារណៈ ការអនុវត្តយន្តការ *«ច្រកចេញ-ចូលតែមួយ»* និង ការបង្កើតការិយាល័យប្រជាពលរដ្ឋ ។ ទន្ទឹមនេះ រាជរដ្ឋាភិបាល នឹងពង្រីកយន្តការថ្មីៗ សម្រាប់ផ្តល់សេវាសាធារណៈ តាមរយៈការបង្កើត *«ទីភ្នាក់ងារប្រតិបត្តិការពិសេស»* នៅតាមបណ្តាក្រសួង-ស្ថាប័ន ព្រមទាំងជំរុញលើកទឹកចិត្តសង្គមស៊ីវិល និង វិស័យឯកជនឱ្យចូលរួមចំណែកដោយផ្ទាល់ ក្នុងការផ្តល់សេវាសាធារណៈ ។

**26.** រាជរដ្ឋាភិបាល នឹងបន្តជំរុញអនុវត្តគោលនយោបាយវិមជ្ឈការ និង វិសហមជ្ឈការ តាមរយៈការរៀបចំបទដ្ឋានគតិយុត្ត និង ការដាក់ចេញនូវវិធានការថ្មីថែមទៀត ដើម្បីអនុវត្តឱ្យមានប្រសិទ្ធភាពនូវ *«ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល*

*រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ»* ជាពិសេស ការរៀបចំ និង អនុវត្តលិខិតបទដ្ឋានដែលពាក់ព័ន្ធ នឹងការផ្ទេរអំណាចពីរដ្ឋបាលថ្នាក់ជាតិ មករដ្ឋបាលថ្នាក់ក្រោមជាតិដោយកំណត់ឱ្យបានច្បាស់លាស់នូវតួនាទី សិទ្ធិ អំណាច និង ការធានាគណនេយ្យភាព ក្នុងការបំពេញការងារ ។ ច្បាប់នេះ នឹងត្រូវបានអនុវត្តជាជំហានៗដោយប្រយ័ត្នប្រយែង ដោយក្រសួង និង ស្ថាប័ននីមួយៗ ត្រូវរៀបចំផែនការជាក់ស្តែងស្តីពីការធ្វើប្រតិភូកម្មអំណាច និង មុខងារដល់ថ្នាក់ក្រោមជាតិ ។ ទន្ទឹមនេះដែរ ការគ្រប់គ្រងហិរញ្ញវត្ថុតាមបែបវិសហមជ្ឈការ នឹងត្រូវអនុវត្តដោយភាពទន់ភ្លន់ និង តាមដំណាក់ៗ ក្នុងរយៈពេលមធ្យម ដើម្បីមានពេលគ្រប់គ្រាន់ក្នុងការកសាងសមត្ថភាពថ្នាក់ក្រោមជាតិ សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ *គណៈកម្មាធិការជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ* នឹងរៀបចំកម្មវិធីជាតិ សម្រាប់ការអនុវត្តក្នុងរយៈពេល ១០ ឆ្នាំ ។

### ទី៤. កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ

**27.** រាជរដ្ឋាភិបាល បានអនុវត្តតាមផែនការនៃកម្មវិធីកំណែទម្រង់ និង បានពង្រីកសមត្ថភាពនៃកងកម្លាំងប្រដាប់អាវុធ ក្នុងនោះ គិតទាំងការរំសាយកងទ័ព និង ការបង្កើតកងកម្លាំងប្រដាប់អាវុធមួយ ដែលមានប្រសិទ្ធភាពជាងមុន រួមមានការកែសម្រួលរចនាសម្ព័ន្ធកងឯកភាពប្រយុទ្ធ ពីថ្នាក់កងពលធំមកនៅត្រឹមកងពលតូច ការច្របាច់បញ្ចូលគ្នានូវបណ្តាកងពលតូច ការហ្វឹកហ្វឺនបណ្តុះបណ្តាលយោធិនអាជីព និង ជំនាញឯកទេស រួមទាំងការងារហ្វឹកហ្វឺនប្រឆាំងភេរវកម្ម និង ការបោសសម្អាតមីនផង កំណែទម្រង់ការគ្រប់គ្រងអាវុធជាតិផ្ទុះ ការចូលរួមរបស់កងវិស្វកម្មក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធលើគ្រប់វិស័យការកសាងកម្លាំង ដើម្បីទៅចូលរួមក្នុងប្រតិបត្តិការថែរក្សាសន្តិភាពនៃអង្គការសហប្រជាជាតិ ជាពិសេស

ក្នុងវិស័យបោសសម្អាតមីន វិសកម្ម និង ការការពារសន្តិសុខ ស្ថិរភាព និង សណ្តាប់ធ្នាប់សង្គម រួមទាំងការប្រយុទ្ធប្រឆាំងនឹងការជួញដូរស្ត្រី និង កុមារ និង ការជួញដូរគ្រឿងញៀន ជាដើម ។

**28.** ក្នុងនីតិកាលទី ៤ ខាងមុខ រាជរដ្ឋាភិបាល នឹងបន្តអនុវត្តនូវកម្មវិធីកំណែទម្រង់កងកម្លាំងប្រដាប់អាវុធ ដើម្បីធានាបាននូវកិច្ចការពារប្រកបដោយប្រសិទ្ធភាពខ្ពស់នូវអធិបតេយ្យ និង បូរណភាពទឹកដី សន្តិសុខ និង សណ្តាប់ធ្នាប់សង្គម នៃព្រះរាជាណាចក្រកម្ពុជា ។ ដោយផ្អែកលើធនធាន ការវិវត្តនៃសភាពការណ៍សន្តិសុខ អន្តរជាតិ និង ស្ថានការណ៍ជាក់ស្តែងរបស់កម្ពុជា កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ ក្នុងនីតិកាលទី ៤ ខាងមុខនេះ នឹងផ្តោតលើ÷

*១.* ការបន្តពង្រឹងកងកម្លាំងប្រដាប់អាវុធ ឱ្យក្លាយទៅជាកងកម្លាំងមានវិជ្ជាជីវៈជំនាញ មានសមត្ថភាព ក្នុងការបន្តវេន មានបច្ចេកវិទ្យា និង សម្ភារៈសមស្រប គោរពប្រតិបត្តិច្បាប់ម៉ឺងម៉ាត់ គោរពសិទ្ធិមនុស្ស មានទឹកចិត្តស្មោះត្រង់ចំពោះ ***ជាតិ សាសនា ព្រះមហាក្សត្រ*** ហ៊ានធ្វើពលិកម្មគ្រប់បែបយ៉ាង ដើម្បីបូរណភាពទឹកដី និង ឧត្តមប្រយោជន៍ជាតិ និង ប្រជាជន ព្រមទាំងខិតខំពង្រឹងសីលធម៌សង្គម និង សីលធម៌វិជ្ជាជីវៈ ដើម្បីបង្កើនជំនឿថែមទៀត មកលើកងកម្លាំងប្រដាប់អាវុធ ។

*២.* ការបន្តជំរុញឱ្យបានកាន់តែប្រសើរថែមទៀត នូវកិច្ចសហប្រតិបត្តិការក្នុងចំណោមកងកម្លាំងប្រដាប់ អាវុធគ្រប់ប្រភេទ និង រវាងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ជាមួយស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត ដើម្បីបុព្វហេតុសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និង ឯកភាពជាតិ ។ រាជរដ្ឋាភិបាល នឹងបន្តជំរុញលើកកម្ពស់ប្រពៃណីនៃការផ្សារភ្ជាប់ការរវាងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទជាមួយ

ប្រជាជន តាមរយៈ ការពង្រឹងសមត្ថភាពចូលរួមប្រតិបត្តិការសង្គ្រោះពេលមានគ្រោះមហន្តរាយ និង កិច្ចប្រតិបត្តិការមនុស្សធម៌ផ្សេងៗ រួមទាំងការជួយប្រជាជនក្នុងការងារបង្កបង្កើនផលផង ។ ព្រមជាមួយគ្នានេះ រាជរដ្ឋាភិបាល នឹងបន្តជំរុញកិច្ចសហប្រតិបត្តិការជាមួយសហគមន៍អន្តរជាតិ ដើម្បីរួមចំណែកការពារ និង ថែរក្សាសន្តិភាព និង សន្តិសុខជាអន្តរជាតិ ជាពិសេស ដើម្បីបង្ការទប់ស្កាត់ និង បង្ក្រាបអំពើភេរវកម្ម និង ឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ប្រភេទ មានជាអាទិ៍ការជួញដូរគ្រឿងញៀន ការជួញដូរមនុស្ស និង បទល្មើសផ្សេងទៀត ។

៣. ការជំរុញការកសាងផែនការយុទ្ធសាស្ត្រ សម្រាប់កងកម្លាំងនគរបាលជាតិ សំដៅពង្រឹងប្រសិទ្ធភាពដឹកនាំបញ្ជាមានទិសដៅច្បាស់លាស់ ដោយធានាភាពសកម្មគ្រប់គ្រងក្នុងការបំពេញមុខងារ ព្រមទាំងពង្រឹងប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងប្រើប្រាស់ធនធានមនុស្ស ធនធានហិរញ្ញវត្ថុ និងធនធានផ្សេងទៀត ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាល នឹងជំរុញកសាងច្បាប់ស្តីពីនគរបាលជាតិ ដែលជាច្បាប់គោលមួយកំណត់អំពីសិទ្ធិ កាតព្វកិច្ច ករណីយកិច្ច និង ការទទួលខុសត្រូវរបស់នគរបាលជាតិទាំងមូល ។

### ២.២.២. បរិស្ថានគ្របដណ្តប់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រចតុកោណ ទី១. សន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និង សណ្តាប់ធ្នាប់សង្គម

29. ក្នុងនីតិកាលទី ៣ កន្លងទៅនេះ រាជរដ្ឋាភិបាល បានពង្រឹងនូវសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និង សណ្តាប់ធ្នាប់សង្គម ដើម្បីសម្រេចបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ការអភិវឌ្ឍ និង ការកាត់បន្ថយភាពក្រីក្រ ។ ជាលទ្ធផល កម្ពុជាបានបង្កើនជំនឿទុកចិត្តពីសំណាក់វិនិយោគិន និង ទេសចរ ដែលត្រូវបានឆ្លុះបញ្ចាំងឡើង តាមរយៈការកើនឡើងនៃការដាក់ទុនវិនិយោគ និង ការកើនឡើង

នៃចំនួនភ្ញៀវទេសចរ ដែលចូលមកទស្សនាកម្ពុជា ។ ទន្ទឹមនឹងនេះ ប្រជាជនយើងអាចរស់នៅប្រកបរបរអាជីវកម្មតាមធម្មតា និង ចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចយ៉ាងសកម្មតាមសមត្ថភាពរៀងៗខ្លួន ។ ការអភិវឌ្ឍនេះ បានក្លាយទៅជាមូលដ្ឋានគ្រឹះនៃការពង្រឹងសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និង សណ្តាប់ធ្នាប់សង្គម សម្រាប់រយៈពេលដ៏យូរអង្វែង ។

**30.** ដូច្នេះ រាជរដ្ឋាភិបាល នឹងបន្តការងាររបស់ខ្លួន ក្នុងគោលដៅពង្រឹងថែមទៀតនូវសន្តិភាព ស្ថិរភាព នយោបាយ សន្តិសុខ និង សណ្តាប់ធ្នាប់សង្គមជូនដល់ប្រជាជន ដើម្បីធានាពង្រឹងលក្ខខណ្ឌគ្រឹះនៃការកសាង និង កែទម្រង់រដ្ឋ សម្រាប់ការបោះជំហានរបស់កម្ពុជាឆ្ពោះទៅរកការអភិវឌ្ឍ និង ភាពកាន់តែចម្រើនរុងរឿង ។ ក្នុងន័យនេះ រាជរដ្ឋាភិបាល នឹងប្រើប្រាស់គ្រប់មធ្យោបាយទាំងអស់ ដើម្បីពង្រឹងសន្តិសុខ និង កាត់បន្ថយឱ្យបានច្រើននូវឧក្រិដ្ឋកម្ម និង បទល្មើសផ្សេងៗ ពង្រឹង *«នីតិរដ្ឋ»* ពង្រឹងការគោរពសិទ្ធិ និង សេចក្តីថ្លៃថ្នូររបស់មនុស្ស ក្នុងគ្រប់ទិដ្ឋភាពទាំងអស់ ដែលផ្តល់នូវកាលានុវត្តភាពប្រកបដោយសមធម៌ជូនប្រជាជនគ្រប់រូប ។

### ទី២. សមាហរណកម្មកម្ពុជានៅក្នុងតំបន់ និង ពិភពលោក

**31.** ក្នុងនីតិកាលទី ៣ នៃរដ្ឋសភា កម្ពុជាបានចូលរួមដោយស្មើភាព និងស្មើសិទ្ធិជាសមាជិកនៅក្នុងអាស៊ាន អង្គការពាណិជ្ជកម្មពិភពលោក ព្រមទាំងបានចូលរួមយ៉ាងសកម្មក្នុងកិច្ចសហប្រតិបត្តិការ និង គំនិតផ្តួចផ្តើមនានា ក្នុងកម្រិតអនុតំបន់តំបន់ អន្តរតំបន់ និងពិភពលោក ជាពិសេស*កិច្ចសហប្រតិបត្តិការមហាអនុតំបន់ទន្លេមេគង្គ (GMS) កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអាយ៉ារ៉ាវ៉ាឌី- ចាវប្រាយ៉ា- មេគង្គ (ACMECS) កិច្ចសហប្រតិបត្តិការនៅក្នុងកម្រិតអនុតំបន់ដទៃទៀត និង កិច្ចប្រជុំ*

*អាស៊ី-អឺរ៉ុប (ASEM)* ជាដើម ។ ដំណើរការសមាហរណកម្មសេដ្ឋកិច្ចកម្ពុជា នៅក្នុងតំបន់ និងពិភពលោក និងការអនុវត្តគោលនយោបាយផ្សារភ្ជាប់ពាណិជ្ជកម្ម ទៅនឹងលក្ខខណ្ឌការងារ បានបង្កើតបរិស្ថានអំណោយផល សម្រាប់ការអភិវឌ្ឍ វិស័យកសិកម្ម ទេសចរណ៍ និង ឧស្សាហកម្ម ជាពិសេស ឧស្សាហកម្មកាត់ដេរ សម្លៀកបំពាក់ និងបានបង្កលក្ខណៈសម្បត្តិឱ្យកសិករកម្ពុជា អាចលក់ដូរផលិតផល របស់ខ្លួននៅលើទីផ្សារតំបន់ និង អន្តរជាតិ ។ ទន្ទឹមនេះ សមាជិកភាពរបស់កម្ពុជា នៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក បាននាំមកនូវឱកាសសមស្របឱ្យកម្ពុជា រៀបចំកំណែទម្រង់ផ្ទៃក្នុង បានទាក់ទាញការវិនិយោគក្នុងស្រុក និង ពីបរទេស និង បានពង្រឹង មូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍសង្គម- សេដ្ឋកិច្ចនៅកម្ពុជា ។

**32.** ដោយពាណិជ្ជកម្ម គឺជាប្រភពសំខាន់នៃកំណើនសេដ្ឋកិច្ច និង ការកាត់បន្ថយភាពក្រីក្រ រាជរដ្ឋាភិបាល នឹងបន្តដំណើរទៅមុខទៀតយ៉ាងស្វាហាប់នៅលើមាគ៌ានៃសេរីភាវូបនីយកម្មពាណិជ្ជកម្ម សំដៅធានាឱ្យទំនិញ និង សេវាគ្រប់ប្រភេទ អាចចរាចរបានដោយសេរីនៅក្នុងទូទាំងប្រទេស និង រវាងប្រទេសកម្ពុជា និង ប្រទេសជាដៃគូសំខាន់ៗនៅក្នុងតំបន់ និង លើសកលលោក ។ រាជរដ្ឋាភិបាល នឹងបន្តបើកច្រកឱ្យផលិតផលកម្ពុជាអាចឈានចូលដោយគ្មានរបាំង និង ឧបសគ្គនានា ទៅកាន់ទីផ្សារដ៏ធំធេងនៅក្នុងតំបន់ និង ក្នុងពិភពលោក ដែលនឹងផ្តល់ឱ្យកម្ពុជានូវកាលានុវត្តភាពនៃវិមាត្រសេដ្ឋកិច្ចដ៏ធំធេង និង ផ្តល់ផលប្រយោជន៍ដល់សេដ្ឋកិច្ចកម្ពុជា ជាកំណើនការវិនិយោគ កំណើនការងារ កំណើនប្រាក់ចំណូល និង កំណើនសេដ្ឋកិច្ចជាតិទាំងមូល ដែលសុទ្ធតែជាកត្តាដ៏សំខាន់ សម្រាប់កាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។

33. ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលនីតិកាលទី ៤ នឹងផ្ដល់អាទិភាពលើការបន្តធ្វើសមាហរណកម្មកម្ពុជាទៅក្នុងតំបន់ និង សហគមន៍អន្តរជាតិ តាមរយៈការជំរុញការងារចូលជាសមាជិកនៃអង្គការសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ី- ប៉ាស៊ីហ្វិក *(APEC)* និង ការចូលរួមកសាងសហគមន៍អាស៊ាន ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលនឹងជំរុញគ្រប់ក្រសួង- ស្ថាប័នទាំងអស់ ឱ្យយកចិត្តទុកដាក់ក្នុងការបំពេញកាតព្វកិច្ចនៃសមាជិកភាពរបស់កម្ពុជា ក្នុងអង្គការពាណិជ្ជកម្មពិភពលោក *(WTO)* តាមរយៈការរៀបចំអនុមតិ និង ការអនុវត្តច្បាប់ និង បទបញ្ញត្តិទាំងឡាយ ។

### ធ៣. ភាពជាដៃគូនៅក្នុងការអភិវឌ្ឍ

34. រាជរដ្ឋាភិបាល បានសម្រេចលទ្ធផលជាច្រើន ក្នុងការពង្រឹងភាពជាដៃគូជាមួយគ្រប់អង្គអភិវឌ្ឍន៍ទាំងអស់ ដែលក្នុងនោះ រួមមានសហគមន៍ដៃគូសហប្រតិបត្តិការអភិវឌ្ឍន៍វិស័យឯកជន និង សង្គមស៊ីវិល ដោយឈរលើគោលការណ៍ជាមូលដ្ឋាន និង ការប្តេជ្ញា ដែលមានចរិតសាកលនានា ដែលធានាឱ្យមានភាពជាម្ចាស់របស់រាជរដ្ឋាភិបាល ក្នុងការដឹកនាំកិច្ចអភិវឌ្ឍប្រទេសជាតិ ។ កម្ពុជា បានទទួលជោគជ័យដ៏ត្រចះត្រចង់ ក្នុងការរៀបចំ និង ដំណើរការជាបន្តបន្ទាប់នូវកិច្ចប្រជុំពិគ្រោះយោបល់ និង ការផ្ទេរកិច្ចដំណើរការនៃកិច្ចប្រជុំពិគ្រោះយោបល់ឱ្យមកជា*«វេទិកានៃកិច្ចសហប្រតិបត្តិការដើម្បីអភិវឌ្ឍកម្ពុជា»* ដែលវេទិកាលើកទី ១ បានប្រព្រឹត្តទៅនៅទីក្រុងភ្នំពេញ នាថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០៧ នៅក្រោមភាពជាម្ចាស់របស់រាជរដ្ឋាភិបាល ។ ជាមួយនោះ វឌ្ឍនភាពនៃការអនុវត្តការដ្ឋានកំណែទម្រង់ ពិសេស លទ្ធផលផ្លែផ្កាគួរជាទីមោទនៈនៃការអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងដំណាក់កាលទី ១ ក៏បានឆ្លុះបញ្ចាំងផងដែរនូវការអនុវត្តដោយជោគជ័យនូវភាពជាដៃគូ ក្នុងការអភិវឌ្ឍរវាងរាជរដ្ឋាភិបាល និង

សហគមន៍ដៃគូសហប្រតិបត្តិការអភិវឌ្ឍន៍ ព្រមទាំងវិស័យឯកជន និង សង្គមស៊ីវិល ។

**35.** រាជរដ្ឋាភិបាល នឹងបន្តពង្រឹងយន្តការ *«វេទិកាកិច្ចសហប្រតិបត្តិការដើម្បីអភិវឌ្ឍកម្ពុជា»* និង *«វេទិការាជរដ្ឋាភិបាល និង វិស័យឯកជន»* ដោយពិចារណាអំពីលទ្ធភាពក្នុងការប្រែក្លាយវេទិកានេះ ឱ្យទៅជា*«វេទិកាអភិវឌ្ឍន៍កម្ពុជា»* ដែលជាយន្តការសម្រាប់រាជរដ្ឋាភិបាល និង ដៃគូអភិវឌ្ឍន៍ទាំងអស់ រួមទាំងដៃគូសហប្រតិបត្តិការអភិវឌ្ឍន៍វិស័យឯកជន និង អង្គការមិនមែនរដ្ឋាភិបាល ក៏ដូចជាបណ្តាភាគីពាក់ព័ន្ធទាំងឡាយចូលរួមពិភាក្សារាល់បញ្ហានានា ដែលពាក់ព័ន្ធនឹងការអភិវឌ្ឍ ទាំងវិស័យសាធារណៈ ទាំងវិស័យឯកជន ។ ទន្ទឹមនេះ យន្តការសម្របសម្រួលនៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និង ដៃគូអភិវឌ្ឍន៍ និង ក្រុមការងារបច្ចេកទេស នឹងត្រូវបានពិនិត្យ និង ពង្រឹងបន្ថែមទៀត ដើម្បីបង្កើនប្រសិទ្ធភាពការងារ ពិសេសកិច្ចសហប្រតិបត្តិការបច្ចេកទេសសម្រាប់ការអភិវឌ្ឍធនធានមនុស្ស និង ស្ថាប័ន និង សម្រាប់ពង្រឹងភាពជាដៃគូរវាងភាគីពាក់ព័ន្ធទាំងអស់ ។ រាជរដ្ឋាភិបាល បន្តលើកទឹកចិត្តអង្គការមិនមែនរដ្ឋាភិបាល និង សមាគមនានា ដែលត្រូវបានបង្កើតឡើងដោយស្របច្បាប់ ហើយប្រតិបត្តិការដោយឈរលើគោលការណ៍អភិបាលកិច្ចល្អ ឱ្យចូលរួមក្នុងកិច្ចដំណើរការស្តារ និង អភិវឌ្ឍន៍សង្គម- សេដ្ឋកិច្ច និងលើកស្ទួយការអនុវត្តលទ្ធិប្រជាធិបតេយ្យ ការគោរពសិទ្ធិ និង សេចក្តីថ្លៃថ្នូររបស់មនុស្ស ព្រមទាំងចូលរួមជាមួយនឹងរាជរដ្ឋាភិបាល ក្នុងការតាមដានការអនុវត្តគោលនយោបាយ និង យុទ្ធសាស្ត្រនានាផងដែរ ។ រាជរដ្ឋាភិបាល នឹងបន្តជំរុញការបង្កើត និង អនុវត្តច្បាប់ស្តីពីអង្គការមិនមែនរដ្ឋា-

ភិបាល និង សមាគម ដោយមានការពិគ្រោះយោបល់ជាមួយនឹងស្ថាប័ន និង អង្គការពាក់ព័ន្ធ ។

**37.** រាជរដ្ឋាភិបាល ប្តេជ្ញាអនុវត្ត *«ផែនការសកម្មភាពទីក្រុងអាក្រា»* ដែលជាលទ្ធផលនៃការសម្រេចចិត្តរបស់វេទិកាកម្រិតខ្ពស់លើកទី ៣ ស្តីពីការបង្កើនប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍ ដើម្បីពង្រឹងភាពជាម្ចាស់ ភាពជាអ្នកដឹកនាំភាពជាដៃគូ និង តម្លាភាពជាមួយដៃគូអភិវឌ្ឍន៍ទាំងអស់ ព្រមទាំងពង្រឹងការគ្រប់គ្រងដោយផ្តោតលើលទ្ធផល ។

***ទី៤. បរិស្ថានម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលមានលក្ខណៈអនុគ្រោះ***

**38.** រាជរដ្ឋាភិបាល បានទទួលជោគជ័យក្នុងការថែរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដែលមានកំណើនសេដ្ឋកិច្ចខ្ពស់ ជាមធ្យម ១១,១% ក្នុងអំឡុងឆ្នាំ ២០០៤-២០០៧ ដែលជាសមិទ្ធកម្មលើសពីគោលដៅដែលបានដាក់ចេញពី ៦ ទៅ ៧% ក្នុងមួយឆ្នាំ ។ ប្រការនេះ បានធ្វើឱ្យចំណូលជាមធ្យមសម្រាប់មនុស្សម្នាក់ៗ បានកើនឡើងពី ៣៩៤ ដុល្លារ នៅឆ្នាំ ២០០៤ មក ៥៩៤ ដុល្លារ នៅឆ្នាំ ២០០៧ ។ ក្នុងរយៈពេលដដែលនេះ ទុនបម្រុងអន្តរជាតិបានកើនឡើងជាងទ្វេដង ហើយនៅដើមឆ្នាំ ២០០៨ នេះ បានកើនឡើងដល់ជិត ២ ពាន់លានដុល្លារអាមេរិក ។ ព្រមជាមួយនោះ អតិផរណាត្រូវបានរក្សាឱ្យនៅក្រោមកម្រិត ៦% ជាមធ្យមក្នុងមួយឆ្នាំ ហើយអត្រាប្តូរប្រាក់ជាទូទៅមានស្ថិរភាពល្អ ។ ការវិនិយោគផ្ទាល់ពីបរទេស បានកើនឡើងជាង ៧ ដងពី ១២១ លានដុល្លារ ក្នុងឆ្នាំ ២០០៤ ទៅ ៨៦៧ លានដុល្លារ ក្នុងឆ្នាំ ២០០៧ ។ បន្ទាប់ពីដាក់ឱ្យអនុវត្តនូវកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ចំណូលថវិកាបានកើនឡើង ២៦% ជាមធ្យមក្នុងមួយឆ្នាំ ។ រាជរដ្ឋាភិបាល បានកែប្រែស្ថានភាពនៃការអនុវត្តថវិកា *ពីភាពរ៉ាំរ៉ៃនៃនិនភាពសាច់ប្រាក់មកមានអតិរេក*

*សាច់ប្រាក់* ដោយធ្វើឱ្យឱកាសមាន *ភាពជឿទុកចិត្តបាន* ។ ទន្ទឹមនេះ រាជរដ្ឋាភិបាល បានអនុវត្តប្រកបដោយជោគជ័យនូវផែនការសកម្មភាព ដែលបានដាក់ចេញក្នុង *«ចក្ខុវិស័យ និង ផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០០១-២០១០»* ហើយត្រូវបានធ្វើបច្ចុប្បន្នកម្មឱ្យទៅជា *«យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០០៦-២០១៥»* ។

**39.** រាជរដ្ឋាភិបាល នឹងបន្តពុះពារដើម្បីសម្រេចឱ្យបាននូវគោលដៅនៃកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងរង្វង់ ៧% ក្នុងមួយឆ្នាំ នៅលើមូលដ្ឋានទូលាយជាងមុន និង មានសមត្ថភាពប្រកួតប្រជែងជាងមុន ក្នុងបរិការណ៍នៃអត្រាអតិផរណាទាបក្នុងកម្រិតតួលេខតែមួយខ្ទង់ អត្រាប្តូរប្រាក់មានស្ថិរភាព និង មានកំណើនទុនបម្រុងជាប្រចាំ ។ រាជរដ្ឋាភិបាល នឹងបន្តអនុវត្តនូវគោលនយោបាយរូបិយវត្ថុ និង ហិរញ្ញវត្ថុសាធារណៈប្រុងប្រយ័ត្ន ដើម្បីពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសលើវិធានការរួមជាកញ្ចប់ ដើម្បីគ្រប់គ្រងអតិផរណា ពិសេស គ្រប់គ្រងថ្លៃទំនិញប្រើប្រាស់ជាមូលដ្ឋានសំខាន់ៗ ដូចជាម្ហូបអាហារ និង ប្រេងឥន្ធនៈ មានជាអាទិ៍ វិធានការសន្សំសំចៃ និង វិចារណកម្មការប្រើប្រាស់ និងវិធានការកាត់បន្ថយកំដៅសេដ្ឋកិច្ចជារួម ។ រាជរដ្ឋាភិបាល នឹងបន្តវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ ដូចជា ផ្លូវថ្នល់ ប្រព័ន្ធធារាសាស្ត្រ និង បណ្តាញចែកចាយថាមពល ដែលអាចកាត់បន្ថយថ្លៃដើមសេដ្ឋកិច្ច និង លើកកម្ពស់ផលិតភាព និង ប្រសិទ្ធភាពសេដ្ឋកិច្ច ព្រមទាំងបង្កើនការវិនិយោគ សម្រាប់បង្កើនផលិតភាពកសិកម្ម ក្នុងគោលដៅឆ្លើយតបប្រកបដោយប្រសិទ្ធភាពទៅនឹងការកើនឡើងនៃថ្លៃម្ហូបអាហារ និង ក្នុងគោលដៅឆក់យកឱកាសនៃការកើនឡើងនូវសេចក្តីត្រូវការស្បៀងនៅក្នុងពិភពលោក ដើម្បីជំរុញការអភិវឌ្ឍវិស័យកសិកម្មកម្ពុជា ។

**40.** ក្នុងទិសដៅធានាកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចិរភាព ដែលជាបុរេ-លក្ខខណ្ឌនៃការបង្កើតការងារ និង បង្កើនចំណូលរបស់ប្រជាជន រាជរដ្ឋាភិបាល នឹងបន្តជំរុញអនុវត្តវិធានការពិពិធភាវូបនីយកម្មសេដ្ឋកិច្ច និង ពង្រឹងសមត្ថភាពប្រកួតប្រជែងរបស់សេដ្ឋកិច្ចកម្ពុជា តាមរយៈការបង្កើតបរិស្ថានអនុគ្រោះដល់ការវិនិយោគ ទាំងវិស័យសាធារណៈ ទាំងវិស័យឯកជន (ទាំងក្នុងស្រុក និង ទាំងបរទេស) សម្រាប់ការអភិវឌ្ឍវិស័យសំខាន់ៗ ដូចតទៅៈ *(១)*. កសិកម្ម *(២)*. ទឹក និង ប្រព័ន្ធស្រោចស្រព *(៣)*. ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន *(៤)*. អគ្គិសនី *(៥)*. ការអភិវឌ្ឍធនធានមនុស្ស*(៦)*. ឧស្សាហកម្មអតិពលកម្ម និង ឧស្សាហកម្មផលិតទំនិញនាំចេញ *(៧)*. ទេសចរណ៍ *(៨)*. អាជីវកម្មប្រេងកាត ឧស្ម័ន ធម្ម-ជាតិ និងរ៉ែដទៃទៀត *(៩)*. បច្ចេកវិទ្យាព័ត៌មានគមនាគមន៍ *(១០)*. ពាណិជ្ជកម្ម ។

**41.** រាជរដ្ឋាភិបាល នឹងពង្រឹងបន្ថែមទៀតនូវវិស័យហិរញ្ញវត្ថុ តាមរយៈការជំរុញអនុវត្តប្រកបដោយប្រសិទ្ធភាពនូវ *«យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០០៦-២០១៥»* ដោយផ្តោតការយកចិត្តទុកដាក់ពិសេសលើវិស័យធនាគារឥណ-ទានជនបទ និង មីក្រូហិរញ្ញវត្ថុ ធានារ៉ាប់រង និង ទីផ្សារមូលបត្រ រួមមានទាំងការជំរុញបង្កើតមជ្ឈមណ្ឌលហិរញ្ញវត្ថុពិសេសផង ដើម្បីកៀរគរធនធានប្រភពហិរញ្ញប្បទានឱ្យបានទូលំទូលាយ ។

**42.** រាជរដ្ឋាភិបាល នឹងបន្តអនុវត្តឱ្យកាន់តែស៊ីជម្រៅថែមទៀតនូវ *«កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ»* ជាពិសេសដំណាក់កាលទី ២ នៃកម្មវិធីនេះ ដើម្បីពង្រឹងប្រសិទ្ធភាពថវិកាជាតិ ដែលជាឧបករណ៍គន្លឹះ ក្នុងការអនុវត្តគោលនយោបាយអភិវឌ្ឍរបស់រាជរដ្ឋាភិបាល ។ ក្នុងន័យនេះ រាជរដ្ឋាភិបាល នឹងបន្តប្រកាន់ខ្ជាប់នូវ *«វិន័យដប់យ៉ាង»* ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ស្របតាមបទបញ្ញត្តិច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ។ រាជរដ្ឋាភិបាល បន្តពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋយ៉ាងហ្មត់ចត់ ស្របតាមច្បាប់ និង បទបញ្ញត្តិជាធរមាន អនុវត្តប្រកបដោយប្រសិទ្ធភាពនូវវិធានការពង្រឹងការប្រមូលចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋគ្រប់ប្រភេទ ។ រាជរដ្ឋាភិបាល បន្តពង្រឹងប្រសិទ្ធភាព តម្លាភាព និង គណនេយ្យភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាល ក៏នឹងផ្ដោតអាទិភាពទៅលើការបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង និង ការធ្វើអាជីវកម្មរបស់សហគ្រាសសាធារណៈតាមរយៈការពង្រឹងសមត្ថភាពគ្រប់គ្រងរបស់ស្ថាប័នអាណាព្យាបាល ទាំងអាណាព្យាបាលបច្ចេកទេស ទាំងអាណាព្យាបាលហិរញ្ញវត្ថុ និង តាមរយៈការជំរុញរៀបចំផែនការធុរកិច្ច លក្ខខណ្ឌវិនិច្ឆ័យប្រតិបត្តិការអាជីវកម្ម និង ការពង្រឹងយន្តការត្រួតពិនិត្យ និង សវនកម្ម ។ ការយកចិត្តទុកដាក់ក៏ត្រូវបានផ្ដោតផងដែរ ទៅលើការកែលំអការគ្រប់គ្រងសហគ្រាសសាធារណៈ ដើម្បីឈានទៅដល់និយាម ដែលអនុញ្ញាតឱ្យសហគ្រាសអាចចូលទៅកៀរគរហិរញ្ញប្បទានពីទីផ្សារមូលបត្របាន ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាល បន្តពង្រឹងតួនាទីរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្នុងការពិនិត្យ និង អនុម័តរាល់កិច្ចព្រមព្រៀង និង កិច្ចសន្យាសម្បទានគ្រប់ប្រភេទស្របតាមបទបញ្ញត្តិច្បាប់ជាធរមាន ។

**43.** រាជរដ្ឋាភិបាល ប្ដេជ្ញាគ្រប់គ្រងឱ្យមានប្រសិទ្ធភាព តម្លាភាព និង គណនេយ្យភាពនូវចំណូល ដែលបានមកពីការធ្វើអាជីវកម្មលើធនធានរ៉ែ ប្រេងកាត និង ឧស្ម័ន ។

## ២.៣. ចតុកោណយុទ្ធសាស្ត្រទាំងបួន សម្រាប់ជំរុញកំណើន

### ចតុកោណទី ១. ការលើកស្ទួយវិស័យកសិកម្ម

**44.** ដោយសារកំណើនសេដ្ឋកិច្ចកម្ពុជានៅមានមូលដ្ឋានតូចចង្អៀត ហើយវិស័យកសិកម្មនៅតែជាវិស័យ ដែលស្រូបពលកម្មច្រើនជាងគេ គួបផ្សំនឹងការកើនឡើងថ្លៃស្បៀងអាហារនៅលើពិភពលោក ការអភិវឌ្ឍវិស័យកសិកម្ម ដែលជាស្នូលនៃសេដ្ឋកិច្ចជនបទ មានអត្ថន័យពីរយ៉ាង គឺការពង្រីកមូលដ្ឋាន និង ការជួយរក្សាចីរភាពនៃកំណើនសេដ្ឋកិច្ចផង និង ការពន្លឿនការកាត់បន្ថយភាពក្រីក្រផង ។ ក្នុងគោលដៅនេះ គោលនយោបាយរបស់រាជរដ្ឋាភិបាល សំដៅជាសំខាន់ទៅលើការលើកកម្ពស់ផលិតភាពកសិកម្ម និង ពិពិធកម្មវិស័យកសិកម្ម ព្រមទាំងលើកំណែទម្រង់ដីធ្លី កំណែទម្រង់ជលផល និង កំណែទម្រង់ព្រៃឈើ ដោយដោះស្រាយជាកញ្ចប់នូវបញ្ហាបច្ចេកទេសកសិកម្ម ហេដ្ឋារចនាសម្ព័ន្ធជនបទ ដូចជាផ្លូវថ្នល់ ធារាសាស្ត្រ និង អគ្គិសនី ព្រមទាំងឥណទាន ទីផ្សារ និង ការកែច្នៃកសិផល ជាពិសេស ការកែច្នៃសម្រាប់ការនាំចេញ ។ ការងារនេះ តម្រូវឱ្យមានយន្តការស្ថាប័ន និង ការសម្របសម្រួល ប្រកបដោយប្រសិទ្ធភាពខ្ពស់ ដើម្បីឱ្យមានវឌ្ឍនភាព និង ការប្រែប្រួលជាគុណភាព ក្នុងវិស័យទាំងមូល ។

#### *មុំទី១. ការលើកកម្ពស់ផលិតភាព និង ពិពិធកម្មកសិកម្ម*

**45.** តម្លៃបន្ថែមក្នុងវិស័យកសិកម្មបានកើនឡើងជាមធ្យម ៧,២% ក្នុងមួយឆ្នាំ ក្នុងដំណាក់កាលឆ្នាំ ២០០៣- ២០០៧ ធៀបទៅនឹង ១,៦% ក្នុងអំឡុងឆ្នាំ ១៩៩៨-២០០២ និង ៤,៩% ក្នុងអំឡុងឆ្នាំ ១៩៩៣-១៩៩៧ ។ កម្ពុជា សម្រេចបាននូវទិន្នផលស្រូវក្នុងរង្វង់ ២,៥ តោន ក្នុងមួយហិកតា ក្នុងអំឡុងឆ្នាំ ២០០៥-២០០៧ ដែលជាទិន្នផលខ្ពស់បំផុតនៅក្នុងប្រវត្តិសាស្ត្រកម្ពុជា ដោយសារការកើនឡើង

នៃការវិនិយោគលើបណ្តាញធារាសាស្ត្រ ការកែលម្អ ការគ្រប់គ្រងទឹក ការកើនឡើងឥណទានពីធនាគារពាណិជ្ជ និង ពីស្ថាប័នមីក្រូហិរញ្ញវត្ថុ និង ការអនុវត្តវិធីដាំដុះប្រសើរជាងមុន ។ ការផ្លាស់ប្តូរទៅរកប្រពលកម្មកសិកម្មកំពុងចាក់ឫសបន្តិចម្តងៗ ។ ការកើនឡើងនៃតម្លៃស្រូវ អង្ករ ពោត សណ្តែក ដំឡូង និង កៅស៊ូ នឹងផ្តល់ការលើកទឹកចិត្តបន្ថែមទៀត ដល់ការអនុវត្តគោលនយោបាយពិពិធភាវូបនីយកម្មកសិកម្មនេះ ។

**46.** រាជរដ្ឋាភិបាល បន្តផ្តល់អាទិភាពខ្ពស់ទៅលើការលើកកម្ពស់ផលិតភាព និងការធ្វើពិពិធភាវូបនីយកម្មកសិកម្ម ព្រមទាំងបន្តជំរុញកសិ- ពាណិជ្ជកម្ម ។ រាជ-រដ្ឋាភិបាល នឹងបន្តយកចិត្តទុកដាក់លើការពង្រីកសមត្ថភាពផលិតលើផ្ទៃដីដែលមានស្រាប់ តាមរយៈការបង្វែទិសពីការអភិវឌ្ឍតាមបែប *«បើកទូលាយ»* ឬ តាមបែប *«វិបុលកម្ម»* ទៅកាន់ការអភិវឌ្ឍតាមបែប *«ស៊ីជម្រៅ»* ឬ តាមបែប *«ប្រពលកម្ម»* ក្នុងគោលដៅបង្កើនផលិតកម្ម បង្កើតការងារ បង្កើនប្រាក់ចំណូលនៅជនបទ និង ធានានូវសន្តិសុខស្បៀង និង បង្កើនការនាំចេញកសិផលជាពិសេស កសិផលសម្រេច សំខាន់គឺបង្កើនការនាំចេញអង្ករ ដោយផ្តោតទៅលើអន្តរាគមន៍ប្រទាក់ក្រឡា ក្នុងវិស័យពាក់ព័ន្ធ ដូចជា ការប្រើប្រាស់ធាតុចូលកសិកម្មតាមបច្ចេកទេស ការស្រាវជ្រាវអភិវឌ្ឍន៍ និង ផ្សព្វផ្សាយកសិកម្ម ការសាងសង់ និង ថែទាំហេដ្ឋារចនាសម្ព័ន្ធជនបទ ជាពិសេស ប្រព័ន្ធធារាសាស្ត្រ ការផ្តល់ឥណទានជនបទ និង មីក្រូហិរញ្ញវត្ថុ ការពង្រីកទីផ្សារកសិកម្ម ការរៀបចំសហគមន៍កសិករ និង ការគ្រប់គ្រងដីធ្លីកសិកម្ម ។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលខិតខំពង្រឹង និង ពង្រីកប្រព័ន្ធសេវាបច្ចេកទេស និង ព័ត៌មានកសិកម្ម ដោយជំរុញសេវានេះ ឱ្យទៅដល់ថ្នាក់ស្រុក ដោយផ្សារភ្ជាប់ជាមួយនឹងបណ្តាញអ្នកស្ម័គ្រចិត្ត

ថ្នាក់ឃុំ ព្រមទាំងទិតខំធានាចីរភាពនៃប្រព័ន្ធសេវាបច្ចេកទេសកសិកម្ម ដែលបាន និង កំពុងអនុវត្តក្នុងក្របខ័ណ្ឌនៃគម្រោងអភិវឌ្ឍន៍នានា ។ រាជរដ្ឋាភិបាល ជំរុញឱ្យមានភាពជាដៃគូរវាងកសិករម្ចាស់ដីតូចៗ និង កសិដ្ឋានខ្នាតធំ សាជីវកម្មកសិកម្ម និង រវាងសម្បទានិកដីសេដ្ឋកិច្ចជាមួយនឹងសម្បទានិកដីសង្គមកិច្ច ជាពិសេសសម្រាប់ដំណាំកសិ-ឧស្សាហកម្ម ជាអាទិ៍ដំណាំកៅស៊ូស្របតាមផែនការយុទ្ធ-សាស្ត្រ អភិវឌ្ឍន៍វិស័យកៅស៊ូ ដំណាំស្វាយចន្ទី ដំណាំអំពៅ ។ រាជរដ្ឋាភិបាលលើកទឹកចិត្តចំពោះ ការអភិវឌ្ឍកសិដ្ឋានពហុបំណង ក្នុងគោលដៅលើកកម្ពស់ផលិតភាពការចិញ្ចឹមសត្វ ការដាំដំណាំចម្រុះ និង ការគួបផ្សំដំណាំជាមួយការចិញ្ចឹមសត្វ ។

**47.** ទន្ទឹមនេះ រាជរដ្ឋាភិបាលជំរុញបង្កើតបរិយាកាសអនុគ្រោះ កាន់តែប្រសើរថែមទៀត សម្រាប់ទាក់ទាញវិនិយោគទុនឯកជន ទាំងក្នុង និង ក្រៅប្រទេស និងស្វាគមន៍ផងដែរ ចំពោះការចូលរួមវិភាគទានរបស់អង្គការមិនមែនរដ្ឋាភិបាល ដើម្បីធានាឱ្យបាននូវការផ្ទេរចំណេះដឹង និង បច្ចេកវិទ្យាថ្មីៗដល់កសិករ ក្នុងការដាំដុះ និង ចិញ្ចឹមសត្វ និង ផ្សារភ្ជាប់កសិករទៅនឹងសង្វាក់ផ្គត់ផ្គង់កសិផលរបស់តំបន់ និង ពិភពលោក ជាពិសេស តាមរយៈការលើកស្ទួយស្តង់ដារគុណភាពកសិផលឱ្យស្របតាមស្តង់ដារអន្តរជាតិ ដោយបង្កើតយន្តការស្ថាប័នសមស្រប ។

*មុំទី២. កំណែទម្រង់ដីធ្លី និង ការបោសសម្អាតមីន*

**48.** កំណែទម្រង់ដីធ្លីរបស់រាជរដ្ឋាភិបាល បានផ្តោតជាសំខាន់លើវិធានការពង្រឹងប្រព័ន្ធគ្រប់គ្រង បែងចែក និង ប្រើប្រាស់ដីធ្លី ការធានាសុវត្ថិភាពនៃកម្មសិទ្ធិដី ការលុបបំបាត់ភាពអនាធិបតេយ្យក្នុងការកាន់កាប់ដីដោយខុសច្បាប់ ការដាក់ចេញនូវវិធានការសមស្រប ដើម្បីទប់ស្កាត់ការប្រមូលដីទុកដោយមិនបានប្រើប្រាស់

និង មិនផលិត ។ ការងារកែទម្រង់ដីធ្លីក៏មានសារៈសំខាន់ផងដែរ ក្នុងការពង្រីក និង បែងចែកដីធ្លីកសិកម្មក្នុងក្របខ័ណ្ឌដីសម្បទានសង្គមកិច្ចជាមូលដ្ឋានសម្រាប់កសិករ សំដៅលើកកម្ពស់ផលិតភាព និង ពិពិធកាវូបនីយកម្មកសិកម្ម ។ ការចុះបញ្ជីដីធ្លី សម្រេចបានលទ្ធផលសមស្រប ដោយបញ្ចប់ការចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធបានចំនួន ១៧៥ ឃុំ- សង្កាត់ ក្នុងទូទាំង ១១ ខេត្ត ក្រុង ។ ដីជាង ១ លានក្បាលដីត្រូវបានផ្តល់ប័ណ្ណកម្មសិទ្ធិរួចហើយ ។

**49.** ក្នុងនីតិកាលទី ៤ នេះ រាជរដ្ឋាភិបាល នឹងបន្តធ្វើកំណែទម្រង់ដីធ្លីក្នុងក្របខ័ណ្ឌច្បាប់ភូមិបាល និង គោលនយោបាយដីធ្លីដែលមានស្រាប់ និង តាមរយៈការរៀបចំក្របខ័ណ្ឌគតិយុត្តបន្ថែមទៀត ដូចជា *ច្បាប់អស្សាមិករណ៍ ច្បាប់ស្តីពីសិទ្ធិបុព្វក្រែ ក្រមសំណង់ និង នគរូបនីយកម្ម* និង *ស្តង់ដារជាតិខាងសំណង់* ។

**50.** រាជរដ្ឋាភិបាល នឹងបន្តពិនិត្យឡើងវិញ និង ដាក់ចេញវិធានការចាំបាច់ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រង និង ប្រើប្រាស់ដីទំនេររបស់រដ្ឋ និង ក្នុងការដោះស្រាយតាមបទបញ្ញត្តិច្បាប់នូវករណីឯកជនកាន់កាប់ដីរដ្ឋ ដោយមិនស្របតាមលិខិតបទដ្ឋានគតិយុត្ត ។ រាជរដ្ឋាភិបាល នឹងជំរុញការធ្វើបញ្ជីសារពើភ័ណ្ឌអចលនទ្រព្យរបស់រដ្ឋ ព្រមទាំងការចុះបញ្ជីជាប្រព័ន្ធឱ្យបានទូលំទូលាយ និង កាន់តែលឿនថែមទៀត ដោយអនុវត្ត *«ច្រកចេញ-ចូលតែមួយ»* លើការផ្តល់សេវាចុះបញ្ជីបន្តឱ្យមានតម្លាភាព និង ដោយផ្តល់អាទិភាពចំពោះតំបន់ដែលគ្មានទំនាស់ និង តំបន់នៃសហគមន៍ជនជាតិដើមភាគតិច ដើម្បីកាត់បន្ថយទំនាស់ដីធ្លី ធានាសុវត្ថិភាពកម្មសិទ្ធិ និង លុបបំបាត់ភាពអនាធិបតេយ្យក្នុងការកាន់កាប់ដី ។ រាជរដ្ឋាភិបាល បន្តដោះស្រាយជម្លោះដីធ្លី ដោយប្រើប្រាស់យន្តការច្បាប់ ដើម្បីធានាយុត្តិធម៌ ដោយតួបផ្សំជាមួយនឹងយន្តការដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការ

ដែលក្នុងនោះ រាជរដ្ឋាភិបាល ផ្ដល់អាទិភាពសមស្របចំពោះសិទ្ធិកាន់កាប់ដីធ្លី សម្រាប់សង់លំនៅដ្ឋាន សម្រាប់កសិកម្ម និង អាជីវកម្មខ្នាតតូចរបស់គ្រួសារក្រីក្រ និង ក្រុមជនងាយរងគ្រោះ ។

**51.** ដើម្បីធានាប្រសិទ្ធភាពក្នុងការប្រើប្រាស់ដី រាជរដ្ឋាភិបាល ជំរុញការរៀបចំផែនការប្រើប្រាស់ដី ដើម្បីបែងចែកដី សម្រាប់ការអភិវឌ្ឍកសិកម្ម ឧស្សាហកម្ម ទេសចរណ៍ តំបន់ទីក្រុង តំបន់ជនបទ តំបន់លំនៅដ្ឋាន តំបន់បម្រុងទុក និង តំបន់អភិរក្ស ចៀសវាងការប្រើប្រាស់ដី និង ការបំប្លែងការប្រើប្រាស់ដីមិនចំសក្ដានុពល ។ រាជរដ្ឋាភិបាល នឹងពិនិត្យឡើងវិញ និង តាមដានជាប្រចាំនូវការអនុវត្តក្នុងក្របខ័ណ្ឌដីសម្បទានសេដ្ឋកិច្ច ដើម្បីឱ្យស្របតាមអាទិភាពរបស់រាជ-រដ្ឋាភិបាល ដែលបានកំណត់ និង ធានាថា ដីសម្បទានសេដ្ឋកិច្ចមានសកម្មភាព ចៀសវាងការទុកចោលមិនមានការផលិត ។ រាជរដ្ឋាភិបាល បន្តអនុវត្តគោល-នយោបាយមិនយកពន្ធលើដីធ្លីកសិកម្មរបស់កសិករ ដែលបង្កបង្កើនផលជាលក្ខណៈគ្រួសារ ។

**52.** វឌ្ឍនភាពក្នុងការបោសសម្អាតមីន ត្រូវបានឆ្លុះបញ្ចាំង តាមរយៈការថយចុះយ៉ាងខ្លាំងនៃអត្រាគ្រោះថ្នាក់ ដោយសារមីន និង យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ដែលនៅឆ្នាំ ២០០៣ មាន ៨០០ ករណី មកត្រឹម ៣១៥ ករណី នៅឆ្នាំ ២០០៧ ការបង្កើនបណ្ដាញផ្លូវថ្នល់ ការពង្រីកផ្ទៃដីកសិកម្ម និង លទ្ធភាពធ្វើដំណើរទូទាំងប្រទេសសឹងតែគ្រប់ច្រកល្ហក ។ ក្នុងនីតិកាលទី ៤ នេះ ការបោសសម្អាតមីន និង យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ នៅតែជាអាទិភាពរបស់រាជរដ្ឋាភិបាល ពិសេសនៅតំបន់ដាច់ស្រយាល តំបន់ដែលកសិករខ្វះដី និង តំបន់មានសក្ដានុពលខ្ពស់ក្នុងការអភិវឌ្ឍកសិកម្ម និង ហេដ្ឋារចនាសម្ព័ន្ធ ។ ទន្ទឹមនឹងនេះ សកម្មភាពដោះមីន និង យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ

ត្រូវផ្សារភ្ជាប់នឹងគោលការណ៍បែងចែកដីសម្បទានរួចហើយនេះ ឱ្យប្រជាកសិករដែលខ្វះដីពិតប្រាកដប្រកបដោយសមធម៌ ។

*មុំទី៣. កំណែទម្រង់ជលផល*

**53.** មច្ឆជាតិជាធនធានធម្មជាតិ ដែលមានសារៈសំខាន់ជាទីបំផុតជាអាហារ ជាចំណូល ជាសំណាញ់សុវត្ថិភាពនៃជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា ។ រាជរដ្ឋាភិបាលបានកាត់ឡូតិ៍នេសាទជូនប្រជាជន ហើយបានបង្កើតសហគមន៍នេសាទ និង សហគមន៍ស្រះជម្រកត្រីសរុប ៥០៩ កន្លែង ទាំងក្នុងដែនទឹកសាប និង ទឹកសមុទ្រ ។ គោលដៅរបស់រាជរដ្ឋាភិបាល គឺរក្សាចីរភាព និង ការកកើតឡើងវិញនៃធនធានធម្មជាតិ ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និង ការថែរក្សាធនធានមច្ឆជាតិឱ្យបានគង់វង្ស ព្រមទាំងការធានាឱ្យបាននូវជីវភាពរស់នៅរបស់អ្នកនេសាទ ។

**54.** រាជរដ្ឋាភិបាល បន្តផ្តល់អាទិភាពលើការរៀបចំសហគមន៍នេសាទ ដោយជំរុញសហគមន៍ជនបទឱ្យចូលរួម ក្នុងការរៀបចំផែនការ និង គ្រប់គ្រងធនធានជលផលដោយខ្លួនឯង ដោយមានការតម្រង់ទិសផ្តល់បច្ចេកទេសបណ្តុះបណ្តាលពីសំណាក់រាជរដ្ឋាភិបាល ដើម្បីធានាចីរភាពក្នុងការគ្រប់គ្រងធនធានជលផលតាមរយៈបទដ្ឋានបច្ចេកទេសច្បាស់លាស់ ។ ក្នុងន័យនេះ រាជរដ្ឋាភិបាល នឹងកំណត់ព្រំប្រទល់ឡូតិ៍នេសាទឱ្យបានត្រឹមត្រូវ ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រង ។

**55.** ដើម្បីធានាថា តម្លៃមច្ឆជាតិឆ្លុះបញ្ចាំងពីតម្លៃសេដ្ឋកិច្ចពិតប្រាកដ រាជរដ្ឋាភិបាលនឹងរៀបចំយន្តការទីផ្សារមច្ឆជាតិមួយឱ្យបានល្អ ពីព្រោះតម្លៃត្រីជាចំណូលផង និង ជាចំណាយផង សម្រាប់ជនក្រីក្រ ។ យន្តការទីផ្សារនេះ រួមបញ្ចូលការកែ

ផ្លូវប្រព័ន្ធដេញថ្លៃឡូតិ៍នេសាទមួយប្រកបដោយតម្លាភាព ដែលនឹងបង្កើន ប្រសិទ្ធភាពសេដ្ឋកិច្ច ក្នុងការធ្វើអាជីវកម្មឡូតិ៍នេសាទ ក៏ដូចជាបង្កើនចំណូលរបស់រដ្ឋ ។

**56.** រាជរដ្ឋាភិបាល នឹងបន្តពង្រឹងការងារអភិរក្សធនធានធម្មជាតិបន្ថែមទៀត ជាពិសេស ការលើកកម្ពស់ការផ្សារភ្ជាប់ការអភិរក្សទៅនឹងទេសចរណ៍ធម្មជាតិ ។ រាជរដ្ឋាភិបាល នឹងបន្តចាត់វិធានការតឹងរ៉ឹងបំផុតចំពោះការទន្ទ្រានព្រៃលិចទឹក ដោយខុសច្បាប់ ការនេសាទដោយប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ និង សកម្មភាពបែបអនាធិបតេយ្យទាំងឡាយ ដែលរាំងស្ទះដល់ការងារអភិរក្ស ដោយជំរុញឱ្យមានការចូលរួមទប់ស្កាត់ពីអាជ្ញាធរដែនដី និង សមត្ថកិច្ចពាក់ព័ន្ធនានានៅមូលដ្ឋាន ។

**57.** ការបំផុសភាពរីវប្បកម្ម គឺជាលក្ខខណ្ឌមិនអាចខ្វះបានក្នុងការថែរក្សាធនធានមច្ឆជាតិឱ្យបានគង់វង្ស ដោយរាជរដ្ឋាភិបាលនឹងជំរុញផ្តល់ជាកញ្ចប់នូវបច្ចេកទេស ពូជ ឥណទាន និង ទីផ្សារជូនកសិករ ។ ការពង្រឹងការអនុវត្តច្បាប់ និង យន្តការដែលមានស្រាប់ គឺជាអាទិភាពរបស់រាជរដ្ឋាភិបាលក្នុងការថែរក្សាធនធានជលផលតាមរយៈវិធានការរដ្ឋបាលតឹងរ៉ឹង ។

*មុំទី៤. កំណែទម្រង់ព្រៃឈើ*

**58.** គោលនយោបាយព្រៃឈើរបស់រាជរដ្ឋាភិបាល គឺការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព និង ការប្រើប្រាស់ធនធានព្រៃឈើ សម្រាប់លើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជននៅតំបន់ជនបទ និង ចូលរួមក្នុងកំណើនសេដ្ឋកិច្ចជាតិ ។ កន្លងមក រាជរដ្ឋាភិបាល បានផ្អាកការធ្វើអាជីវកម្មព្រៃឈើ បង្កើតតំបន់ការពារ និងអភិរក្សធនធានជីវចម្រុះ ការដាំព្រៃឈើឡើងវិញ ការរៀបចំសហគមន៍

ព្រៃឈើ ការកំណត់ព្រំប្រទល់ឱ្យបានច្បាស់លាស់ និង ការចាត់វិធានការទប់ស្កាត់បង្ក្រាប និងលុបបំបាត់ការដុតរានឈូសឆាយ និងហ៊ុំព័ទ្ធដីព្រៃធ្វើកម្មសិទ្ធិឯកជន ។

**59.** រាជរដ្ឋាភិបាល ចាត់ទុកសហគមន៍ព្រៃឈើជាការងារអាទិភាពក្នុងការគ្រប់គ្រងព្រៃឈើ ។ ក្នុងន័យនេះ រាជរដ្ឋាភិបាល នឹងបន្តតាមដានវាយតម្លៃប្រសិទ្ធភាពកម្មវិធីលើកកម្ពស់កម្រិតជីវភាពប្រជាជនជនបទ និង ថែរក្សាចីរភាពព្រៃឈើ និងជំរុញការអនុវត្តព្រៃសហគមន៍ឱ្យបានកាន់តែទូលំទូលាយ ។ ទន្ទឹមនឹងនេះដែររាជរដ្ឋាភិបាល ផ្តល់ការលើកទឹកចិត្តដល់វិស័យឯកជន ក្នុងការដាំដុះព្រៃឯកជនដែលមានលក្ខណៈសេដ្ឋកិច្ច ដោយមានបទដ្ឋានបច្ចេកទេសច្បាស់លាស់ ពិសេសក្នុងតំបន់ព្រៃឈើរិចរិល ។

**60.** រាជរដ្ឋាភិបាល នឹងបន្តយកចិត្តទុកដាក់ត្រួតពិនិត្យតាមដានការធ្វើអាជីវកម្មព្រៃឈើ ឱ្យសមស្របតាមបទដ្ឋានអន្តរជាតិ ដោយស្វែងរកហិរញ្ញប្បទានខាងផ្នែកបច្ចេកទេស និង សម្ភារៈ ដើម្បីធានាប្រសិទ្ធភាពការងារ និង អនុញ្ញាតឱ្យសង្គមស៊ីវិលបានចូលរួមសកម្ម និង សមស្របជាងមុនក្នុងការងារតាមដាននេះ ។ រាជរដ្ឋាភិបាល នឹងយកចិត្តទុកដាក់បន្ត ក្នុងការពង្រឹងការអនុវត្តច្បាប់ព្រៃឈើ និងដាក់វិធានការម៉ឺងម៉ាត់ចំពោះបទល្មើសព្រៃឈើ ព្រមទាំងបន្តអប់រំប្រជាពលរដ្ឋឱ្យយល់ពីកាតព្វកិច្ចការពារព្រៃឈើ និង បញ្ឈប់ការកាប់រានព្រៃដោយខុសច្បាប់ ។

**61.** ដោយសារព្រៃឈើជាអាយុជីវិតរបស់ប្រជាជន រាជរដ្ឋាភិបាល នឹងបង្កើនប្រសិទ្ធភាពគ្រប់គ្រងព្រៃបម្រុង ដែលត្រូវទទួលបានការការពារ និង អភិវឌ្ឍដ៏សមស្រប ដើម្បីបង្កើតការងារ និង ប្រភពចំណូលបន្ថែមជូនប្រជាជន ដូចជាការអភិវឌ្ឍទេសចរណ៍ធម្មជាតិជាដើម ។ ទន្ទឹមនេះ ការគ្រប់គ្រងតំបន់ការពារធម្មជាតិក៏ត្រូវបន្តទទួលបាននូវការយកចិត្តទុកដាក់ខ្ពស់ផងដែរ ។ លើសពីនេះ រាជរដ្ឋា-

ភិបាល នឹងប្រមូលធនធាន ការគាំទ្រ និង ហិរញ្ញប្បទាននានា ដើម្បីរួមដោះស្រាយបញ្ហាបម្រែបម្រួលអាកាសធាតុ ដែលជាបញ្ហាប្រឈមរបស់ពិភពលោកនាពេលបច្ចុប្បន្ន ។

## ចតុកោណទី ២. ការបន្តស្តារ និង កសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

### *មុំទី១. ការបន្តស្តារ និង កសាងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍*

62. ក្នុងបរិការណ៍កម្ពុជាបច្ចុប្បន្ន បណ្តាញគមនាគមន៍ មានតួនាទីជា ***«ក្បាលរថភ្លើងនៃកំណើនសេដ្ឋកិច្ច»*** និង ជាសរសៃឈាម សម្រាប់តភ្ជាប់គ្រប់ច្រកល្ហកនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្លាយជាសរីរាង្គសេដ្ឋកិច្ចមួយ ក្នុងគោលដៅធ្វើសមាហរណកម្មផ្ទៃក្នុងខ្លួនឯងផង និង ក្នុងគោលដៅសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាទៅក្នុងសេដ្ឋកិច្ចតំបន់ និង ពិភពលោកផង ។ លើមូលដ្ឋាននៃសមិទ្ធផលដែលរាជរដ្ឋាភិបាលបញ្ចប់បានស្ទើរតែទាំងស្រុងនូវការស្តារ និង កសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តផ្លូវថ្នល់ថ្នាក់ជាតិសំខាន់ៗ រាជរដ្ឋាភិបាល នឹងបន្តផ្តល់អាទិភាពខ្ពស់ទៅលើការស្តារ និង កសាងប្រព័ន្ធគមនាគមន៍ដឹកជញ្ជូនពហុប្រភេទ ដែលតភ្ជាប់រវាងគ្រប់តំបន់នៅទូទាំងប្រទេស និង តភ្ជាប់ជាមួយបណ្តាប្រទេសជិតខាង ឱ្យទៅជាប្រព័ន្ធគមនាគមន៍ និង បណ្តាញសេវាដឹកជញ្ជូនមួយងាយស្រួល មានស្ថិរភាព មានសុវត្ថិភាព មានប្រសិទ្ធភាពសេដ្ឋកិច្ច និង មានតម្លៃទាប ក្នុងទិសដៅសម្រួលដល់ការធ្វើ ពាណិជ្ជកម្ម ជំរុញវិស័យទេសចរណ៍ ការអភិវឌ្ឍជនបទ ការធ្វើសមាហរណកម្មសេដ្ឋកិច្ច ក្នុងតំបន់ និង សកលលោក ព្រមទាំងបម្រើដល់កិច្ចការពារជាតិថែមទៀតផង ។

63. រាជរដ្ឋាភិបាល មានគោលដៅបន្តស្តារហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ ដោយផ្តោតអាទិភាពខ្ពស់លើការថែទាំផ្លូវជាតិ ការបន្តកសាងផ្លូវខេត្ត និង

ជនបទ ការស្តារ និង ពង្រីកសមត្ថភាពរបស់កំពង់ផែធំៗ និង ការស្តារ និង កសាងបណ្តាញអយស្ម័យយាន ដើម្បីតភ្ជាប់ជាមួយបណ្តាញអយស្ម័យយាន នៃប្រទេសជិតខាង ក្នុងក្របខ័ណ្ឌមហាអនុតំបន់មេគង្គ ។ រាជរដ្ឋាភិបាល នឹងសម្រេចឱ្យបាននូវការធ្វើឯកជនូបនីយកម្មនៃកិច្ចប្រតិបត្តិការអាជីវកម្មនៃរាជាយស្ម័យយានកម្ពុជា ព្រមទាំងនឹងបន្តលើកទឹកចិត្តដល់ការចូលរួមពីវិស័យឯកជន ក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធ និង ការផ្តល់សេវាដឹកជញ្ជូន ។

**64.** រាជរដ្ឋាភិបាល នឹងជំរុញអនុវត្តការចូលរួមដេញថ្លៃដោយវិស័យឯកជន ក្នុងកិច្ចសន្យាថែទាំផ្លូវខួប និង ថែទាំជាប្រចាំឱ្យកាន់តែទូលំទូលាយ ហើយពង្រឹងសមត្ថភាពគ្រប់គ្រង និង ត្រួតពិនិត្យបច្ចេកទេសរបស់មន្ទីរសាធារណការ និង ដឹកជញ្ជូន និង មន្ទីរអភិវឌ្ឍន៍ជនបទ ។ រាជរដ្ឋាភិបាល នឹងបន្តគោលនយោបាយបើកចំហជើងមេឃ និង ពង្រឹងសុវត្ថិភាពហោះហើរ ព្រមទាំងពង្រីក និង ពង្រឹងសេវាព្រលានយន្តហោះ ។

**65.** រាជរដ្ឋាភិបាល នឹងជំរុញអនុម័តច្បាប់ស្តីពីផ្លូវថ្នល់ ព្រមទាំងច្បាប់ និង លិខិតបទដ្ឋានផ្សេងៗទៀត សម្រាប់ការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនឱ្យកាន់តែមានប្រសិទ្ធភាព ។ រាជរដ្ឋាភិបាល នឹងផ្តោតការយកចិត្តទុកដាក់ផងដែរដល់ការងារសុវត្ថិភាពចរាចរ និង មានវិធានការម៉ឺងម៉ាត់ចំពោះបទល្មើសដឹកជញ្ជូនលើសទម្ងន់ ។

*មុំទី២. ការគ្រប់គ្រងធនធានទឹក និង ប្រព័ន្ធធារាសាស្ត្រ*

**66.** រាជរដ្ឋាភិបាល បានខិតខំស្តារ និង កសាងប្រព័ន្ធធារាសាស្ត្រ ហើយបានដាក់ចេញនូវវិធានការ ដើម្បីប្រើឱ្យអស់លទ្ធភាពនូវសក្តានុពលពីប្រព័ន្ធធារាសាស្ត្រនេះ ដើម្បីដោះស្រាយបញ្ហាទឹក សម្រាប់វិស័យកសិកម្ម ។ ជាលទ្ធផល

សមត្ថភាពស្តុកទឹកត្រូវបានពង្រីក ហើយលទ្ធភាពនៃការដោះស្រាយទឹក សម្រាប់ការដាំដុះ ក៏បានកើនឡើង ។ រាជរដ្ឋាភិបាល បានបង្កើតសហគមន៍កសិករប្រើ-ប្រាស់ទឹក ដែលមានការចូលរួមកាន់តែច្រើនឡើងពីសំណាក់កសិករ ។ ការផ្គត់ផ្គង់ទឹកស្អាតនៅទីក្រុង និង ទីប្រជុំជន ក៏មានការរីកចម្រើនគួរឱ្យកត់សម្គាល់ផងដែរ ។

**67.** រាជរដ្ឋាភិបាល នឹងបន្តផ្តល់អាទិភាពខ្ពស់ដល់ការស្តារ ការកសាង ការថែទាំ និង ការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព នូវហេដ្ឋារចនាសម្ព័ន្ធស្រោចស្រព អាងស្តុកទឹក ប្រឡាយទឹក លូទឹក ប្រព័ន្ធដោះទឹក ប្រឡាយនាំដីល្បាប់ ទំនប់ការពារទឹកជំនន់- ទឹកប្រៃ និងស្ថានីយបូមទឹក ដើម្បីបង្កើនផ្ទៃដីស្រោចស្រព និងជំរុញការងារបង្កបង្កើនផល ។

**68.** រាជរដ្ឋាភិបាល នឹងផ្តោតការយកចិត្តទុកដាក់លើការធានាសិទ្ធិរបស់ប្រជា-ពលរដ្ឋ ក្នុងការទទួលបានទឹកស្អាត តាមរយៈការផ្គត់ផ្គង់ទឹកស្អាតគ្រប់គ្រាន់ជូនប្រជាជនគ្រប់រូប ដើម្បីធានាសន្តិសុខស្បៀង ក្នុងជីវភាពរស់នៅរបស់ប្រជាជនស្របតាមគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា និង តាមរយៈការធានាបាននូវប្រព័ន្ធអេកូឡូស៊ី និង បរិស្ថានទឹកគ្មានការបំពុល ។ ជាចក្ខុវិស័យសម្រាប់អនាគតក្នុងការគ្រប់គ្រងទឹកនៃអាងទន្លេមេគង្គ រាជរដ្ឋាភិបាល នឹងបន្តមានវិធានការធ្វើវិចារណកម្មការប្រើប្រាស់ធនធានទឹកនៅគ្រប់ដងស្ទឹង បឹង និង ទន្លេ រួមទាំងបឹងទន្លេសាបផង ។

**69.** រាជរដ្ឋាភិបាល នឹងបង្កើនប្រសិទ្ធភាពគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ តាមរយៈការពង្រឹងសមត្ថភាពស្ថាប័នពាក់ព័ន្ធ និង ការពង្រឹងភាពជាម្ចាស់របស់ប្រជាជនក្នុងការចូលរួមគ្រប់គ្រង និងប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រ តាមបែបវិមជ្ឈការ ដើម្បីដោះស្រាយទឹក សម្រាប់បង្កបង្កើនផលផង សម្រួលដល់ការធ្វើដំណើររបស់

ប្រជាជនផង និង អនុវត្តវារីវប្បកម្មផង និង តាមរយៈការពង្រឹងសមត្ថភាពរបស់សហគមន៍កសិករប្រើប្រាស់ទឹក ។ ទន្ទឹមនឹងការកៀរគរធនធានពីដៃគូអភិវឌ្ឍ និង ធនធានផ្ទាល់របស់ខ្លួន ដើម្បីធ្វើការវិនិយោគក្នុងវិស័យនេះ រាជរដ្ឋាភិបាល នឹងបន្តជំរុញឱ្យវិស័យឯកជនមានការចូលរួមចំណែកយ៉ាងសកម្មបន្ថែមទៀត ក្នុងការអភិវឌ្ឍ និង ការគ្រប់គ្រងវិស័យធារាសាស្ត្រ និង ការផ្គត់ផ្គង់ទឹកស្អាត ។

*មុំទី៣. ការអភិវឌ្ឍវិស័យថាមពល*

**70.** ក្នុងនីតិកាលទី ៣ កន្លងទៅ រាជរដ្ឋាភិបាលសម្រេចបាននូវការស្តារប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី ដែលកំពុងមានស្រាប់ឡើងវិញ និង រៀបចំឱ្យមានការផ្គត់ផ្គង់អគ្គិសនីនៅតំបន់សំខាន់ៗមួយចំនួនទៀត ។ ជាលទ្ធផលជាក់ស្តែងសំខាន់ៗរួមមានៈ *(១)*. ការចាប់ផ្តើមការសាងសង់វារីអគ្គិសនីកំចាយ និង អាតៃ ព្រមទាំងបណ្តាញបញ្ជូនអគ្គិសនីមួយចំនួន *(២)*. ការផ្គត់ផ្គង់អគ្គិសនីនៅរាជធានីភ្នំពេញ ត្រូវបានស្តារឡើងវិញ និង ត្រូវបានពង្រីកឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង *(៣)*. ការផ្គត់ផ្គង់អគ្គិសនីនៅតាមបណ្តាទីរួមខេត្ត ក៏ត្រូវបានស្តារ និង កសាងថ្មី ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការក្នុងទីរួមខេត្តទាំងនោះ *(៤)*. ទីប្រជុំជននានាជាប់ព្រំដែនត្រូវបានរៀបចំឱ្យមានការផ្គត់ផ្គង់អគ្គិសនី តាមរយៈការនាំចូលអគ្គិសនីពីប្រទេសជិតខាង ដែលមានតម្លៃថោក *(៥)*. តំបន់ជនបទនានា ក៏ត្រូវបានរៀបចំឱ្យ មានការផ្គត់ផ្គង់អគ្គិសនីផងដែរ តាមរូបភាពតូចៗ ដោយសេវាករឯកជនក្នុងក្របខ័ណ្ឌនៃអាជ្ញាប័ណ្ណស្របតាមច្បាប់ស្តីពីអគ្គិសនី ។

**71.** រាជរដ្ឋាភិបាលនីតិកាលទី ៤ នឹងផ្តល់អាទិភាពក្នុងការបន្តពង្រីកវិសាលភាពនៃការផ្គត់ផ្គង់ និង បញ្ចុះថ្លៃអគ្គិសនីឱ្យបានសមរម្យ ព្រមទាំងយកចិត្តទុកដាក់លើការពង្រឹងយន្តការស្ថាប័ន និង សមត្ថភាពគ្រប់គ្រង ។ ក្នុងន័យនេះ រាជរដ្ឋាភិបាល

នឹងបន្តជំរុញការបង្កើតរោងចក្រផលិតអគ្គិសនី ដែលមានថ្លៃដើមថោកប្រើប្រភពថាមពលក្នុងស្រុក ដូចជា វារីអគ្គិសនី ឧស្ម័នធម្មជាតិ រ៉ែធ្យូងថ្ម គួបផ្សំនឹងការអភិវឌ្ឍរោងចក្រផលិតអគ្គិសនីដែលប្រើបច្ចេកវិទ្យាទំនើប និង ប្រភពថាមពលបែបមិនមែនប្រពៃណី រួមបញ្ចូលនូវការពិនិត្យលទ្ធភាពប្រើប្រាស់ប្រភពថាមពលនុយក្លេអ៊ែរផង ព្រមទាំងការបន្តតភ្ជាប់បណ្ដាញថាមពលអគ្គិសនីជាមួយប្រទេសជិតខាង ។ ការធ្វើពិពិធភាវូបនីយកម្មប្រភពថាមពល និង ការបង្កើតឱ្យមានប្រភពថាមពលបម្រុងសមស្របក្នុងប្រព័ន្ធ គឺជាកត្តាគន្លឹះក្នុងការធានាសន្តិសុខថាមពលសម្រាប់កម្ពុជា ។ ជាមួយគ្នានេះ រាជរដ្ឋាភិបាល នឹងជំរុញកសាងប្រព័ន្ធបណ្ដាញអគ្គិសនី ឱ្យគ្របដណ្ដប់ទូទាំងប្រទេស ដើម្បីបញ្ជូនថាមពល ដែលមានគុណភាព និង ថ្លៃសមរម្យពីប្រភពនានា ទៅផ្គត់ផ្គង់សេចក្ដីត្រូវការនៅតាមបណ្ដាទីក្រុង ទីរួមខេត្ត ទីប្រជុំជន និង តំបន់ជនបទទាំងឡាយ ព្រមទាំងរៀបចំជាបណ្ដើរៗ ដើម្បីធ្វើសមាហរណកម្មប្រព័ន្ធថាមពលអគ្គិសនីកម្ពុជា ទៅក្នុងបណ្ដាញប្រទេសក្នុងមហាអនុតំបន់មេគង្គ និង អាស៊ាន ។

**72.** ដើម្បីចូលរួមក្នុងការកាត់បន្ថយភាពក្រីក្រ និង ធានានូវការរស់នៅដោយសុខដុមរមនារបស់ប្រជាជន នៅតំបន់ជនបទ រាជរដ្ឋាភិបាល នឹងផ្ដល់អាទិភាពជំរុញអនុវត្តអគ្គិសនីនីយកម្មជនបទជាបន្តទៀត រួមទាំងកាអភិវឌ្ឍថាមពលកកើតឡើងវិញ ដើម្បីឱ្យប្រជាជននៅតំបន់ជនបទមានអគ្គិសនីប្រើប្រាស់ ។

**73.** រាជរដ្ឋាភិបាល នឹងផ្ដល់អាទិភាពខ្ពស់ទៅលើការទាក់ទាញឱ្យមានការចូលរួមរបស់វិស័យឯកជននៅក្នុងការវិនិយោគអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធថាមពល ទាំងការផលិត ការបញ្ជូន និង ការចែកចាយ ក្នុងនោះ រាជរដ្ឋាភិបាល នឹងបន្តខិតខំគិតគូរឱ្យបានជាអតិបរមាលើបរិស្ថានធម្មជាតិ និង សង្គម ក្នុងការអភិវឌ្ឍគម្រោង

វិស័យថាមពល ទន្ទឹមនឹងការសង្កត់ធ្ងន់លើប្រសិទ្ធភាពសេដ្ឋកិច្ចរបស់គម្រោងនីមួយៗ ។ ការយកចិត្តទុកដាក់ក៏នឹងត្រូវផ្ដោតជាសំខាន់ផងដែរ លើការកសាងសមត្ថភាព និង ការកែទម្រង់ស្ថាប័នក្នុងវិស័យថាមពលអគ្គិសនី រួមមានអាជ្ញាធរអគ្គិសនី ក្រុមហ៊ុនអគ្គិសនីកម្ពុជា ព្រមទាំងក្រសួងស្ថាប័នពាក់ព័ន្ធផ្សេងទៀត ដើម្បីបង្កើនប្រសិទ្ធភាពគ្រប់គ្រង ក៏ដូចជាគុណភាពសេវាផ្គត់ផ្គង់អគ្គិសនី ។

**74.** រាជរដ្ឋាភិបាល ចាត់ទុកធនធានប្រេង និង ឧស្ម័នកម្ពុជា គឺជាសក្ដានុពលថ្មីដ៏សំខាន់ សម្រាប់ធានាសន្តិសុខថាមពល និង ជាប្រភពនៃធនធានដ៏មានតម្លៃក្នុងការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជាក្នុងរយៈពេលវែង ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលនឹងរៀបចំក្របខ័ណ្ឌគោលនយោបាយ និង ក្របខ័ណ្ឌគតិយុត្ត សម្រាប់វិស័យនេះ ដើម្បីធានាប្រសិទ្ធភាពនៃការគ្រប់គ្រង និង ការប្រើប្រាស់ធនធាននេះ ក្នុងបុព្វហេតុនៃការអភិវឌ្ឍសេដ្ឋកិច្ច និង ការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា ។

**75.** រាជរដ្ឋាភិបាលលើកទឹកចិត្តឱ្យប្រើប្រាស់ប្រភេទថាមពល ដែលមានប្រសិទ្ធភាព និង មានផលប៉ះពាល់តិចដល់បរិស្ថាន ។

### *មុំទី៤. ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានគមនាគមន៍*

**76.** ក្នុងនីតិកាលទី ៣ កន្លងមក វិស័យបច្ចេកវិទ្យាព័ត៌មានគមនាគមន៍ សម្រេចបាននូវការរីកចម្រើនគួរឱ្យកត់សម្គាល់ តាមរយៈការពង្រីកវិសាលភាពគ្របដណ្ដប់នៃសេវាប្រៃសណីយ៍ និង ទូរគមនាគមន៍ រួមទាំងសេវាអ៊ីនធឺណេតផង និង ការកើនឡើងនៃចំនួនអ្នកប្រើប្រាស់សេវានេះ ។

**77.** ដោយវិស័យនេះ ជាវិស័យមួយប្រកបដោយការប្រកួតប្រជែងខ្ពស់ រាជរដ្ឋាភិបាល នឹងបន្តអភិវឌ្ឍប្រព័ន្ធប្រៃសណីយ៍ និង ទូរគមនាគមន៍ និង ជំរុញការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានគមនាគមន៍ទំនើបទាន់សម័យ ប្រកបដោយគុណភាព

ខ្ពស់ ស្របតាមស្តង់ដារអន្តរជាតិ មានថ្លៃថោកសមរម្យ និង មានសេវាគ្របដណ្តប់ទូទាំងប្រទេស ដោយផ្តោតលើអាទិភាពដូចតទៅ *(១)*. ជំរុញអនុម័តច្បាប់ស្តីពីទូរគមនាគមន៍ និង លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ *(២)*. កសាងសមត្ថភាពស្ថាប័នក្នុងវិស័យនេះ *(៣)*. កែលម្អ និង ជំរុញធ្វើទំនើបកម្មមូលដ្ឋានសម្ភារៈបច្ចេកទេសនៃវិស័យនេះ ដើម្បីធានាប្រសិទ្ធភាព និងវិសាលភាពនៃសេវា *(៤)*. លើកស្ទួយការប្រកួតប្រជែង នៅក្នុងទីផ្សារសេវាប្រៃសណីយ៍ និង ទូរគមនាគមន៍ ដើម្បីធានាប្រសិទ្ធភាពនៃវិស័យនេះ *(៥)*. បន្តពង្រឹងប្រសិទ្ធភាពនៃការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និង រដ្ឋបាលអេឡិចត្រូនិច *(៦)*. ជំរុញកសាង និង បង្កើនប្រសិទ្ធភាពនៃហេដ្ឋារចនាសម្ព័ន្ធឆ្អឹងខ្នង សម្រាប់វិស័យបច្ចេកវិទ្យាព័ត៌មាន គមនាគមន៍ ។

### ចតុកោណទី៣. ការអភិវឌ្ឍវិស័យឯកជន និង ការងារ

#### មុំទី ១. ការពង្រឹងវិស័យឯកជន និង ការទាក់ទាញការវិនិយោគ

**78.** រាជរដ្ឋាភិបាល បានធ្វើឱ្យតម្លៃនៃការធ្វើធុរកិច្ចថយចុះ និង ពង្រីកទីផ្សារ កាត់បន្ថយចំណាយលើការដឹកជញ្ជូន និង កែលម្អសុវត្ថិភាពធ្វើដំណើរ តាមរយៈការកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដោយធានាបាននូវសមាហរណកម្មសេដ្ឋកិច្ចជនបទជាមួយនឹងសេដ្ឋកិច្ចទីក្រុង ។ រាជរដ្ឋាភិបាលបានរៀបចំក្របខ័ណ្ឌគតិយុត្តចាំបាច់ជាច្រើន សម្រាប់គាំទ្រការអភិវឌ្ឍវិស័យឯកជន និង បានពង្រឹង *«វេទិការាជរដ្ឋាភិបាល-វិស័យឯកជន»* ឱ្យទៅជាយន្តការដោះស្រាយបញ្ហាដ៏មានប្រសិទ្ធភាព ។ កិច្ចសម្រួលពាណិជ្ជកម្មបានកាត់បន្ថយនូវការតម្រូវខាងឯកសារ ដែលជួយសម្រួលដល់ធុរកិច្ចនានា ជាពិសេសតាមរយៈការដាក់ឱ្យអនុវត្តនូវប្រព័ន្ធ *«រដ្ឋបាលតែមួយ»* និង សេវា *«ច្រកចេញ-ចូលតែមួយ»* ។

**79.** រាជរដ្ឋាភិបាល នឹងបន្តផ្តោតអាទិភាពលើការកែលម្អហេដ្ឋារចនាសម្ព័ន្ធរឹបវន្ត សម្រាប់ការអភិវឌ្ឍវិស័យឯកជន តាមរយៈការបង្កើនការវិនិយោគសាធារណៈ ក្នុងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនផ្លូវគោក រួមមាន ផ្លូវថ្នល់ និង ផ្លូវដែក ផ្លូវទឹក រួមទាំងតាមទន្លេ និង សមុទ្រ និង ផ្លូវអាកាស ការជំរុញការផលិត និង ការពង្រីកបណ្តាញចែកចាយអគ្គិសនីនៅទីប្រជុំជន និង ទីជនបទ ក្នុងថ្លៃថោកសមរម្យ ការពង្រឹង និងពង្រីកបណ្តាញទូរគមនាគមន៍ ដែលមានសេវាទំនើប ក្នុងថ្លៃថោកសមរម្យ ការពង្រឹង និង ពង្រីកបណ្តាញផ្គត់ផ្គង់ទឹកស្អាត ព្រមទាំងការពង្រឹង និង ពង្រីកប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ សម្រាបវិស័យទេសចរណ៍វប្បធម៌ និង ទេសចរណ៍ធម្មជាតិ ។

**80.** រាជរដ្ឋាភិបាល នឹងបន្តកិច្ចខិតខំប្រឹងប្រែង ដើម្បីពង្រីកច្រកចូលទៅកាន់ទីផ្សារអន្តរជាតិ តាមរយៈការអនុវត្តយ៉ាងម៉ឺងម៉ាត់នូវកាតព្វកិច្ចរបស់ខ្លួន ក្នុងក្របខ័ណ្ឌនៃអង្គការពាណិជ្ជកម្មពិភពលោក ក្របខ័ណ្ឌអាស៊ាន និង ក្របខ័ណ្ឌនៃគំនិតផ្តួចផ្តើមសមាហរណកម្មសេដ្ឋកិច្ចតំបន់ និង អនុតំបន់ដទៃទៀត ។ បន្ថែមលើនេះ រាជរដ្ឋាភិបាល នឹងបន្តពង្រឹងក្របខ័ណ្ឌគតិយុត្ត សម្រាប់គាំទ្រវិស័យឯកជន រួមមានបទបញ្ញត្តិច្បាប់ និង នីតិវិធីរដ្ឋបាល ការលើកកម្ពស់ផលិតភាពការងារ តាមរយៈការបណ្តុះបណ្តាលបុគ្គលិក អ្នកបច្ចេកទេស និង កម្មករជំនាញការធានាឱ្យមានការប្រកួតប្រជែងដោយយុត្តិធម៌ ការបន្តជំរុញកិច្ចសម្រួលពាណិជ្ជកម្ម ការបន្តពង្រឹងការគោរពច្បាប់ការងារ និង ការពង្រឹងយន្តការដោះស្រាយវិវាទឱ្យមានប្រសិទ្ធភាព ។

**81.** ជាចំណែកមួយដ៏សំខាន់នៃគោលនយោបាយពិពិធភាវូបនីយកម្មមូលដ្ឋានសេដ្ឋកិច្ច រាជរដ្ឋាភិបាល នឹងជំរុញបង្កើតនូវបរិស្ថានអំណោយផល សម្រាប់ការអភិវឌ្ឍវិស័យឧស្សាហកម្មកែច្នៃ និង ម្ហូបអាហារ វិស័យឧស្សាហកម្មគ្រឿងបង្គុំ

រួមមានគ្រឿងបង្គុំអេឡិចត្រូនិច និង គ្រឿងម៉ាស៊ីន ។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាល នឹងបន្តពង្រឹងក្របខ័ណ្ឌគតិយុត្តចាំបាច់ ជាពិសេស ការរៀបចំច្បាប់សម្រាប់កិច្ចដំណើរការតំបន់សេដ្ឋកិច្ចពិសេស ។

**82.** រាជរដ្ឋាភិបាល នឹងបន្តលើកទឹកចិត្តដល់ភាពជាដៃគូរវាងវិស័យសាធារណៈ និង វិស័យឯកជន ក្នុងការវិនិយោគ ជាពិសេសក្នុងគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ។

*មុំទី២. ការបង្កើតការងារ និង ការធានាលក្ខខណ្ឌការងារល្អប្រសើរ*

**83.** ក្នុងនីតិកាលទី ៣ កន្លងទៅ ចំនួនសហគ្រាស និង គ្រឹះស្ថានហិរញ្ញវត្ថុ បានកើនឡើងគួរឱ្យកត់សម្គាល់ ចំនួន ២.៤០០ ហើយស្រូបយកកម្មករនិយោជិតប្រមាណ ៤៤០.៥០០ នាក់ ។ ពលករកម្ពុជាចំនួនជាង ៥០.០០០ នាក់ ត្រូវបានបញ្ជូនទៅធ្វើការនៅបរទេស ។ ការអនុវត្តគោលនយោបាយបើកចំហជើងមេឃ បាននាំឱ្យចំនួនភ្ញៀវទេសចរកើនឡើងយ៉ាងខ្លាំង និង បានបង្កើនការងារជាច្រើនជូនប្រជាពលរដ្ឋយើង ។ សេរីភាពសហជីព ត្រូវបានលើកកម្ពស់ ។ យន្តការត្រួតពិនិត្យការងារ និង ដោះស្រាយវិវាទ ត្រូវបានពង្រឹង ដើម្បីធានាការអនុវត្តច្បាប់ការងារ និង ធានានូវបរិស្ថានការងារប្រកបដោយសុខដុមរមនា ។

**84.** រាជរដ្ឋាភិបាល នឹងបន្តអនុវត្តគោលនយោបាយផ្សារភ្ជាប់ពាណិជ្ជកម្មទៅនឹងលក្ខខណ្ឌការងារ តាមរយៈការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវស្តង់ដារការងារ បទដ្ឋានពលកម្ម និង ច្បាប់ការងារ និង អនុសញ្ញាអន្តរជាតិនានា រួមទាំងការបន្តជំរុញយន្តការ *«រោងចក្រល្អប្រសើរ»* ការនាំចេញពលករទៅបរទេស ការពង្រឹងសមត្ថភាពជំនាញ តាមរយៈការបណ្តុះបណ្តាលវិជ្ជាជីវៈ ឱ្យសមស្របតាមតម្រូវការទីផ្សារ ដោយផ្តោតជាសំខាន់លើមុខសញ្ញាយុវជន ដែលពុំមានលទ្ធភាពបន្តការ

សិក្សានៅសាលាចំណេះទូទៅ ជនពិការ ស្ត្រី ជនបាត់បង់ឱកាស និង ជនជាតិភាគតិច ការកសាងប្រព័ន្ធស្ថិតិការងារ និង ក្របខ័ណ្ឌគុណវុឌ្ឍិជាតិ ការផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវព័ត៌មានស្តីពីតម្រូវការទីផ្សារការងារ ដើម្បីធានាបាននូវចល័តភាពនៃពលកម្ម និង ការពង្រឹងយន្តការដោះស្រាយវិវាទការងារ ដែលមានស្រាប់ ដូចជាក្រុមប្រឹក្សាអាជ្ញាកណ្តាល គណៈកម្មការដោះស្រាយបាតុកម្មកូដកម្មគ្រប់ថ្នាក់ ។

**85.** រាជរដ្ឋាភិបាល នឹងបណ្តុះបណ្តាលអ្នកផ្សះផ្សាវិវាទស្ម័គ្រចិត្ត ក្នុងចំណោមអាជ្ញាធរមូលដ្ឋានសំដៅដោះស្រាយវិវាទប្រកបដោយសន្តិវិធី ដែលធានាបាននូវចីរភាពនៃការងារ និង ពង្រឹងការអនុវត្តច្បាប់ការងារ តាមរយៈការអប់រំបណ្តុះ-បណ្តាល និង ការធ្វើអធិការកិច្ចការងារតាមរោងចក្រសហគ្រាស ដើម្បីពន្យល់ពីលក្ខខណ្ឌការងារ អនាម័យ និង សុខភាព សុវត្ថិភាពការងារ អំពីពលកម្មកុមារ និងអំពីការប្រើប្រាស់ពលករបរទេស ការអនុវត្តសេរីភាពរបស់សហជីពស្របតាមច្បាប់ស្តីពីការងារ និង កសាង *ច្បាប់ស្តីពីសហជីព* ព្រមទាំងក្របខ័ណ្ឌគតិយុត្តស្តីពីតុលាការការងារ តាមរយៈការពិគ្រោះយោបល់ឱ្យបានទូលំទូលាយជាមួយភាគីពាក់ព័ន្ធ ។

*មុំទី៣. ការលើកស្ទួយសហគ្រាសធុនតូច និង មធ្យម*

**86.** រាជរដ្ឋាភិបាល បានកាត់បន្ថយនូវការតម្រូវអប្បបរមា សម្រាប់ការចុះបញ្ជីសហគ្រាសធុនតូច និង មធ្យម និង បានកាត់បន្ថយចំណាយក្នុងការចុះបញ្ជីក្រុមហ៊ុន ។ ប្រព័ន្ធគណនេយ្យ និង របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានកែលម្អឱ្យមានលក្ខណៈសាមញ្ញ ។ កម្ចីដែលផ្តល់ដោយស្ថាប័នហិរញ្ញវត្ថុ សម្រាប់សហគ្រាសធុនតូច និង មធ្យម បានកើនឡើងគួរឱ្យកត់សម្គាល់ ។

87. រាជរដ្ឋាភិបាល នឹងបន្តពង្រឹងបរិស្ថានធុរកិច្ច សម្រាប់អភិវឌ្ឍសហគ្រាសធុនតូច និង មធ្យម ដោយផ្តោតលើទិដ្ឋភាពសំខាន់បួន គឺៈ *(១). ក្របខ័ណ្ឌច្បាប់ និង និយ័តកម្ម* រួមមានការសម្រួលការចុះបញ្ជី ជាពិសេសតាមប្រព័ន្ធអ៊ីនធរណេត ការកំណត់នីតិវិធី និង គោលការណ៍ សម្រាប់ការត្រួតពិនិត្យ និង បញ្ជាក់ពីផលិតផលនាំចេញ និង នាំចូល ការរៀបចំ និង អនុម័តអនុក្រឹត្យស្តីពីការសម្រួលពាណិជ្ជកម្ម តាមរយៈវិធីសាស្ត្រគ្រប់គ្រងហានិភ័យ *(២). ការផ្តល់ហិរញ្ញប្បទាន* រួមមាន ការបង្កើតក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ និង ការពង្រឹងអភិបាលកិច្ច និង របាយការណ៍ហិរញ្ញវត្ថុ *(៣). សកម្មភាពគាំទ្រសហគ្រាសធុនតូច និង មធ្យម* រួមមាន ការលើកស្ទួយនវានុវត្តន៍ និង បច្ចេកវិទ្យា ព្រមទាំងការផ្តល់ហិរញ្ញប្បទានដល់សហគ្រាសធុនតូច និង មធ្យម និង ការពង្រឹង និងពង្រីកសេវាគាំទ្រផ្សេងៗទៀត *(៤). ការបញ្ចូលសហគ្រាសធុនតូច និង មធ្យម* ទៅក្នុងខ្សែសង្វាក់តម្លៃជាសកល និង ការទប់ស្កាត់ការរត់ពន្ធគ្រប់ប្រភេទ ។

**88.** បន្ថែមលើនេះ រាជរដ្ឋាភិបាល នឹងជំរុញអនុវត្តវិធានការថ្មីមួយចំនួនទៀត មានជាអាទិ៍ៈ ការបង្កើតមជ្ឈមណ្ឌលផលិតភាពជាតិ ដើម្បីលើកកម្ពស់ផលិតភាព និង កាត់បន្ថយថ្លៃដើមផលិតកម្ម ការបង្កើតវិទ្យាស្ថានស្តង់ដារជាតិ ដើម្បីធានាបាននូវគុណភាពផលិតផលតាមស្តង់ដារតំបន់ និង អន្តរជាតិ ការបង្កើតមន្ទីរពិសោធន៍ជាតិផ្នែករូបគីមី មីក្រូជីវៈ មេកានិច និង ការធ្វើតេស្ត ដើម្បីកំណត់គុណភាព និងលក្ខណៈវិនិច្ឆ័យផលិតផល ការពង្រឹងយន្តការការពារកម្មសិទ្ធិបញ្ញាឧស្សាហកម្ម ដើម្បីជំរុញតក្កកម្មការប្រើប្រាស់បច្ចេកទេស និង បច្ចេកវិទ្យាថ្មី ព្រមទាំងផលិតផលថ្មី ការលើកកម្ពស់ការបណ្តុះបណ្តាលវិជ្ជាជីវៈ និង ការពង្រឹងប្រព័ន្ធតតិយភូមិ ។

**89.** រាជរដ្ឋាភិបាល បន្តជំរុញចលនា *«ភូមិមួយ-ផលិតផលមួយ»* ដោយបណ្ដុះគំនិតច្នៃប្រឌិត សហគ្រិនភាព និងជំនឿលើខ្លួនឯងនៅតាមទីជនបទ ។ ចលនានេះជាក្របខ័ណ្ឌគ្រប់ជ្រុងជ្រោយមួយ ដើម្បីភ្ជាប់ផលិតកម្មទៅនឹងទីផ្សារ រក្សាអត្តសញ្ញាណតំបន់ លើកទឹកចិត្តឱ្យមានគំនិតផ្តួចផ្តើមថ្មីៗ និង ទូលំទូលាយ តាមរយៈពិពិធកាវូបនីយកម្មប្រភេទមុខទំនិញឱ្យបានច្រើន ។ រាជរដ្ឋាភិបាល ជំរុញការធ្វើវិក្រិត្យការបញ្ជាក់ទេសចំពោះទំនិញ ដែលមានលក្ខណៈពិសេស នៅតាមតំបន់មួយចំនួន ក្នុងន័យពង្រឹងគុណភាព និង ពង្រីកទីផ្សារ ដែលជាចំណុចស្នូល សម្រាប់លើកកម្ពស់ចលនានេះ ឱ្យមានការគាំទ្រ និង ការចូលរួមកាន់តែច្រើនឡើង ។

*មុំទី៤. ការរៀបចំប្រព័ន្ធសុវត្ថិភាពសង្គម*

**90.** ក្នុងនីតិកាលទី ៣ កន្លងទៅនេះ រាជរដ្ឋាភិបាល សម្រេចបាននូវសមិទ្ធផលគួរជាទីកត់សម្គាល់ នៅក្នុងការជួយសង្គ្រោះជនអនាថា ស្ត្រី កុមារ និង ជនរងគ្រោះ ដោយសារការជួញដូរគ្រួសារ ដែលទទួលរងគ្រោះមហន្តរាយ និង ក្នុងការបណ្តុះបណ្តាលវិជ្ជាជីវៈជូនដល់ជនរងគ្រោះ ជនអនាថា និង ជនពិការឱ្យមានមុខរបរផ្ទាល់ខ្លួន និង ឱ្យមានការងារធ្វើ ។

**91.** រាជរដ្ឋាភិបាល បានសហការជាមួយនឹងអង្គការជាតិ អន្តរជាតិ និង ស្ថាប័នពាក់ព័ន្ធនានា ដើម្បីលើកស្ទួយកាលានុវត្តភាពការងារ បន្ថយភាពងាយរងគ្រោះរបស់ប្រជាជនក្រីក្រ ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាល បានកែលម្អ និង ពង្រឹងប្រព័ន្ធសន្តិសុខសង្គម សម្រាប់អតីតមន្ត្រីរាជការស៊ីវិល ក៏ដូចជាអតីតយុទ្ធជន តាមរយៈការដំឡើងប្រាក់ខែ និង ប្រាក់ឧបត្ថម្ភផ្សេងៗ ។

**92.** ក្នុងការបន្តជំរុញអនុវត្តគោលនយោបាយស្តីពីសុវត្ថិភាពសង្គម រាជរដ្ឋាភិបាល នឹងផ្តល់អាទិភាពទៅលើការកែលម្អឱ្យកាន់តែប្រសើរឡើងនូវលក្ខខណ្ឌ

ការងាររបស់កម្មករ និង និយោជិត ការជំរុញអនុវត្តច្បាប់ស្ដីពីរបបសន្តិសុខសង្គម ការអនុវត្តគោលការណ៍ផ្តល់របបសោធននិវត្តន៍ សម្រាប់អ្នកបាត់បង់សមត្ថភាពពលកម្ម និងអ្នកនៅក្នុងបន្ទុក និងជំរុញបន្ថែមទៀតនូវការការពារដល់ជនទាំងឡាយ ដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ការងារ និង ធានាឱ្យនិយោជិតទាំងអស់ទទួល បាននូវការធានារ៉ាប់រងចំពោះគ្រោះថ្នាក់ការងារ ។ រាជរដ្ឋាភិបាល នឹងបន្តពង្រឹងការជួយឧបត្ថម្ភឱ្យបានជិតដល់ចំពោះជនពិការ និង គ្រួសារយុទ្ធជន ដែលបានបូជាជីវិតដើម្បីប្រទេសជាតិ ។ ព្រមជាមួយនេះ រាជរដ្ឋាភិបាល នឹងបន្តជួយគាំទ្រដល់យោធិន និងមន្ត្រីរាជការចូលនិវត្តន៍ តាមរយៈការអនុវត្តប្រព័ន្ធសោធននិវត្តន៍មួយ ដែលមានវិសាលភាពទូលំទូលាយ ដោយបន្តជំរុញអនុវត្ត *បេឡាជាតិសន្តិសុខសង្គម* ។ ក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលនឹងជំរុញអនុមតិ *ច្បាប់ស្តីពីបេឡាជាតិសន្តិសុខសង្គមទូលំទូលាយ* និង *ច្បាប់ស្តីពីការបង្កើតបេឡាជាតិសោធនអតីតយុទ្ធជន* ។

### ***ចតុកោណទី ៤. ការកសាងសមត្ថភាព និង ការអភិវឌ្ឍធនធានមនុស្ស***

#### *មុំទី១. ការពង្រឹងគុណភាពវិស័យអប់រំ*

**93.** រាជរដ្ឋាភិបាល សម្រេចបាននូវវឌ្ឍនភាពគួរជាទីមោទនៈ ក្នុងការអនុវត្តយុទ្ធសាស្ត្រ *«អប់រំសម្រាប់ទាំងអស់គ្នា»* តាមរយៈការធានាសមធមិ ក្នុងការអប់រំមូលដ្ឋានរយៈពេល ៩ ឆ្នាំ សម្រាប់កុមារគ្រប់រូប ។ សមិទ្ធផលធំៗរួមមានៈ ចំនួនសាលារៀន និង គ្រូបង្រៀន ព្រមទាំងអត្រាចុះឈ្មោះចូលរៀន នៅគ្រប់កម្រិតសិក្សានៃចំណេះទូទៅបានកើនឡើងជាលំដាប់ ពិសេសនៅតាមជនបទ ដោយឡែកអនុវិទ្យាល័យ ត្រូវបានបង្កើតឡើងនៅក្នុងស្ទើរគ្រប់ឃុំ សង្កាត់ទូទាំងប្រទេស ។ ចំនួនគ្រឹះស្ថានមធ្យមសិក្សាបច្ចេកទេស និង គ្រឹះស្ថានឧត្តមសិក្សា ព្រមទាំងចំនួន

បុគ្គលិកបង្រៀន ក៏បានកើនឡើងស្របគ្នាដែរ ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាល បានបង្កើនថវិកាយ៉ាងច្រើន សម្រាប់វិស័យអប់រំ ។ ក្នុងនីតិកាលទី ៣ កន្លងទៅនេះ ថវិកាចំណាយចរន្តសម្រាប់វិស័យអប់រំបានកើនឡើងទ្វេដង ក្នុងឆ្នាំ ២០០៧ ធៀបទៅនឹងឆ្នាំ ២០០៣ បើគិតជាភាគរយនៃថវិកាចរន្តសរុបថវិកាចរន្ត សម្រាប់វិស័យអប់រំមានប្រមាណ ១៩,២% ។ រាជរដ្ឋាភិបាល សម្រេចបានជោគជ័យគួរជាទីមោទនៈ ក្នុងការលើកកម្ពស់ភាពជាដៃគូជាមួយដៃគូអភិវឌ្ឍន៍ នៅក្នុងវិស័យអប់រំនេះ រួមទាំងដៃគូផ្តល់ជំនួយ ទាំងវិស័យឯកជន ទាំងអង្គការមិនមែនរដ្ឋាភិបាល ។

**94.** ក្នុងនីតិកាលទី ៤ នេះ រាជរដ្ឋាភិបាលនឹងបន្តអនុវត្ត *ផែនការយុទ្ធសាស្ត្រវិស័យអប់រំ* ដោយផ្តោតលើការផ្តល់ឱកាសស្មើៗគ្នាដល់កុមារ និង យុវជនកម្ពុជាទាំងអស់ ក្នុងការទទួលការអប់រំមូលដ្ឋាននៅក្នុងប្រព័ន្ធ និង ក្រៅប្រព័ន្ធ ដោយមិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើត និង ឋានៈនៅក្នុងសង្គមឡើយ ។ ម៉្យាងវិញទៀត ការអនុវត្តផែនការយុទ្ធសាស្ត្រនេះ ត្រូវផ្សារភ្ជាប់នឹងការអប់រំ វប្បធម៌សន្តិភាព ការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស ការគោរពគោលការណ៍សេរីភាព ប្រជាធិបតេយ្យ និងយុត្តិធម៌ ដោយប្រឆាំងនឹងអំពើហិង្សា ប្រឆាំងនឹងការប្រើប្រាស់គ្រឿងញៀន ការជួញដូរកុមារ ស្ត្រី និង ការរើសអើងគ្រប់ប្រភេទក្នុងសង្គម ។

**95.** រាជរដ្ឋាភិបាល បន្តយកចិត្តទុកដាក់លើការកែលម្អគុណភាពអប់រំ តាមរយៈការលើកទឹកចិត្តគ្រូបង្រៀន ការកែលម្អកម្មវិធីសិក្សា ការលើកទឹកចិត្តសិស្សពូកែ ការបណ្តុះបណ្តាលគ្រូបង្រៀន និង បំប៉នវិធីសាស្ត្របង្រៀន ព្រមទាំងការកែលម្អលក្ខខណ្ឌនៃការសិក្សា និង ការផ្គត់ផ្គង់សម្ភារៈសិក្សា ការបង្កើតបណ្ណាល័យ មន្ទីរពិសោធន៍ ។ ក្នុងទិសដៅធានាកាលានុវត្តភាពប្រកបដោយសមធម៌ រាជរដ្ឋាភិបាល

បន្តបង្កើតអន្តេវាសិកដ្ឋានសម្រាប់សិស្ស- និស្សិត ពិសេសសម្រាប់សិស្ស- និស្សិតជានារីភេទ និង បន្តសាងសង់សាលារៀនគ្រប់កម្រិតសិក្សា ពិសេសនៅតាមតំបន់ជនបទ និង តំបន់ដាច់ស្រយាល និង ការបង្កើនអាហារូបករណ៍សម្រាប់សិស្សនិស្សិតក្រីក្រ ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាល នឹងបន្តបណ្តុះបណ្តាលគ្រូបង្រៀនប្រកបដោយគុណភាពឱ្យបានគ្រប់គ្រាន់ និង អនុវត្តគោលនយោបាយពង្រាយគ្រូឱ្យមានប្រសិទ្ធភាព ។ រាជរដ្ឋាភិបាល នឹងលើកទឹកចិត្តឱ្យគ្រូបឋមសិក្សា និង មធ្យមសិក្សាបឋមភូមិ និង គ្រូដែលបានបន្តរៀនចប់បរិញ្ញាបត្របានប្រឡងចូលក្របខ័ណ្ឌគ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិ ដោយគ្មានកម្រិតអាយុ និង បង្កលក្ខណៈសម្បត្តិឱ្យគ្រូបឋមសិក្សា ដែលមិនទាន់មានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមានលទ្ធភាពប្រឡងយកសញ្ញាបត្រសមមូលមធ្យមសិក្សាទុតិយភូមិ ដើម្បីបើកឱកាសឱ្យពួកគាត់មានលទ្ធភាពរៀននៅថ្នាក់ឧត្តមសិក្សា ឬ ក្រោយឧត្តមសិក្សា និង ផ្លាស់ប្តូរនូវកាំប្រៀវត្សរ៍ ។

**96.** រាជរដ្ឋាភិបាល នឹងបន្តពង្រឹងភាពជាដៃគូជាមួយវិស័យឯកជន ព្រមទាំងសហគមន៍ជាតិ និង អន្តរជាតិ ដើម្បីបង្កើន និង លើកកម្ពស់គុណភាពសេវាអប់រំ ក្នុងនេះ មានការយកចិត្តទុកដាក់បន្ថែមលើការបណ្តុះបណ្តាលផ្នែកព័ត៌មានវិទ្យា និង ភាសាបរទេស ទាំងក្នុងគ្រប់កម្រិតមធ្យមសិក្សាចំណេះទូទៅ ទាំងក្នុងការបណ្តុះបណ្តាលវិជ្ជាជីវៈ និង បច្ចេកទេស និង ទាំងក្នុងកម្រិតឧត្តមសិក្សា ឱ្យស្របទៅនឹងស្តង់ដារអន្តរជាតិ និង តម្រូវការអភិវឌ្ឍ របស់ប្រទេស ។ ពិសេស ជាងនេះទៅទៀត ក្នុងកម្រិតមធ្យមសិក្សាបច្ចេកទេស និង ឧត្តមសិក្សា រាជរដ្ឋាភិបាល បន្តផ្តោតការយកចិត្តទុកដាក់ទៅលើការបណ្តុះបណ្តាលវិស្វករ និង អ្នកបច្ចេកទេស ។ ទន្ទឹមនេះ ដើម្បីកាត់បន្ថយ គម្លាតរវាងការផ្គត់ផ្គង់ និង តម្រូវការការងារ រាជរដ្ឋា-

ភិបាល បន្តអនុវត្តគោលនយោបាយបណ្តុះបណ្តាលវិជ្ជាជីវៈ ផ្សារភ្ជាប់ទៅនឹងទីផ្សារពលកម្ម ដោយសហការយ៉ាងជិតស្និទ្ធជាមួយតួអង្គពាក់ព័ន្ធ តាមរយៈវិធានការដូចតទៅ៖ *(ទី១)*. ផ្តល់ការបណ្តុះបណ្តាលជំនាញមូលដ្ឋានដល់ប្រជាពលករនៅជនបទ ដើម្បីបង្កើនប្រាក់ចំណូល *(ទី២)*. ផ្តល់ការបណ្តុះបណ្តាល ឬ វិក្រឹតការដល់ពលករតាមរោងចក្រ ដោយសហការជាមួយនិយោជក *(ទី៣)*. បន្តជំរុញការអប់រំបណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈ ដោយពង្រីកសេវានេះ ឱ្យទៅដល់ខេត្តក្រុង ក្នុងនោះ មានរួមបញ្ចូលនូវការបណ្តុះបណ្តាលសហគ្រិនភាព ទៅក្នុងកម្មវិធីផងដែរ *(ទី៤)*. ការរៀបចំបង្កើតទីភ្នាក់ងារជាតិមុខរបរ និង ការងារ និង មជ្ឈមណ្ឌលការងារតាមខេត្ត ក្រុង សម្រាប់ជាយន្តការសម្រួលដល់ការផ្សព្វផ្សាយព័ត៌មានទីផ្សារការងារ ។

**97.** រាជរដ្ឋាភិបាល នឹងបន្តពង្រីកការអប់រំក្រៅប្រព័ន្ធ តាមរយៈកម្មវិធីអក្ខរកម្ម និង អក្ខរកម្មវិជ្ជាជីវៈ បង្កើនការសាងសង់មជ្ឈមណ្ឌលសិក្សាសហគមន៍ ព្រមទាំងអនុវត្តកម្មវិធីសមធម៌ ។ រាជរដ្ឋាភិបាល នឹងបន្តបង្កើនចំណាយថវិកា និង កៀរគរហិរញ្ញប្បទានឱ្យបានច្រើនថែមទៀត សម្រាប់គាំទ្រការអប់រំ ដើម្បីធានាគុណភាពអប់រំឱ្យកាន់តែមានកម្រិតខ្ពស់ និង ប្រកបដោយប្រសិទ្ធភាព ។

*មុំទី២. ការលើកកម្ពស់សេវាសុខាភិបាល*

**98.** រាជរដ្ឋាភិបាល បានចាត់ទុកថា សុខភាពប្រជាពលរដ្ឋ គឺជាកត្តាដ៏ចម្បងសម្រាប់ការអភិវឌ្ឍធនធានមនុស្ស និងវឌ្ឍនភាពសង្គម និងសេដ្ឋកិច្ចប្រកបដោយចីរភាព ។ រាជរដ្ឋាភិបាល បានលើកស្ទួយសុខុមាលភាពប្រជាជនទូទៅ ពិសេសប្រជាជនក្រីក្រ ស្ត្រី និង កុមារ ។ ជាលទ្ធផល អត្រាស្លាប់របស់ទារក បានថយចុះពី ៩៥ មកត្រឹម ៦៦ ក្នុង ១០០០ កំណើត ក្នុងចន្លោះរវាងឆ្នាំ ២០០០-២០០៥ ។ អត្រា

ស្លាប់របស់កុមារក្រោមអាយុ ៥ ឆ្នាំ ក៏បានធ្លាក់ចុះគួរកត់សម្គាល់ ។ អត្រាមរណៈរបស់មាតាបានធ្លាក់ចុះពី ៤៧២ មកត្រឹម ៤៣៧ ក្នុង ១០០.០០០ កំណើតរស់ ។ ក្នុងឆ្នាំ ២០០៥ ស្ត្រីជាមាតាលើសពី ៦៥% បានទទួលការថែទាំសុខភាព ដោយបុគ្គលិកសុខាភិបាលមួយដងយ៉ាងតិច មុនពេលសម្រាលកូន ។ អត្រាឆ្លងនៃមេរោគហ៊ីវបានធ្លាក់ចុះជាលំដាប់ ។ អង្កេតប្រជាសាស្ត្រ និង សុខភាព កម្ពុជាឆ្នាំ ២០០៥ បានបង្ហាញថា អត្រាឆ្លងមេរោគហ៊ីវនៃប្រជាជនកម្ពុជា ក្នុងក្រុមអាយុ ១៥- ៤៩ ឆ្នាំ បានថយចុះពី ១,៩% នៅឆ្នាំ ២០០៣ មកត្រឹម ០,៦% នៅឆ្នាំ ២០០៥ ។ នៅក្នុងនីតិកាលទី ៣ កន្លងទៅនេះ ថវិកាចំណាយចរន្ត សម្រាប់វិស័យសុខាភិបាល បានកើនឡើងជាងទ្វេដង ។ ក្នុងឆ្នាំ ២០០៧ ធៀបទៅនឹងឆ្នាំ ២០០៣ បើគិតជាភាគរយនៃថវិកាចរន្តសរុបថវិកាចរន្ត សម្រាប់វិស័យសុខាភិបាលមានប្រមាណ ១០% ។

**99.** ក្នុងនីតិកាលទី ៤ នេះ រាជរដ្ឋាភិបាល បន្តជំរុញអនុវត្តផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាល ក្នុងគោលដៅកាត់បន្ថយអត្រាស្លាប់របស់មាតា និង ទារក និង កែលម្អសូចនាករសុខាភិបាលសំខាន់ៗផ្សេងទៀត តាមរយៈ ការពង្រឹងគុណភាព និង ពង្រីកសេវាសុខាភិបាល ជាពិសេស សេវាសុខភាពបន្តពូជមាតា ទារក និង កុមារ ។

**100.** ក្នុងនេះ រាជរដ្ឋាភិបាល ផ្តោតការយកចិត្តទុកដាក់លើការអនុវត្តកម្មវិធីបង្ការ និង ព្យាបាលជំងឺឆ្លងនានា កសាងមន្ទីរពេទ្យបង្អែក និង មណ្ឌលសុខភាពនៅទូទាំងប្រទេស ដែលអាចផ្គត់ផ្គង់សេវាសុខាភិបាលមូលដ្ឋាន ប្រកបដោយប្រសិទ្ធភាព ចីរភាព សមធម៌ និង បង្កើនគុណភាពវិជ្ជាជីវៈ ។ រាជរដ្ឋាភិបាល បន្តជំរុញកែលម្អការបែងចែកចំនួនវេជ្ជបណ្ឌិត គ្រូពេទ្យមធ្យម ឆ្មប ក្នុងប្រព័ន្ធសុខាភិបាល បង្កើនប្រាក់កម្រៃលើកទឹកចិត្តសម្រាប់ បុគ្គលិកសុខាភិបាលនៅទីជនបទ និង បង្កើនចំនួន

វេជ្ជបណ្ឌិត គ្រូពេទ្យមធ្យម ឆ្មប ។ រាជរដ្ឋាភិបាល បន្តផ្តោតការយកចិត្តទុកដាក់លើការអប់រំ និង ផ្សព្វផ្សាយព័ត៌មានសុខាភិបាល និង អនាម័យឱ្យបានទូលំទូលាយ ពិសេសដល់ជនបទ ព្រមទាំងផ្តល់សេវាដល់ជនក្រីក្រ តាមរយៈមូលនិធិសមធម៌ និង ប្រព័ន្ធធានារ៉ាប់រងសុខភាព ។

**101.** រាជរដ្ឋាភិបាល នឹងបន្តជំរុញអនុវត្តវិធានការចាំបាច់នានា ដើម្បីធ្វើឱ្យសេវាសុខាភិបាលកាន់តែឆ្លើយតប និង ខិតកាន់តែជិតសាធារណជន តាមរយៈការអនុវត្តវិមជ្ឈការលើមុខងារផ្តល់សេវា និង ការធ្វើវិមជ្ឈការការគ្រប់គ្រងទៅឱ្យថ្នាក់ក្រោមជាតិ ដូចជា មន្ទីរពេទ្យជាតិ មន្ទីរពេទ្យបង្អែក និង មណ្ឌលសុខភាព ការបង្កើនវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត បរិក្ខារពេទ្យ និង បច្ចេកវិទ្យា ជាមួយនឹងការលើកកម្ពស់សេវាគាំទ្រផ្សេងៗ ការលើកកម្ពស់ការស្រាវជ្រាវសុខភាព សម្រាប់ការកសាងគោលនយោបាយ ផែនការ ការពិនិត្យតាមដានសមិទ្ធផល និង ការវាយតម្លៃការពង្រឹងអភិបាលកិច្ចទូទាំងវិស័យសុខាភិបាល តាមរយៈការអនុវត្ត *«អភិក្រមគ្របដណ្តប់ទូទាំងវិស័យ»* ដោយត្រូវបង្កើនភាពជាម្ចាស់ និង ពង្រឹងភាពជាដៃគូជាមួយសហគមន៍អន្តរជាតិ ។ ទន្ទឹមនេះ រាជរដ្ឋាភិបាលបន្តលើកកម្ពស់ការចូលរួមរបស់វិស័យឯកជន ដើម្បីបង្កើនការវិនិយោគបន្ថែមទៀត ក្នុងវិស័យសុខាភិបាល និង ការពង្រឹងអន្តរាគមន៍សុខភាពសាធារណៈ ។

### *មុំទី៣. ការអនុវត្តគោលនយោបាយសមភាពយេនឌ័រ*

**102.** រាជរដ្ឋាភិបាល បានចាត់ទុកស្ត្រីជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច និង សង្គមជាតិ ។ រាជរដ្ឋាភិបាលបានអនុវត្តផែនការយុទ្ធសាស្ត្រ *«នារីរតនៈទី ២»* ប្រកបដោយជោគជ័យ ។ រាជរដ្ឋាភិបាល បានជំរុញអនុម័ត និង អនុវត្តច្បាប់ ដើម្បីការពារស្ត្រី រួមមាន *ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និង កិច្ចការពារជនរងគ្រោះ*

និង *ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ* ។ ក្នុងវិស័យអប់រំ រាជរដ្ឋាភិបាលបានកាត់បន្ថយគម្លាតយេនឌ័រ តាមរយៈការបង្កើនការចុះឈ្មោះចូលរៀនរបស់កុមារី ។ ក្នុងវិស័យសុខាភិបាល រាជរដ្ឋាភិបាល បានបង្កើនសេវាសុខភាពបឋម សុខភាពបន្តពូជ អាហារូបត្ថម្ភ ការទប់ស្កាត់នឹងជំងឺគ្រុនចាញ់ និង ការទប់ស្កាត់ការរីករាលដាលនៃជំងឺអេដស៍- ហ៊ីវ ។ រាជរដ្ឋាភិបាល បានបង្កើនតួនាទីរបស់ស្ត្រីក្នុងវិស័យសេដ្ឋកិច្ច និង បានការពារសិទ្ធិរបស់កម្មការិនី តាមរយៈការស្វែងរកការគាំទ្រមតិ និង ការធ្វើអន្តរាគមន៍ផ្នែកគោលនយោបាយ ។ លើសពីនេះ ស្ត្រីទទួលបានជំនាញសមត្ថភាព និង តួនាទី ដើម្បីចូលរួមកាន់តែច្រើនឡើងក្នុងការដឹកនាំ និង ការធ្វើសេចក្តីសម្រេចនៅគ្រប់កម្រិតនៃអភិបាលកិច្ច ។ សមាមាត្រស្ត្រី ដែលបានជាប់ឆ្នោតជាសមាជិករដ្ឋសភាបានកើនដល់ ១៩% នៅឆ្នាំ ២០០៣ ហើយក្នុងឆ្នាំ ២០០៧ សមាជិកក្រុមប្រឹក្សាឃុំសង្កាត់ ១៥% ជាស្ត្រី ហើយបច្ចុប្បន្ន ស្ត្រី ៣០% គឺជាអ្នកដឹកនាំថ្នាក់ភូមិ ។

**103. រាជរដ្ឋាភិបាលនីតិកាលទី ៤ នេះ នឹងបន្តអនុវត្តគោលនយោបាយបង្កើន** កាលានុវត្តភាពឱ្យសិស្ស- និស្សិតនារី បានចូលរៀនឱ្យបានកាន់តែច្រើន តាមរយៈការបង្កើនអាហារូបករណ៍ សម្រាប់សិស្ស- និស្សិតនារី កម្មវិធីបំប៉ននៅគ្រឹះស្ថានសិក្សាការផ្តល់កន្លែងស្នាក់នៅ និង ការធានាសុវត្ថិភាព សម្រាប់សិស្ស- និស្សិតនារី និង ការបង្កើនចំនួនគ្រូបង្រៀនជាស្ត្រី ។ រាជរដ្ឋាភិបាល បន្តលើកតម្កើងតួនាទីរបស់ស្ត្រី ក្នុងការធ្វើសេចក្តីសម្រេចចិត្ត និង យកចិត្តទុកដាក់លើការបណ្តុះ- បណ្តាលមុខជំនាញដល់ស្ត្រីនៅគ្រប់កម្រិត ។ រាជរដ្ឋាភិបាល នឹងបង្កើនសមាមាត្រនៃការចូលរួមរបស់ស្ត្រីឱ្យបានជាអតិបរមា ក្នុងស្ថាប័នជាតិគ្រប់ថ្នាក់ ដោយបន្តពង្រីកឱកាសការងារ សម្រាប់ស្ត្រី និង ណែនាំបណ្តុះបណ្តាលអំពីរបៀបនៃការ

តស៊ូមតិ ក្នុងការឈរឈ្មោះនៅតាមបណ្តាភូមិឃុំទូទាំងប្រទេស ព្រមទាំងការពារសិទ្ធិធ្វើការងាររបស់ស្ត្រី ។

**104.** ដើម្បីកាត់បន្ថយភាពក្រីក្រក្នុងសង្គម រាជរដ្ឋាភិបាល បន្តអនុវត្តគោលការណ៍ផ្តល់ឥណទានខ្នាតតូច និង មធ្យមដល់ស្ត្រី និង សហគមន៍ ដើម្បីបង្កើតមុខរបរចិញ្ចឹមជីវិត ។ ម៉្យាងទៀត ដើម្បីទប់ស្កាត់អំពើហិង្សា និង ការជួញដូរស្ត្រី រាជរដ្ឋាភិបាល នឹងអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និង កិច្ចការពារជនរងគ្រោះ សម្រាប់ផ្តល់នូវការការពារស្របច្បាប់យ៉ាងមានប្រសិទ្ធភាព និង ទាន់ពេលវេលា ដល់ជនរងគ្រោះ ដែលភាគច្រើនជាស្ត្រី និង កុមារ ដោយមានការចូលរួមសហការពីគ្រប់ស្ថាប័នពាក់ព័ន្ធ និង ដៃគូនានា ។

*មុំទី៤. ការអនុវត្តគោលនយោបាយជាតិប្រជាជន*

**105.** លទ្ធផលបឋមនៃជំរឿន ១០ ឆ្នាំម្តង ដែលត្រូវបានធ្វើឡើងកាលពីខែ មីនា ឆ្នាំ ២០០៨ កន្លងទៅថ្មីៗនេះ បានបង្ហាញឱ្យឃើញថា បច្ចុប្បន្នប្រជាជនកម្ពុជាសរុបមានចំនួនប្រមាណ ១៣,៤ លាន នាក់ ក្នុងនោះ ស្ត្រីមានចំនួន ៥១,៥% និង មានប្រជាជនរស់នៅក្នុងទីក្រុង ចំនួន ១៩,៤% ហើយប្រជាជនរស់នៅទីជនបទ មានចំនួន ៨០,៦% ។ ជំរឿននេះ ក៏បានបង្ហាញដែរថា អត្រាកំណើនជាមធ្យមរបស់ប្រជាជនកម្ពុជា ក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ គឺមានប្រមាណ ១,៥៤% ។ សមិទ្ធផលសំខាន់ៗ ដែលសម្រេចបានក្នុងការអនុវត្តគោលនយោបាយជាតិប្រជាជន រួមមាន *(១)*. ស្ត្រីភាគច្រើនមានការយល់ច្បាស់ពីការប្រើប្រាស់មធ្យោបាយពន្យារកំណើត *(២)*. អត្រាលទ្ធភាពផ្តល់កំណើតសរុបបានធ្លាក់ចុះពី ៤,០ នៅឆ្នាំ ២០០០ មកត្រឹម ៣,៤ នៅឆ្នាំ ២០០៥ *(៣)*. ចំនួនកូន ដែលមាន

តាមបំណង គឺស្មើនឹង ៣.៣ សម្រាប់ស្ត្រីម្នាក់ ដែលនាំឱ្យទំហំគ្រួសារមានការរួមតូចជាងមុន ។

**106.** ក្នុងនីតិកាលទី ៤ នេះ រាជរដ្ឋាភិបាល នឹងបន្តកិច្ចខិតខំប្រឹងប្រែង ដើម្បីបញ្ចូលគោលនយោបាយប្រជាជន ទៅក្នុងគោលនយោបាយសង្គម- សេដ្ឋកិច្ច និង ក្នុងផែនការ និង កម្មវិធីនានា នៅគ្រប់កម្រិតទាំងអស់ ។

**107.** រាជរដ្ឋាភិបាល បន្តដាក់ចេញនូវវិធានការចាំបាច់ ដើម្បីពង្រឹងគុណភាពប្រជាជន ដោយលើកកម្ពស់ការអភិវឌ្ឍវិស័យអប់រំ សុខាភិបាល សមភាពយេនឌ័រ និង អភិវឌ្ឍន៍ជនបទជាគោលដៅអាទិភាព ។ ដោយសាររចនាសម្ព័ន្ធប្រជាជនកម្ពុជាមាន ៦០.៨% ជាប្រជាជនមានអាយុក្រោម ២៤ ឆ្នាំ វិធានការនេះ នឹងប្រែក្លាយយុវជន ឱ្យទៅជាកម្លាំងចលករដ៏សំខាន់សម្រាប់ការអភិវឌ្ឍគ្រប់វិស័យ ។ រាជរដ្ឋាភិបាល នឹងពង្រឹងការរៀបចំទីក្រុង និង ទីប្រជុំជននានា ឱ្យក្លាយជាទីក្រុងស្អាត គ្មានសំរាម ប្រកបដោយអនាម័យ បរិស្ថានខ្យល់អាកាសបរិសុទ្ធ និង មាន **ទីវាលឧទ្យានបៃតង ទីធ្លាសម្រាប់កីឡាលំហាត់ប្រាណ និង រៀបចំកម្មវិធីផ្សព្វផ្សាយសិល្បៈវប្បធម៌ជាដើមសម្រាប់ទ្រទ្រង់សុខភាពប្រជាជន ទាំងផ្លូវកាយ និងផ្លូវចិត្ត ។**

## សេចក្តីសន្និដ្ឋាន

**108.** ដំណាក់កាលទី ១ នៃការអនុវត្ត ***យុទ្ធសាស្ត្រចតុកោណ*** គឺជាដំណាក់-កាល ដែលកម្ពុជាសម្រេចបាននូវស្ថិរភាពនយោបាយ កំណើនសេដ្ឋកិច្ចខ្ពស់ ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច កំណើននៃការវិនិយោគ និង លំហូរចូលយ៉ាងច្រើននៃទុនវិនិយោគពីក្រៅប្រទេស ទោះបីជាមានបញ្ហាប្រឈមខាងក្រៅ ដូចជា អតុល្យភាព

នៃសេដ្ឋកិច្ចពិភពលោក និង វិបត្តិហិរញ្ញវត្ថុ រួមមាន ការកើនឡើងនូវថ្លៃប្រេងឥន្ធនៈ និង ស្បៀងអាហារជាដើមក៏ដោយ ។

**109.** ដូច្នេះ ក្នុងរយៈពេលដ៏ខ្លីប៉ុណ្ណោះ រាជរដ្ឋាភិបាលកម្ពុជាសម្រេចបាននូវសមិទ្ធផលដ៏ច្រើន បើប្រៀបធៀបនឹងប្រទេសដទៃទៀត ដែលត្រូវចំណាយពេលវេលាអស់រាប់ទសវត្សរ៍ ។ ទន្ទឹមនេះ រាជរដ្ឋាភិបាលទទួលស្គាល់ថា ក្នុងការឈានទៅសម្រេចឱ្យបានតាមចក្ខុវិស័យនៅក្នុង *យុទ្ធសាស្ត្រចតុកោណ* កម្ពុជានៅត្រូវជួបនឹងបញ្ហាប្រឈម ព្រមទាំងឧបសគ្គជាច្រើន ដែលតម្រូវឱ្យប្រជាជាតិកម្ពុជាទាំងមូលខិតខំបង្កើនជវភាព និង សមត្ថភាពប្រកួតប្រជែងរបស់ខ្លួន ដើម្បីបន្តបោះជំហានទៅមុខ ក្នុងល្បឿនកាន់តែលឿនជាងមុន និង មានប្រសិទ្ធភាពជាងមុន ។ យ៉ាងណាក៏ដោយ ផ្អែកលើសមិទ្ធផលសម្រេចបានកន្លងមក ផ្អែកលើសក្តានុពលដ៏ធំធេងរបស់កម្ពុជា ផ្អែកលើឆន្ទៈដ៏មោះមុត និង ទេពកោសល្យរបស់ប្រជាជនកម្ពុជា ព្រមទាំងផ្អែកលើសមត្ថភាពក្នុងការរៀនសូត្រ ការដកស្រង់នូវបទពិសោធន៍ ការតម្រឹម ការបន្សាំ និង ការចេះជ្រើសយកវិធានការចាំបាច់របស់រាជរដ្ឋាភិបាល និង របស់ប្រជាជនកម្ពុជាទាំងមូល រួមជាមួយនឹងយុទ្ធសាស្ត្រដ៏ត្រឹមត្រូវ ដែលបានដាក់ចេញមកនេះ រាជរដ្ឋាភិបាល មានជំនឿយ៉ាងមុតមាំថា កម្ពុជានឹងជំនះបាននូវរាល់បញ្ហាប្រឈម និង ឧបសគ្គទាំងឡាយ នៅលើមាគ៌ាឆ្ពោះទៅកាន់វឌ្ឍនភាព ។

**110.** ក្នុងស្មារតីនេះ រាជរដ្ឋាភិបាល ខិតខំពុះពារឱ្យអស់ពីសមត្ថភាព ដើម្បីសម្រេចបាននូវគោលដៅជាអាទិភាពក្នុងនីតិកាលទី ៤ នេះ ដូចខាងក្រោម៖

***ទី១.*** ការធានាឱ្យបាននូវចីរភាពសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និង សណ្តាប់ធ្នាប់សង្គម សំដៅលើកស្ទួយនីតិរដ្ឋ ការពារសិទ្ធិ និង សេចក្តីថ្លៃថ្នូររបស់មនុស្ស និង លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ។

***ទី២.*** ការធានាឱ្យបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ក្នុងអត្រាប្រមាណ ៧% ក្នុងមួយឆ្នាំ នៅលើមូលដ្ឋានទូលាយជាងមុន និង មានសមត្ថភាពប្រកួតប្រជែងជាងមុន នៅក្នុងបរិការណ៍អត្រាអតិផរណាទាប ក្នុងកម្រិតតួលេខមួយខ្ទង់ ។

***ទី៣.*** ការធានាសម្រេចឱ្យបាននូវការកាត់បន្ថយអត្រានៃភាពក្រីក្រ ឱ្យបានលើស ១% ក្នុងមួយឆ្នាំ និង ការធានាកែលម្អសូចនាករសំខាន់ៗ ក្នុងវិស័យសង្គមកិច្ច ជាពិសេស ក្នុងវិស័យអប់រំ សុខាភិបាល និង សមភាពយេនឌ័រ ។

***ទី៤.*** ការធានាបង្កើនវិសាលភាព ប្រសិទ្ធភាព និង គុណភាពនៃសេវាសាធារណៈ ឱ្យកាន់តែប្រសើរឡើង ហើយទទួលបាននូវការជឿទុកចិត្ត ។

សសសសសសស

*ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ ដែលជាសមាជិក- សមាជិកានៃអង្គគណៈរដ្ឋមន្ត្រីទាំងមូល ជាទីមេត្រី !*

**111.** ខ្ញុំបានដាក់ចេញនូវ ***«យុទ្ធសាស្ត្រចតុកោណ» ដំណាក់កាលទី ២*** នេះ ដែលជារបៀបវារៈគោលនយោបាយសង្គម- សេដ្ឋកិច្ចនៃ ***«កម្មវិធីនយោបាយ»*** របស់រាជរដ្ឋាភិបាលនីតិកាលទី ៤ នៃរដ្ឋសភា ។ យុទ្ធសាស្ត្រនេះ នឹងត្រូវអនុវត្តតាមរយៈ ***ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ*** ដែលនឹងក្លាយជាមធ្យោបាយដ៏សំខាន់ ក្នុងការអនុវត្តបន្តនូវចក្ខុវិស័យនៃការកសាងសង្គមកម្ពុជាមួយ ដែលមានសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និង សណ្តាប់ធ្នាប់សង្គម មានការអភិវឌ្ឍប្រកបដោយចីរភាព និង សមធម៌ ជាមួយនឹងការគោរពយ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍ប្រជាធិបតេយ្យសេរីពហុបក្ស ការគោរពសិទ្ធិ និង សេចក្តីថ្លៃថ្នូររបស់មនុស្ស

មានកោសិកាផ្សារភ្ជាប់គ្នា មានប្រជាជនប្រកបដោយចំណេះដឹងខ្ពស់ និង វប្បធម៌ព្រៀងព្រៃ មានជីវភាពសមរម្យ និង មានការរស់នៅប្រកបដោយសុខដុមរមនា ទាំងក្នុងសង្គមជាតិ ទាំងក្នុងក្រុមគ្រួសារ ដែលប្រការទាំងអស់នេះ នឹងលើកស្ទួយព្រះរាជាណាចក្រកម្ពុជា ឱ្យមានកិត្យានុភាពរុងរឿងលើឆាកអន្តរជាតិ ។

**112.** ខ្ញុំសូមអំពាវនាវដល់ដៃគូអភិវឌ្ឍន៍ទាំងអស់ ដែលក្នុងនោះរួមមានដៃគូទ្វេភាគី និង ពហុភាគី វិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងថ្នាក់ដឹកនាំ មន្ត្រីរាជការនៅតាមបណ្តាក្រសួង និង ស្ថាប័ននានា អង្គនីតិបញ្ញត្តិ អង្គនីតិប្រតិបត្តិ តុលាការ កងកម្លាំងប្រដាប់អាវុធ អាជ្ញាធរដែនដី និង ជនរួមជាតិទាំងអស់ សូមផ្តល់ការគាំទ្រ និង យកចិត្តទុកដាក់ចូលរួមចំណែកយ៉ាងសកម្មជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការអនុវត្តគោលនយោបាយ និង កម្មវិធីនានាក្នុងក្របខណ្ឌនៃ ***«យុទ្ធសាស្ត្រចតុកោណ» ដំណាក់កាលទី ២*** នេះ ។

**113.** ខ្ញុំសូមបញ្ជាក់សាជាថ្មីម្តងទៀតថា ប្រជាជនកម្ពុជាបានបោះឆ្នោតផ្តល់ជំនឿទុកចិត្តមកលើយើងទាំងអស់គ្នា ដើម្បីដឹកនាំប្រទេសជាតិ និង បម្រើប្រជាជន ក្នុងរយៈពេលប្រាំឆ្នាំបន្តទៀត ។ ដូច្នេះ យើងមានកាតព្វកិច្ចរែកពន្ធនូវការទទួលខុសត្រូវ ដើម្បីធានាឱ្យបាននូវសន្តិភាព ស្ថិរភាព វឌ្ឍនភាព និងវិបុលភាព សម្រាប់បំពេញតាមបំណងប្រាថ្នារបស់ប្រជាជន ។ យើងទាំងអស់គ្នាត្រូវប្តេជ្ញាប្រឹងប្រែងយ៉ាងខ្លាំងក្លាបំផុត ក្នុងនាមជាសហសេវិកនៅក្នុងរាជរដ្ឋាភិបាល ដែលប្រកបដោយសាមគ្គីភាព កិច្ចសហការល្អ និង សុខដុមរមនា ដើម្បីដោះស្រាយបញ្ហាប្រឈមនានានៅចំពោះមុខ ។ ខ្ញុំជំរុញលើកទឹកចិត្តដល់សហសេវិកទាំងអស់ ឱ្យបំពេញភារកិច្ចរៀងៗខ្លួន តាមស្មារតីនេះ ដើម្បីសម្រេចឱ្យបាននូវគោលដៅរួមរបស់យើង ដោយទុកផលប្រយោជន៍បុគ្គលដោយឡែក និង តម្កល់ផលប្រយោជន៍

របស់ប្រជាជនជាធំ ។ យើងត្រូវចងចាំជាប់ជានិច្ចនៅក្នុងអារម្មណ៍របស់យើងនូវរូបភាពរបស់គ្រួសារសាមញ្ញនៃប្រជាជនកម្ពុជា រួមមាន ប្ដី ប្រពន្ធ កូន ឪពុក ម្ដាយចាស់ជរា ដែលកំពុងតែតស៊ូប្រឹងប្រែង ដើម្បីជីវភាពប្រចាំថ្ងៃរបស់ខ្លួន ហើយបានបោះឆ្នោតជូនដល់រាជរដ្ឋាភិបាល ឱ្យជួយកែលម្អជោគវាសនារបស់ពួកគេទាំងអស់គ្នា ។ ច្បាស់ណាស់ថា ភារកិច្ចចំពោះមុខរបស់យើងទាំងអស់គ្នា ពិសេស គឺភារកិច្ចនៃការលុបបំបាត់ភាពក្រីក្រ មិនអាចសម្រេចបានក្នុងរយៈពេលតែមួយថ្ងៃ ឬ មួយឆ្នាំនោះឡើយ ។ យើងត្រូវជំរុញអនុវត្តនូវសកម្មភាពប្រទាក់ក្រឡាគ្នា ប្រកបដោយចិរភាពជាប់មិនដាច់ នៅក្នុងគ្រប់ការដ្ឋានទាំងអស់ ដើម្បីសម្រេចបានវឌ្ឍនភាពនៅក្នុងបេសកកម្មនេះ ។

**114.** គ្មានគោលដៅអ្វីសំខាន់ជាងគោលដៅនៃការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជននោះទេ ហើយក៏គ្មានភារកិច្ចអ្វីដែលត្រចះត្រចង់ជាងនេះដែរ ។ ប្រជាជនកម្ពុជា នឹងចងចាំយើង គឺមិនមែនដោយសារតែវោហាសាស្ត្ររបស់យើងនោះទេ ប៉ុន្តែ គឺដោយសារស្នាដៃជាក់ស្ដែង និង សមិទ្ធផលល្អៗ ដែលយើងសម្រេចបាន ។ ការបំពេញការងារដោយមិនគិតពីប្រយោជន៍ផ្ទាល់ខ្លួន ដើម្បីលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជន គឺជាស្នាដៃ និង ជាគុណសម្បត្តិពិតៗរបស់យើងទាំងអស់គ្នា ។ ជាថ្មីម្ដងទៀត ខ្ញុំសុំឱ្យសហសេវិកទាំងអស់យកយុទ្ធ-សាស្ត្រនេះ ទៅអនុវត្តក្នុងទឹកចិត្តស្មោះត្រង់ និង ឆន្ទៈប្ដូរផ្ដាច់បំផុត ឱ្យអស់ពីសមត្ថភាព ឱ្យមានប្រសិទ្ធភាពខ្ពស់ និង ឱ្យទទួលបានលទ្ធផលជាផ្លែផ្កាល្អ ។

**115.** ខ្ញុំសូមប្រសិទ្ធពរជូនដល់សហសេវិកទាំងអស់ នូវពុទ្ធពរទាំងបួនប្រការ និងសូមសម្រេចបានជោគជ័យ ក្នុងគ្រប់ភារកិច្ចជូនជាតិ និង មាតុភូមិ ។ *ពេលវេលា*

បន្ទាន់ណាស់ ហើយសង្ខេបយើងណាស់ ខ្ញុំសូមប្រកាសចាប់ផ្តើមអនុវត្ត «យុទ្ធ-សាស្ត្រចតុកោណ» ដំណាក់កាលទី ២ ពីពេលនេះតទៅ ។

សូមអរគុណ!

## Rectangular Strategy Diagram

